

ឧប សៅ សង្ហា

# ចិត្តគំនិតខ្មែរ និង កំឈែនម្រង់

## មាតិកា

សេចក្តីផ្តើម ..... 4
ធម្មជាតិ នៃ អរិយធម៌ ..... 6
អរិយធម៌ខ្មែរ ..... 14
គ្រួសារ ខ្មែរ ..... 21
ភូមិ ខ្មែរ ..... 25
ជំនឿ និង សាសនា ..... 26
ការគោរព ចំពោះ មេ-បា ..... 27
ការគោរព ចំពោះ នាង គង្ហីង និង ក្រពើ ..... 30
ជំនឿ ចំពោះ អ្នកតា ..... 32
ព្រហ្មញ្ញ សាសនា ..... 35
ពុទ្ធ សាសនា ..... 36
វិវត្តិន៍ នៃ ព្រហ្មញ្ញ សាសនា និង ពុទ្ធ សាសនា ..... 38
ក. សម័យ នគរ ភ្នំ (ស.វ. ទី១ ដល់ ទី៦) ..... 38
ខ. សម័យ ចេនឡា (ស.វ. ទី៦ ដល់ ទី៨) ..... 38
គ. សម័យ មហា នគរ (ស.វ. ទី៨ ដល់ ទី១៥) ..... 39
ភាសា ខ្មែរ ..... 42
អក្សរ ខ្មែរ ..... 44

អក្សរសិល្ប៍ ខ្មែរ ....................................................... 46
សិល្បៈ ខ្មែរ ....................................................... 49
ស្ថាប័ន ជាតិ ខ្មែរ ....................................................... 50
ទ្រឹស្តី នៃ វត្ថុធាតុ ៧ យ៉ាង ទុក ជា បតិដ្ឋាប័ន នៃ រដ្ឋ ....... 52
ភាពទូទៅ នៃចិត្តគំនិត ....................................................... 57
សង្គមពហុវិជ្ជា ....................................................... 57
កំណែទម្រង់ជាសាកល ....................................................... 59
ចំណេះដឹងថ្មី នៃវិទ្យាសាស្ត្រ ....................................................... 65
ចិត្តគំនិតខ្មែរ ....................................................... 70
មូលដ្ឋានគ្រឹះ នៃជាតិខ្មែរ ....................................................... 73
ប្រពៃណី ....................................................... 73
ភាសា និង អក្សរ ....................................................... 75
ពុទ្ធសាសនា ....................................................... 80
គតិ នៃ អភិរក្សនិយម ....................................................... 84
ការកែទម្រង់ ....................................................... 99
ឯណា គ្រោះថ្នាក់ សំរាប់ ប្រជាជាតិ ខ្មែរ ? ....................................................... 99
ដាន នៃ កំណែទម្រង់ នាពេល កន្លងមក ....................................................... 108
តើ ខ្មែរ អាច ធ្វើ អ្វី បាន ? ....................................................... 120
ចប់ ....................................................... 123

# សេចក្តីផ្តើម

វប្បធម៌ ខ្មែរ បង្កើត ជា ចំណេះដឹង គ្រប់ វិស័យ របស់ ប្រជាជាតិ ខ្មែរ។ តែ បើ វប្បធម៌ ស្ថិត នៅ ក្នុង រង្វាស់ ដែល គេ យល់ ឃើញ ខុស, វាយ តម្លៃ ស្រាល, បំបែក ចេញ ជា ផ្នែក ជ្រើសរើស ដាច់ៗ គ្នា វា អាច នាំ បង្កើត ជា វិបត្តិ ដល់ ជាតិ ព្រមគ្នា នឹង វិបត្តិ យល់ ដឹង របស់ ប្រជាពលរដ្ឋ។ ប្រព័ន្ធ នៃ ចំណេះដឹង បែប នេះ នៅ ក្នុង សង្គម នីមួយៗ ដែល បុព្វបុរស គ្រប់ ជាតិ សាសន៍ បាន បង្រៀន ហើយ ចំណេះដឹង នេះ ត្រូវ បាន ឆ្លាក់ នៅ ក្នុង ស្មារតី សង្គម ដែល វា នាំ ឱ្យ មាន ការយល់ច្រឡំ ដ៏ ច្រើន។ វិធី បែប យល់ស្រាល ឬ ជ្រើសរើស ដាច់ៗ គ្នា នេះ បាន ធ្វើ ឧនាភិវឌ្ឍន៍ នៃ សមត្ថភាព ធ្វើ បរិបទកម្ម (contextualiser) នៃ ការ បង្កើត ព័ត៌មាន និង ធ្វើ បូរណកម្ម (intégrer) ដែល មិន អាច នឹង ផ្តល់ នូវ ការយល់ដឹង ទាំងមូល។ ជា ឧទាហរណ៍ បញ្ញាជន ខ្មែរ ច្រើន តែ លើក យកសម័យ រុងរឿង នៅ សម័យ មហា នគរ ខ្មែរ មក ធ្វើ បរិបទកម្ម ក្នុង ស្មារតី ខ្មែរ សព្វ ថ្ងៃ នេះ ថា ខ្មែរ អាច ប្រត្យាស្ថាបនា ឲ មាន ឡើង វិញ បាន។ គំនិត ស្រាល ឬ ជ្រើសរើស ដាច់ៗ គ្នា បែប នេះ វា មិន បង្ហាញ នូវ ការពិត ទាំង អស់ ទេ នៅ ក្នុង ការផ្សាយព័ត៌មាន សំរាប់ ចំណេះដឹង ខ្មែរ ព្រោះ សម័យ រុងរឿង ពី អតីតកាល និង សម័យ បច្ចុប្បន្ន វា

មាន បរិបទ ខុស គ្នា ស្រឡះ ទាំង រូបភាព និង ស្មារតី ដែល មិន អាច យក វា មក ធ្វើ សមាហរណកម្ម តាម ការប្រៀបធៀប គ្នា បាន ជា ដាច់ខាត។ ដូច្នេះ ការសិក្សា ប្រវត្តិសាស្ត្រ ជាតិ មិន មាន គោលដៅ បង្រៀន មេរៀន ដើម្បី ទាញ យក បទ ពិសោធន៍ ដើម្បី ធ្វើ ត្រាប់ តាម នោះ ទេ។ ការពិត វា គ្រាន់ ជា ការបង្ហាញ នៃ រូបភាព នៃ ព្រឹត្តការណ៍ ពិត មួយ និង បរិបទ មួយ នៅ ពេល ក្នុង ពេល នឹងថ្កល់ មួយ ដែល អ្នក សិក្សា ត្រូវ ដឹង ដើម្បី ជា ចំណេះដឹង សំរាប់ យល់ដឹង អំពី បច្ចុប្បន្ន មិន ឋិតថេរ។ ភាព មិន ឋិតថេរ នៃ បច្ចុប្បន្នកាល នេះឯង ដែល តម្រូវ ឱ្យ មាន ការយល់ដឹង អំពី អតីតកាល ព្រោះ ចំណុច នៃ ទី កន្លែង ទាំង ពីរ នេះ វា មាន ការវិវត្តន៍ ជា តំណាក់កាល ហើយ បន្ត វិវត្ត ទៅ អនាគតកាល ដែល គ្មាន នរណា អាច ដឹង ជា មុន បាន។ គ្មាន អ្វី ដែល ស្ថិតស្ថេរ ឡើយ, ដូច្នេះ យក ចំណេះ ដឹង ដែល មាន កន្លង មក យក មក ធ្វើ ត្រាប់ វា មិន អាច បង្កើត ចំណេះដឹង ទាំងមូល សំរាប់ បច្ចុប្បន្នកាល នោះ បាន ឡើយ។ ត្រូវ ដឹង ថា ការ យក មក ធ្វើ ត្រាប់ និង យក មក ធ្វើ ជា ចំណេះដឹង ទាំងមូល វា ខុស គ្នា ស្រឡះ : មួយ គ្មាន ការ ពិចារណា មួយទៀត មាន ការពិចារណា នៅ ក្នុង បរិបទ និង បរិស្ថានថ្មី។

# ធម្មជាតិ នៃ អរិយធម៌

ប្រវត្តិសាស្ត្រ នៃ មនុស្សលោក គឺ ជា ប្រវត្តិសាស្ត្រ នៃ អរិយធម៌។ ដូច នេះ វា ពុំ អាច យល់ បាន អំពី ការវិវត្តន៍ នៃ អរិយធម៌ នៃ មនុស្សជាតិ តាំង ពី អរិយធម៌ បុរាណ ដូច ជា អរិយធម៌ នៃ ជនជាតិ សុហ្មះ (Suhma), ជនជាតិ អេស៊ីប រហូត មក ដល់ អរិយធម៌ នៃ សាសនាគ្រិស្ត និង សាសនាអ៊ីស្លាម ឆ្លងកាត់ តាម អរិយធម៌ បរេណី និង មេសូ-អាមេរិកាំង (méso-américaine) និង បន្ត រហូត មក ដល់ អរិយធម៌ ចិន និង ឥណ្ឌូ តាម ទម្រង់ ប្លែកៗ គ្នា ដោយ ពុំ បាន អាន និង សិក្សា ប្រវត្តិសាស្ត្រ នៃ មនុស្សជាតិ នោះឡើយ។ អរិយធម៌ ទាំងឡាយ នោះ ហើយ ដែល ផ្តល់ អោយ មនុស្សលោក នូវ លក្ខណៈ វិនិច្ឆ័យ សំខាន់ សំរាប់ សំគាល់ ខ្លួន តាម ដំណើរ នៃ ប្រវត្តិសាស្ត្រ នៃ មនុស្សជាតិ។ ប្រវត្តិវិទូ ជា ច្រើន បាន សិក្សា ជា ជម្រៅ អំពី អរិយធម៌ និមួយៗ ហើយ យក មក ប្រៀបធៀប គ្នា ទុក ជា ចំណេះចេះដឹង សំរាប់ មនុស្សជាតិ។ ក៏ ប៉ុន្តែ អ្នកប្រាជ្ញ ទាំង នោះ មាន ការព្រមព្រៀង រវាង គ្នា អំពី គោលការណ៍ សំខាន់ មួយ ចំនួន ស្តី ពី ធម្មជាតិ, អត្តសញ្ញាណ និង ថាមវ័ន្ត នៃ អរិយធម៌។ ជា បឋម គឺ ការបែងចែក ពាក្យ អរិយធម៌ (civilisation)

ក្នុង ន័យ ឯកវចនៈ និង អរិយធម៌ ទាំងឡាយ (civilisations)[1] ក្នុង ន័យ ពហុវចនៈ។ គំនិត នៃ អរិយធម៌ ត្រូវ បាន ចិន្តបណ្ឌិត[2] បារាំងសែស (penseurs français) មួយ ចំនួន យក មក ប្រើ ក្នុង សតវត្សទី១៨ ក្នុង ទស្សនៈ ផ្ទុយ នឹង ពាក្យ អមនុស្សធម៌។ តាម ទស្សនៈ របស់ ចិន្តបណ្ឌិត ទាំងឡាយ នោះ សង្គម អារ្យធម៌ ខុស ពី សង្គម អនារ្យធម៌ ស្ថិត នៅ លើ ស្ថាប័ន មាន ការជឿនលឿន ក្នុង បូរី និង កំរិត នៃ ការអប់រំ របស់ ប្រជាជន។ មនុស្ស មាន អារ្យធម៌ ជា មនុស្សល្អ, មនុស្ស គ្មាន អារ្យធម៌ ជា មនុស្ស មិនល្អ។ ទស្សនៈ នេះ ផ្តល់ នូវ បទដ្ឋាន ហើយ នៅ អំឡុង សតវត្សទី ១៩ ពួក ជនជាតិ អ៊ឺរ៉ុប ធ្វើ សមារម្ភ ដោយ ប្រើ ថាមពល បញ្ញា, ទូត និង នយោបាយ ជា ច្រើន ដើម្បី យក បទដ្ឋាន នោះ សំរាប់ វាយ តម្លៃ ថា សង្គម ណា ពុំ មែន ជា សង្គម មស្ទីម ហើយ មិន សូវ មាន អរិយធម៌ តើ អាច ទុក បាន ជា សមាជិក ក្នុង ប្រព័ន្ធ អន្តរជាតិ គ្រប់គ្រង ដោយ ទ្វីបអ៊ឺរ៉ុប បាន ដែរ ឬទេ ? គួរ កត់ សំគាល់ ថា បទដ្ឋាន នោះ ដែរ ដែល មស្ទីម ប្រទេស យក ទៅ ផ្សាយ នៅ ប្រទេស អាណានិគម ក្នុង បេសកកម្ម នៃ អរិយធម៌ របស់ ខ្លួន គឺ ថា ទុក អរិយធម៌ មស្ទីម ជា អរិយធម៌ ខ្ពង់ខ្ពស់ ដោយ ប្រៀប ធៀប នឹង អរិយធម៌ ដទៃ ទៀត នៅ ក្នុង លោកិយ នេះ។

[1] ដើម្បី សំរួលក្នុងការសរសេរ របស់យើង នៅទីនេះ យើង សន្មតប្រើពាក្យ អរិយធម៌ (civilisation) ក្នុងន័យ ឯកវចនៈ និង អរិយធម៌ទាំងឡាយ (civilisations) ក្នុងន័យ ពហុវចនៈ។

[2] ចិន្តបណ្ឌិត : អ្នកមានគំនិតជ្រៅ ; អ្នកប្រាជ្ញ។

ក្រោយ មក ពួក ចិន្តបណ្ឌិត មស្ទឹម ចាប់ ផ្ដើម និយាយ បន្តិច ម្ដងៗ អំពី អរិយធម៌ ទាំងឡាយ ក្នុង ន័យ ពហុវចនៈ គឺ ថា ចាប់ ផ្ដើម ទទួល ស្គាល់ នូវ អត្តតម្លៃ នៃ អរិយធម៌ នីមួយៗ។ នៅ ក្នុង ទស្សនៈ ថ្មី នេះ គឺ ពួក គេ សន្មត បោះបង់ចោល គំនិត ទុក អរិយធម៌ ជា ឧត្តមគតិ តែ មួយ គត់ តែ ជា ឧត្តម គតិ ទូទៅ ហើយ ក៏ ឈប់ យល់ឃើញ ថា អរិយធម៌ មាន បទដ្ឋាន តែ មួយ គត់ ដែរ សំរាប់ តែ ប្រជាពលរដ្ឋ មួយ ចំនួន តូច ឬ សំរាប់ តែ ក្រុម មួយ ដែល ទុក ជា ‹វេជី នៃ មនុស្សជាតិ[3]›, នេះ ជា រូបមន្ត របស់ លោក Braudel ជា ប្រវត្តិវិទូ បារាំងសែស។ ម្លោះ ហើយ គំនិត ថា មាន អរិយធម៌ សាកល តែ មួយ គេ មិន អាច ការពារ វា បាន ទៀត ឡើយ។

តែ ពួក ចិន្តបណ្ឌិត អាលឺម៉ង់ នៅ សតវត្ស ទី១៩ យល់ឃើញ ថា អរិយធម៌ ជា អង្គភាព មួយ របស់ វប្បធម៌។ ក្នុង ទស្សនៈ នេះ ពួកគេ ចែក ដាច់ អរិយធម៌ ពី វប្បធម៌ គឺ ថា អរិយធម៌ គឺ រាប់ បញ្ចូល តែ យន្តសាស្ត្រ, បច្ចេកវិជ្ជា និង កត្តា នៃ សម្ភារៈ ដទៃ ទៀត, ចំណែក វប្បធម៌ គឺ ពាក់ ព័ន្ធ នឹង តម្លៃ, ឧត្តមគតិ, គុណភាព នៃ បញ្ញា និង សីលធម៌ របស់ សង្គម មួយ។ ទស្សនៈ នេះ ស្ថិត នៅ ក្នុង គំនិត អាលឺម៉ង់ រហូត មក ដល់ សព្វ ថ្ងៃ នេះ តែ ជា ទស្សនៈ មួយ គ្មាន ការយល់ព្រម ជា ទូទៅ នោះឡើយ។ រហូត ដល់ មាន ពួក នរវិទូ ខ្លះ យក វា មក បកស្រាយ បញ្ច្រាស

3 វេជី នៃ មនុស្សជាតិ ; élite de l’humanité។

ថា សង្គម នៅ សម័យ ដើម មួយ មាន ស្ថិរភាព តែ គ្មាន ទីក្រុង គឺ ជា សង្គម បង្ហាញ ចរិត លក្ខណៈ របស់ ខ្លួន តាម វប្បធម៌, ចំណែក សង្គម ដែល រួម បញ្ចូល របស់ ជា ច្រើន[4], មាន ការ ជឿនលឿន, មាន ទីក្រុង ហើយ ជា សង្គម ថាមវ័ន្ត គឺ ជា សង្គម ផ្សំផ្គុំ នូវ អរិយធម៌ ផ្សេងៗ ជា ច្រើន។ ដូច្នេះ អរិយធម៌ វា ជា សារព័ន នៃ ភីយេ្យាភាព របស់ សង្គម។ តាម គំនិត របស់ លោក Fernand Braudel បំណង ចង់ ចែក វប្បធម៌ ពី អរិយធម៌ វា គ្រាន់ តែ ជា គំនិត ចង់ បំភាន់ (idée illusoire) តែ ប៉ុណ្ណោះ។

អរិយធម៌ និង វប្បធម៌ យក តាម របៀប រស់នៅ ជា ទូទៅ គឺ អរិយធម៌ ជា វប្បធម៌ រីកសាយ ន័យ តែ ប៉ុណ្ណោះ។ ន័យ ទាំង ពីរ នោះ បញ្ចូល នូវ ‹តម្លៃ, បទដ្ឋាន, ស្ថាប័ន និង វិធី នៃ គំនិត ដែល មនុស្សលោក ពី ទំនាន់ មួយ ទៅ ទំនាន់ មួយ ទៀត រស់ នៅ ដោយ ជាប់ ចិត្ត ជា ខ្លាំង នៅ ក្នុង សង្គម ដែល រៀងៗ ខ្លួន កំពុង រស់នៅ។ តាម លោក Braudel អរិយធម៌ ជា ‹ ទីលំហ› (un espace) នៃ ‹ដំបន់ វប្បធម៌ មួយ› និង ការប្រមូលរួម នៃ លក្ខណៈ និង បាតុភូត នៃ វប្បធម៌ មួយ ចំនួន »។ តាម លោក Wallerstein វិញ អរិយធម៌ គឺ ការប្រមូលរួម ជា កំណត់ ច្បាស់លាស់ នៃ ចក្ខុវិស័យ នៃ លោកា[5] ដូច យ៉ាង ទំនៀមទំនាប់, រចនាសម្ព័ន្ធ និង វប្បធម៌ ក្នុង ន័យ សម្ភារៈ និយម ក៏ដូច

[4] សង្គម ដែលរួមបញ្ចូលរបស់ជាច្រើន ; société plus complexe។
[5] ប្រមូលរួម ជាកំណត់ច្បាស់លាស់ នៃ ចក្ខុវិស័យ នៃ លោកា ; concaténation bien déterminée de vision du monde។

ក្នុង ន័យ ខ្ពង់ខ្ពស់ ដែល ផ្សំផ្គុំ ជា ប្រភេទ មួយ នៃ ប្រវត្តិសាស្ត្រ ហើយ រួមរស់ (ទោះ បី នៅ ក្នុង ពេល វេលា ខុស គ្នា ក្ដី) ជា មួយ បាតុភូត ផ្សេងៗ ទៀត។ តាម លោក Dawson អរិយធម៌ ជា ផលា នៃ អភិក្រមដើម (processus original) នៃ ការបង្កើត ដំបូង នៃ វប្បធម៌ ដែល ជា ស្នាដៃ ផ្ទាល់ ខ្លួន នៃ ប្រជាពលរដ្ឋ មួយ។ ចំណែក លោក Durkheim និង Mauss វិញ លោក មាន ទស្សនៈ ថា អរិយធម៌ ជា ប្រការ មួយ នៃ មជ្ឈដ្ឋាន សីលធម៌ រួម បញ្ចូល នៃ ប្រជាជាតិខ្លះ, វប្បធម៌ ជាតិ និមួយៗ គ្រាន់ តែ ជា ទម្រង់ ពិសេស បូករួម ចូលគ្នា តែ មួយ។ តាម លោក Spengler អរិយធម៌ គឺ ជា វាសនា មិន អាច ជៀស បាន នៃ វប្បធម៌, ជា កំរិត នៃ ការជឿនលឿន ជាង គេ ខាង ក្រៅ និង សិប្បនិម្មិត ជាង គេ ដែល មនុស្សជាតិ អាច ធ្វើ បាន, ជា សេចក្ដី សន្និដ្ឋាន, ជា ផលា នៃ ការបង្កើត ផល។ វប្បធម៌ ជា វត្ថុ ធាតុ រួម តាម គ្រប់ និយមន័យ អ្វី អាច មាន បាន នៃ អរិយ ធម៌។

អរិយធម៌ ទាំឡាយ គ្មាន ព្រំដែន ច្បាស់លាស់ នោះឡើយ, គ្មាន ដើម គ្មាន ចុង ពិតប្រាកដ។ គេ អាច អោយ និយមន័យ ជា ថ្មី អំពី អត្ថសញ្ញាណ នៃ អរិយធម៌ ទាំងឡាយ លុះត្រា តែ ការផ្សំ និង ទម្រង់ របស់ វា ដូរ តាម ខ្សែ នៃ ពេលវេលា។ វប្បធម៌ ទាំងឡាយ ធ្វើ អន្តរប្រតិកម្ម រវាង គ្នា និង គង លើ គ្នា ហើយ ភាព ខុស គ្នា និង ភាព ដូច គ្នា រវាង វប្បធម៌ ដែល ជា របស់ អរិយធម៌ ផ្សេងៗ គ្នា វា អាច ផ្លាស់ ប្ដូរ បាន។ អរិយធម៌

ទាំងឡាយ ក៏ ដូច ជា អង្គភាព ទាំងឡាយ ដែល មាន ន័យ ជាក់លាក់ ទុក ណា ជា ព្រំដែន រវាង គ្នា កម្រ មាន សីមា ច្បាស់លាស់ ក៏ វា នៅ មាន អត្តភាព និមួយៗ របស់ វា ពិតប្រាកដ។

អរិយធម៌ ទាំងឡាយ ទំនង ជា អាច នឹង ស្លាប់ តែ វា មាន ជីវិត ពិបាកក្រៃ ក្នុង ដំណើរ ជីវិត របស់ វា, វាវិវត្ត, សម្រួល ខ្លួនឯង ហើយ បង្កបង្កើត គ្រប់ របៀប នៃ នរសមាគម ដ៏ រឹងប៉ឹងបំផុត។ គឺ របស់ ពិត នៃ អរិយធម៌ ទាំងឡាយ ដែល មាន រយៈពេល ដ៏ យូរ នោះ ឯង ជា អត្តរស់ ទោល និង ពិស្ដា របស់ វា នៅ ក្នុង និរន្តរភាព នៃ ប្រវត្តិសាស្ត្រ ដ៏ យូរ អង្វែង។ អរិយធម៌ទាំងឡាយ គឺ តាម ការណ៍ពិត ជា ប្រវត្តិសាស្ត្រ ដ៏ វែង ឆ្ងាយនោះ ឯង។ រាជាធិរាជាណាចក្រ កើត ស្លាប់, របប ដឹកនាំ ជាតិប្ដូរ និង វិលត្រឡប់ មក វិញ តែ អរិយធម៌ ឋិត នៅ ដដែលហើយ រស់នៅ ជា និច្ច ក្រោយ ពី កើត មាន អំពើ មិន ទៀង នៃនយោបាយ, នៃ សង្គម, នៃ សេដ្ឋកិច្ច ហើយ នឹង អំពើ នៃមនោគមវិជ្ជា ដែរ។ ម្លោះហើយ អរិយធម៌ ធំ ចម្បង ទាំងឡាយនៅ ក្នុង សតវត្ស ទី២១ នេះ មាន តាំង ពី ច្រើន សហស្សវត្សមក ម្លេះ ដូចយ៉ាង អរិយធម៌ ចិន, ជប៉ុន, ឥណ្ឌូ, អ៊ីស្លាម (musulmane), មស្ជិមប្រទេស, អាមេរិឡាទិន ជាអាថ៍។

អរិយធម៌ ទាំងឡាយ ជា អង្គភាព នៃ សីលធម៌, វា មិនមែន ជាអង្គភាព នៃ នយោបាយ នោះ ឡើយ។ ម្លោះហើយ វា គ្មាន មុខ

ងារ ជា សារវ័ត្រ[6], អ្នកច្បាប់, ភ្នាក់ងារ ទារពន្ធ, អ្នក ដឹកនាំ សង្គ្រាម, មន្ត្រី ទូត និង អ្នក រដ្ឋការ នោះឡើយ។ ការផ្សំ នៃ នយោបាយ នៃ អរិយធម៌ ទាំងឡាយ ប្រែប្រួល រវាង គ្នា និង ទៅ តាម ពេលវេលា។ អរិយធម៌ មួយ អាច ប្រមូល អង្គភាព នៃ នយោបាយ តែ មួយ ឬ ជា ច្រើន ដូចយ៉ាង ជា បូរី, រដ្ឋ, រាជាធិរាជាណាចក្រ, សហព័ន្ធ, សម្ព័ន្ធ, រដ្ឋ-ប្រជាជាតិ ឬ រដ្ឋ-ពហុប្រជាជាតិ ហើយ អង្គភាព ទាំងនោះ រើស យក សណ្ឋាន នៃ ការ ដឹកនាំ ផ្សេងៗ គ្នា។ លុះ ចំណេរ មក ធម្មជាតិ នៃ អង្គភាព នៃ នយោបាយ ដែល ផ្សំ ក្នុង អរិយធម៌ អាច ដូរ។ នឹង អាច និយាយ បាន ដែរ ថា អរិយធម៌ និង អង្គភាព នៃ នយោបាយ វា អាច ជាប់គ្នា។ សម័យ អង្គរ វា ជា អរិយធម៌ ដែល ជា រដ្ឋ, ចំណែក ប្រទេស ជប៉ុន វិញ ក៏ ជា អរិយធម៌ ដែល ជា រដ្ឋ នោះ ដែរ។

ប្រវត្តវិទូ ម្នាក់ៗ រក ឃើញ ចំនួន អរិយធម៌ ធំ ចម្បង សព្វថ្ងៃ និង អតីតកាល ខុស គ្នា ដូចយ៉ាង លោក Braudel ថា មាន ៧ អរិយធម៌ ធំៗ, លោក Toynbee ថា មាន រហូត ដល់ ទៅ ២៣ តែ ប្រវត្តិវិទូ ទាំងឡាយ នោះ មាន ទស្សនៈ ស្រប គ្នា ថា ពិត ជា មាន អរិយធម៌ ធំ ចម្បង និង បរិមណ្ឌល (périphérique) នៅ ក្នុង លោក នេះ។ ដូច នេះ អរិយធម៌ ធំៗ ទាំងឡាយ តាម លោក Braudel មាន ដូច ខាង ក្រោម នេះ : អរិយធម៌ អ៊ីស្លាម, ខ្មែរ,

[6] សារវ័ត្រ ; responsable de l’ordre ou maintien de l’ordre។

ទ្វីប អាហ្វ្រិក ខ្មៅ, ចុង បូព៌ា ប្រទេស (ចិន បុរាណ និង ចិន សព្វថ្ងៃ, ឥណ្ឌា បុរាណ និង សព្វថ្ងៃ), ចុង បូព៌ា ប្រទេស នៃ សមុទ្រ (ឥណ្ឌូចិន, ឥណ្ឌូណេស៊ី, ហ្វីលីពិន, កូរ៉េ និង ជប៉ុន), អឺរ៉ុប, អាមេរិក, អឺរ៉ុប ដទៃ ទៀត (មូស្គូវី, រុស្សី, សហភាព សូវៀត)។

# អរិយធម៌ខ្មែរ

អ្នក ប្រវត្តិសាស្ត្រ ខ្មែរ ជា ច្រើន ធ្លាប់ បាន សរសេរ អំពី អរិយធម៌ ខ្មែរ ជា ភាសាជាតិ ដូច ព្រះភិក្ខុ ប៉ាង ខាត់, លោកស្រី ត្រឹង ងា, លោក ទាវ ឆៃសុខ, លី ឆាមតេង, ដែល ជា ស្នាដៃ សំរាប់ អប់រំ យុវជន អោយ ស្គាល់ និង យល់ដឹង ច្បាស់លាស់ អំពី តម្លៃ ជាតិ ខ្លួន ដែល ជា ប្រជាជាតិ ធ្លាប់ មាន អរិយធម៌ ខ្ពង់ខ្ពស់ នៅ ក្នុង ពិភពលោក បាន ទុក ស្នាម ជា វត្ថុធាតុ ពិត (éléments objectifs) ដូចយ៉ាង ភាសា, ប្រវត្តិសាស្ត្រ, សាសនា, ប្រពៃណី, ស្ថាប័ន និង វត្ថុធាតុ អត្តវិស័យ (éléments subjectifs) ដូចយ៉ាង ស្វ័យ អត្តសញ្ញាណកម្ម គឺ ថា ការស្គាល់ ខ្លួន ដោយ ខ្លួន ឯង ជា ខ្មែរ ដែល ខ្មែរ យើង តែង ហៅ ថា ព្រលឹង ជាតិ របស់ ខ្មែរ។ តែ យើង ដឹង ថា អ្នក ជំនាញ ខាង អរិយធម៌ ខ្មែរ គឺ អ្នក ប្រាជ្ញ បរទេស មួយ ចំនួន ដែល បាន សិក្សា-ស្រាវជ្រាវ វា យ៉ាង ជម្រៅ តាម គោលវិធី វិទ្យាសាស្ត្រ ដើម្បី បង្ហាញ នូវ តម្លៃ ខ្ពង់ខ្ពស់ នៃ អរិយធម៌ ខ្មែរ ក្រោយ ពី អរិយធម៌ នោះ លាក់ ខ្លួន បាត់ឈឹង នៅ ក្នុង ព្រហារ៉ៃន (forêt profonde) អស់ ច្រើន សតវត្ស។ តែ អ្នក ប្រាជ្ញ បរទេស ទាំង នោះ សន្និដ្ឋាន ថា អរិយធម៌ ខ្មែរ ជា និស្សន្ទវត្ថុ (dérivée) នៃ អរិយធម៌ ឥណ្ឌូ ដែល ជា អរិយធម៌ កើតឡើង តាំង ពី ១៥០០

ឆ្នាំ មុន គ.ស.។ ត្រូវ ដឹង ថា អរិយធម៌ ឥណ្ឌា នេះ មាន អត្ថ ប្រយោជន៍ ជា វត្ត ជា សាសនា ផង ប្រព័ន្ធ សង្គម ផង ហើយ ន័យ ពាក្យ ឥណ្ឌូ គឺ ជា អរិយធម៌ នៃ ភារៈ ជា អ្នក បំភ្លឺ ផ្លូវ។ យ៉ាងនេះ គេ ឃើញ មាន វប្បធម៌ ដែល មាន ចង ព័ន្ធ នឹង អរិយធម៌ ឥណ្ឌូ បាន ហូរ ចេញ ពី ប្រទេស ឥណ្ឌា ចូល មក ក្នុង ដំបន់ អាស៊ី ភាគ អគ្នេយ៍ ឬ ក្នុង ដែន សុវណ្ណភូមិ[7]។ មាន ទស្ស នៈ ខ្លះ ហ៊ាន ប្រកាស ថា ខ្មែរ ជា ឥណ្ឌា ទី២ ព្រោះ យល់ ឃើញ ថា  ជាតិខ្មែរ ជា ជាតិ ប្រវេសន៍ ចេញ ពី ប្រទេស ឥណ្ឌា ហើយ បាន មក លុកលុយ ដណ្ដើម យក ទឹកដី របស់ ជាតិ ដើម មួយ គឺ ជនជាតិ ក្នុង អំបូរ ម៉ាឡាយូ ប៉ូលី នេស៊ីយែន ឬ ជនជាតិ ថៃ កាដៃ ប៉ុន្តែ ជា ជាតិ មួយ ដោយ ឡែក ពី ឥណ្ឌា ហើយ ស្ថិត នៅ ក្នុង អំបូរ មន-ខ្មែរ។ តែ មាន ទស្សនៈ ខ្លះ យល់ ឃើញ ថា ជាតិ ខ្មែរ ជា ជាតិ ពិសេស មួយ ស្ថិត នៅ ក្នុង អំបូរ មន-ខ្មែរ ហើយ បាន កើត ឡើង នៅ ភូមិភាគ អាស៊ី អាគ្នេយ៍ នេះ តែ ម្តង[8]។

គេ ដឹង ថា នៅ ឥណ្ឌូចិន ជនជាតិ ខ្មែរ ជា ម្ចាស់ ទឹកដី ដើម គេ បំផុត។ គួរ កត់ សំគាល់ ថា ទោះ បី ខ្មែរ និង មន បែក ឆ្ងាយ ពី គ្នា ប្រមាណ ជិត ១៥០០ ឆ្នាំ មក ហើយ ក៏ ដោយ ក៏ ភាសា មន វប្បធម៌ មន ទំនៀមទម្លាប់ មន ខ្លះ នៅ តែ មាន ទ្រង់ទ្រាយ ដូច ខ្មែរ ដដែល។ ដូច្នេះ គេ អាច ពោល អះអាង ថា

[7] ដែន សុវណ្ណភូមិ គឺ ស្រុកខ្មែរ, ថៃ, ភូមា និង លាវ។
[8] សូមរកអាន សៀវភៅមួយ មានចំណងជើងថា ប្រទេសខ្មែរ (C.M.G – Promo-Khmer) បានសរសេររៀបរាប់យ៉ាងក្បោះក្បាយ អំពី ដើមកំណើតខ្មែរ។

នា បុព្វសម័យ មន និង ខ្មែរ ជា អំបូរ តែ មួយ។ ប្រមាណ ជិត ៣០០០ ឆ្នាំ មុន គ.ស. ជនជាតិ មន មក រស់ នៅ ក្នុង ប្រទេស ភូមា សព្វថ្ងៃ។ នៅ សតវត្ស ទី២ មុន គ.ស. ជនជាតិ មន បាន បង្កើត ព្រះរាជាណាចក្រ មួយ ឈ្មោះ ថា សុវណ្ណភូមិ មាន រាជ ធានី នៅ ថាតុន (Thatön) លើ ឈូង សមុទ្រ មាតាបង់ (Martaban)។ ហើយ នៅ ខាង ជើង ប្រទេស ថៃ បច្ចុប្បន្ន ជន ជាតិ មន បាន បង្កើត ព្រះរាជាណាចក្រ មួយ ដែរ នៅ សតវត្ស ទី៨ ឈ្មោះ Haripunjaya។ តាម ទស្សនៈ លោក កេង វ៉ាន់សាក់ ខ្មែរ និង មន មាន ឈ្មោះ ខុស គ្នា ព្រោះ បាន ជ្រើសរើស ទី កន្លែង សំរាប់ រស់នៅ ខុស គ្នា តែ ប៉ុណ្ណោះ។

តាម ឯកសារ ចិន របស់ អ្នក ដំណើរ ចិន ម្នាក់ មក ដល់ ស្រុក ខ្មែរ ក្នុង សតវត្ស ទី៣ ថា ស្រុកខ្មែរ ឈ្មោះ នគរ ហ្វូណន មាន ដែន ដី ចម្ងាយ ៣០០០ លី ខាង លិច ប្រទេស លីយី ដូច្នេះ ដែន ដី ហ្វូណន គឺ ស្ថិត នៅ លើ ទឹកដី កម្ពុជាក្រោម សព្វថ្ងៃ នេះ។ តាម ទស្សនៈ ប្រវត្តិវិទូ បារាំងសែស ឈ្មោះ G. Cœdès ថា ពាក្យ នេះ ក្លាយ ចេញ ពី ពាក្យ ខ្មែរ « វ្នំ » ដែល សព្វថ្ងៃ ក្លាយ ជា ភ្នំ ដូច នេះ ស្រុកខ្មែរ ជំនាន់ ដើម មាន ឈ្មោះ ថា នគរ ភ្នំ។ តាម ឯកសារ ចិន ដដែល នោះ ថា នគរ ហ្វូណន់ មាន ស្តេច ស្រី មួយ អង្គ សោយរាជ្យ ព្រះនាម លីវ យី។ ប្រជាជន ខ្មែរ គោរព បូជា នាគ ដែល គេ ចាត់ ទុក ជា អាទិទេព។ ដូច្នេះ ហើយ បាន ជា

នៅ ក្នុង ពង្សាវតារ ខ្មែរ គេ ច្រើន តែ និយាយ អំពី នាង នាគ ស្តេច នាគ និង នាម៉ឺន នាគ។

តាម ឯកសារ ប្រវត្តិសាស្ត្រ ផ្សេងទៀត កត់ ទុក ថា មាន ព្រាហ្មណ៍ ម្នាក់ ឈ្មោះ ហ៊ុន ទៀន បាន លើក ទ័ព តាម សំពៅ កាត់ឆ្លង តាម សមុទ្រ ចូល មក វាយ ប្រហារ លុកលុយ កាន់កាប់ ត្រួតត្រា នគរ ហ្វូណន ហើយ បាន រៀបអភិសេក ជា មួយ នឹង នាង លីវ យី ហើយ បាន ឡើង សោយរាជសម្បត្តិ នៅ នគរ ហ្វូណន ចាប់ ពី ថ្ងៃ នោះ មក។ មាន ឯកសារ ផ្សេង ទៀត ថា ប្រមាណ ជិត ៥០ ឆ្នាំ ក្រោយ គ.ស. មាន ព្រាហ្មណ៍ ក្លឹង ម្នាក់ ឈ្មោះ កៅណ្ឌិន្យ មក ពី ប្រទេស មាលាយូ (Malaisie) ដែល ជាដែនដី អាណានិគម ពួក ឥណ្ឌា នៅ សម័យនោះ បាន វាយ លុកលុយ តាម ផ្លូវ សមុទ្រ នគរ ហ្វូណន ហើយ ច្បាំង ឈ្នះ ស្តេច ស្រី នគរ នោះ ព្រះនាម លីវ យី។ បន្ទាប់ មក ព្រាហ្មណ៍ កៅណ្ឌិន្យ បាន ឡើង គ្រង រាជសម្បត្តិ ហើយ បាន រៀបអភិសេក ជា មួយ នឹង ស្តេច ស្រី លីវ យី តែ ម្តង។ ចាប់ ពី ពេលនោះ មក ភាសា សំស្ក្រឹត បាន ក្លាយ ជា ភាសា ផ្លូវការ របស់ ខ្មែរ ហើយ រាជវាំង (la cour) មាន រូបភាព បេះបិទ នឹង រាជានិយម ឥណ្ឌា, ការ រៀប ចំសង្គម គឺ ឈរ លើ ប្រព័ន្ធ នៃ វណ្ណៈ នៃ ព្រាហ្មញ្ញ សាសនា ជា ពិសេស វណ្ណៈ ក្សត្រិយៈ, ព្រាហ្មណៈ, វៃស្សៈ និង សូទ្រៈ តែ ការ អនុវត្តន៍ មិន សូវ តឹងរ៉ឹង ដូច នៅ ឥណ្ឌា នោះ ទេ ព្រោះ មិន ចង់ អោយ មាន ទំនាស់ នឹង ទំនៀមទំលាប់ របស់ អ្នក ស្រុក អាយ។ ទោះបី របៀប និទានរឿង មាន សភាព ប្លែកៗគ្នា ក៏

ដោយ គេ អាច សន្និដ្ឋាន បាន ថា តួអង្គ ហ៊ុន ទៀន ឬ កៅណ្ឌិន្យ ជា មនុស្ស តែ មួយ។ ក៏ ដូច ជា តួអង្គ ព្រះថោង គឺ ជា តួអង្គ កៅណ្ឌិន្យ នៅ ក្នុង រឿង ព្រះថោង-នាងនាគ និង នៅក្នុង ពង្សាវតារ ខ្មែរ ទៀត ដែរ។ រឿងព្រេង ខ្មែរ ទាំង នោះ ឯង បង្ហាញ នូវ លក្ខណ: រួម មួយ គឺ ការហូរចូល វប្បធម៌ ឥណ្ឌា មក ក្នុង ស្រុកខ្មែរ នាំ បង្កើត បាន នូវ វប្បធម៌ ចំរុះ មួយ ដែល បាន វិវត្តន៏ រហូត មក ដល់ សព្វថ្ងៃ នេះ។ ដូច នេះ ខ្មែរ អាច សួរ ជា សំនួរ ថា តើ អរិយធម៌ ខ្មែរ ដើម មាន គុណភាព បែប យ៉ាង ណា ដែរ ? មុន នឹង ឆ្លើយ នឹង សំនួរ នេះ គួរ គប្បី ពិនិត្យ អំពី ធាតុ នៃ អរិយធម៌ ដើម្បី បំភ្លឺ ការសាកល្បង ពិចារណា បន្ត របស់ យើង។

នៅ ទី នេះ យើង លើក យក តែ លក្ខណ: សំខាន់ៗ នៃ អរិយធម៌ ខ្មែរ មក អធិប្បាយ ដូចយ៉ាង គ្រួសារ, ភូមិ, សាសនា, ភាសា, អក្សរ, អក្សរសិល្ប៍, សិល្ប:, អ្នក ចេះដឹង និង ស្ថាប័ន ជាតិ។ ប្រវត្តិវិទូ បរទេស ចែក អរិយធម៌ ជា ពីរ កាល សម័យ ធំៗ : កាល សម័យ បរិ ប្រវត្តិសាស្ត្រ និង កាល សម័យ ប្រវត្តិសាស្ត្រ។ តែ កាល សម័យ ដែល គេ យក ចិត្ត ទុកដាក់ ខ្លាំង គឺ សម័យ អង្គរ ដែល ជា សម័យ រុងរឿង នៃ ជនជាតិ ខ្មែរ។ ប្រវត្តិវិទូ មាន យោបល់ ខុស គ្នា អំពី ប្រភាព នៃ ជាតិសាសន៏ ខ្មែរ។ ជា សង្ខេប វា មាន បី ទស្សន: ខុស គ្នា : ទស្សន:ទី១ ថា ខ្មែរ ជា ជនជាតិ ឥណ្ឌា ទី២ ផ្ញើ ទេសន្តរប្រវេសន៏ ពី ឥណ្ឌា មក រស់នៅ ដំបន់ សុវណ្ណភូមិ មុន គេ; ទស្សន: ទី២ គឺ ថា ជនជាតិ ខ្មែរ ពិត មែន

តែ មាន ប្រភព ចេញ ពី ឥណ្ឌា ពិត មែន តែ ជា ជនជាតិ ខុស ពី ជនជាតិ ឥណ្ឌា ទាំងស្រុង នាំ គ្នា ចាកចេញ ពី ឥណ្ឌា មក រស់នៅ តំបន់ ឥណ្ឌូចិន មុន គេ; ទស្សនៈ ទី៣ គឺ ជនជាតិ ខ្មែរ មាន កំណើត នៅ លើ ទឹកដី របស់ ខ្លួន តែ ម្ដង តែ បាន ទទួល ឥទ្ធិពល ពី អរិយធម៌ ឥណ្ឌា។ តែ ទោះ បី ទស្សនៈទាំង បី នេះ ខុស គ្នា យ៉ាង ណា ក៏ ដោយ តែ ចំណុច រួម មួយ គឺ យល់ ស្រប គ្នា ថា ជនជាតិ ខ្មែរ ជា ជនជាតិ រស់នៅ មុន គេ នៅ តំបន់ មជ្ឈឹម និង ដែនដី សណ្ដ នៃ ទន្លេ មេគង្គ ដូច ជា ទឹកដី ប្រទេស ថៃ សព្វថ្ងៃ រហូត ទៅ ដល់ សមុទ្រ ចិន។ តាម សៀវភៅ[9] សរសេរ ដោយ លោក សាស្ត្រាចារ្យ វិជ្ជបណ្ឌិត ថាច់ ទាន់, ស្រុក ខ្មែរ ជា ស្រុក មាន នគរ បូរី ចំណុះ ជា ច្រើន ស្ថិន នៅ ក្រោម អំណាច រាជាណាចក្រ អធិរាជ មួយ។ ដូច ជា រាជាណាចក្រ អង្គរ បូរី ដែល ចិន ហៅ ថា ហ្វូណន ក្រោយ ឆ្នាំ ៦៣០ ក្រោយ គ្រិស្ត សករាជ ត្រូវ បាន សមន្តរាជ របស់ ខ្លួន ឈ្មោះ កម្ពុជា វាយ បញ្ចូល ក្នុង រដ្ឋ កម្ពុជា រួច ក្លាយ ជា រាជាណាចក្រ អធិរាជ តែ ម្ដង។ ដី ដើម កំណើត នៃ នគរ ហ្វូណន គឺ អតីត ទឹកដី កូសាំង ស៊ិន បារាំងសែស ឬ វៀតណាម ខាងត្បូង មាន រាជធានី នៅ ស្រុក អង្គរបូរី ក្នុង ខេត្ត តាកែវ សព្វថ្ងៃ[10]។ នគរ ហ្វូណន មាន នគរ ចំណុះ ជា ច្រើន បណ្ដា នគរ ទាំង នោះ មាន នគរ ចេន

[9] Thach Toan : Histoire des Khmers, Edition L'Harmattan.
[10] លោក G. Coedès មានទស្សនៈផ្សេងថា រាជធានី នគរហ្វូណន ឈ្មោះ វ្យាធបុរ ស្ថិននៅ បាភ្នំ នៅក្នុងខេត្ត ព្រៃវែង នៅក្បែរ ស្រុក បាណាម ទៅវិញ។ ទស្សនៈនេះ ខុសពី លោក Claude Jacques ថានៅ អង្គរបូរី ក្នុងខេត្តតាកែវ ព្រោះថា នៅបាភ្នំ គេគ្មានឃើញទាល់តែសោះ នូវ ស្នាម នៃ អត្ថភាព រាជធានី ឈ្មោះ វ្យាធបុរ នោះ។

ឡា។ ទី កំណើត ចេនឡា គឺ នៅ ត្រង់ ជ្រលងភ្នំ រំយអែត និង ទន្លេមូល ដែល ជា ដៃ ទន្លេ នៃ ទន្លេ មជ្ឈិម មេកុង ហើយ លាត សន្ធឹង ទៅ ខាង ត្បូង ដោយ ប្រើ នយោបាយ វាត ទឹកដី ជា និច្ច រហូត លេប បាន ទឹកដី នគរ ហ្វូណន ទាំងមូល។ នៅ សតវត្សរ៍ ទី៥-ទី៦ នគរ ចេនឡា មាន ទឹកដី ផ្នែង ខាង ជើង ទាំងអស់ នៃ ប្រទេស ថៃ គឺ ខេត្ត នគរ រាជសីមា, អ៊ូបុន, ឧត្តន និង រំយអែត និង ពាក់ កណ្តាល ខាង ត្បូង នៃ ប្រទេស លាវ នូវ មួយផ្នែក ធំ ខាង ជើង នៃ ស្រុកខ្មែរ សព្វថ្ងៃ គឺ ខេត្ត ស្ទឹងត្រែង ក្រចេះ និង ខាងត្បូង នៃ ខេត្តកំពង់ធំ។

ជន ខ្មែរ មាន សម្បុរ ស្រអែម មាន កំពស់ មធ្យម ១,៦១ ម៉ែត្រ មាន ភ្នែក បើក ធំ, ច្រមុះ ទូលាយ, ក្បាល ពយ មាន រាងកាយ សមរម្យ[11]។ ខុស ពី ឯកសារ បុរាណ ចិន សរសេរ ដោយ ជន ចិន ឈ្មោះ k'ang T'ai អំពី ជនជាតិ ខ្មែរ នៅ សម័យ ហ្វូណន ថា ‹ ប្រជាជន ហ្វូណន ជា មនុស្ស មាន រាយកាយ អាក្រក់ មាន សក់ ក្រញាញ់ ហើយ ចេញ ដើរ ទៅ ណា មក ណា ទាំង អាក្រាត តែ មិន លួច ជា ដាច់ ខាត។ ជន ខ្មែរ ដាក់ ម្ហូបចំណី នៅ ក្នុង ភាជន៍ ធ្វើ អំពី ប្រាក់ ហើយ នៅ ក្នុង ផ្ទះ នីមួយៗ មាន ទូដាក់ សៀវភៅ និង បណ្ណសារ ផ្សេងៗ។ ដូច នេះ ប្រជាជន ខ្មែរ សម័យ

11 ក្នុងសៀវភៅ លោក P.W. Schmid (Les peuples Mon-Khmer) បោះពុម្ពផ្សាយនៅឆ្នាំ ១៩០៨។

នោះ ពុំ មែន ជា មនុស្ស ព្រៃផ្សៃ តែ ជា មនុស្ស មាន វឌ្ឍនាការ លឿន ទៅ មុខ ហើយ។

ជនជាតិ ខ្មែរ ហៅ ឈ្មោះ នគរ ខ្លួន ថា ‹ស្រុកខ្មែរ› គឺ ថា ស្រុក របស់ ជនជាតិ ខ្មែរ នោះ បើ មាន ឈ្មោះ នគរ ជា ផ្លូវការ ថា កម្ពុជា និង ឈ្មោះ ដែល ចិន ចារ នៅ ក្នុង ឯកសារ បុរាណ ថា ហ្វូណន និង ចេនឡា ក៏ ដោយ។

ផ្ទះ ខ្មែរ ជា ផ្ទះ មាន សសរ ចន្ទល់ ពី ២ ទៅ ៤ ខ្នង មាន កំពស់ ច្រើន តែ ២ ម៉ែត្រ មាន ជណ្ដើរ សំរាប់ ឡើង លើផ្ទះ ព្រម នឹង កាំជណ្ដើរ ចំនួន សេស ជា និច្ច។

## គ្រួសារ ខ្មែរ

គ្រួសារ ខ្មែរ ស្ថិត នៅ ក្រោម អំណាច មាតា (មតេយ្យកា)។ អ្វី ដែល ទុក ជា ឧត្តុងឧត្ដម ខ្មែរ ហៅ ថា មេ មាន ន័យ ថា មាតា ជា អ្នក ដឹកនាំ។ លោក សាស្ត្រាចារ្យ វិជ្ជបណ្ឌិត ថាច់ ទាន់ សេ សេរ ពន្យល់ យ៉ាង ពិស្ដា អំពី ប្រព័ន្ធ នៃ មតេយ្យកា នៅ ក្នុង សៀវភៅ របស់ លោក ដែល យើង យក ខ្លឹម គំនិត មួយ ចំនួន មក អធិប្បាយ នៅ ទី នេះ។ អ្នក ខ្លះ យល់ ឃើញ ថា ប្រព័ន្ធ មតេយ្យកា ខ្មែរ គឺ ស្ថិត នៅ លើ សេរីភាព របស់ ស្ត្រី ជ្រើសរើស បុរស ជា ស្វាមី ឬ ជា ដៃគូ សំរាប់ រួមរក្ស តែ ប៉ុណ្ណោះ ដូច ប្រព័ន្ធ នៃ ពហុស្វាមី មាន នៅ ទីបេ និង ឥណ្ឌា ៖ ជា រឿយៗ គឺ ស្ត្រី ម្នាក់

រៀបការ ជា មួយ បុរស ច្រើន នាក់ ដែល ជា បងប្អូន នឹង គ្នា ព្រោះ គេ លើក យក លេស ថា កុំ អោយ បែក សម្បត្តិ គឺ ចែក ដី នៅ ក្នុង គ្រួសារ ដែល ជា ដី មូលដ្ឋាន នៃ សេដ្ឋកិច្ច គ្រួសារ។ នៅ ក្នុង ឯកសារ ជន ចិន ឈ្មោះ Tcheou Ta Kouan[12] មាន សរសេរ ថា : នៅ ក្នុង គ្រួសារ ខ្មែរ បើ មាន កើត កូន ស្រី គេ អោយ ពរ ថា សូម អោយ កូន ស្រី នេះ មាន ស្វាមី មួយ រយ ឬ មួយ ពាន់ ស្វាមី។ តែ ស្រុកខ្មែរ បុរាណ មិន មាន រហូត ដល់ ទៅ ប្រព័ន្ធ នៃ ពហុស្វាមី នោះ ទេ តែ វា អាច មាន នៅ ត្រឹម តែ លើ សេរីភាព ស្ត្រី ជ្រើសរើស ស្វាមី តែ ប៉ុណ្ណោះ ដែល ជា សេរីភាព សារពើ នៅ ក្នុង ប្រព័ន្ធ នៃ មាតេយ្យកា។ នៅ ស្រុកខ្មែរ បុរាណ ប្រព័ន្ធ នៃ មាតេយ្យកា ទុក ជា របប សង្គម គឺ គ្រឹះ ស្ថិត នៅ លើ ការគោរព ចំពោះ ‹មេ-បា› គឺ ថា គោរព មាតា បិតា តែ ទុក មាតា ជា ភាព ប្រសើរ។ ដូច្នេះ មាតា ជា មេ សារពើឋាន នៅ ក្នុង ការ រស់នៅ នៅ ក្នុង សង្គម ខ្មែរ ដូចយ៉ាង ខ្មែរ ប្រើ ពាក្យ មេទ័ព, មេស្រុក, មេភូមិ, មេឃ្លាំង, ទន្លេ មេកុង ។ល។ អ្វី ដែល ជា រូបភាព នៃ ស្ត្រី ជា ភាពប្រសើរ ដូច យ៉ាង ពហិលក្ខណ: នៃ ព្រះមហាក្សត្រ មាន រូបភាព ជា ស្ត្រី គឺ ថា ផាត់ម្សៅ ពណ៌ ក្រហម លើ បាតដៃ និង បាតជើង, សៀតផ្កា លើ ផ្នួង សក់, ពាក់ ខ្សែ ក ធ្វើ ពី គជ ពាក់ ក្រវិល ហើយ ប្រើ ពាក្យ ចាស[13]

12 ជនចិន ដែលបានមកស្រុកខ្មែរ នៅឆ្នាំ ១២៩៦។
13 ពាក្យ ចាស នេះ ជា ពាក្យទោល សំរាប់និយាយ នៅក្នុង រាជវង្សានុវង្ស។

ដែល ជា ពាក្យ សំរាប់ ស្ត្រី និយាយ ជំនួស ពាក្យ បាទ សំរាប់ បុរស។

តែ ការគោរព ចំពោះ ‹មេ-បា› មិន ដូច ការគោរព បូជា ចំពោះ បុព្វបុរស របស់ ជនជាតិ ចិន-យួន នោះឡើយ ព្រោះ ថា ខ្មែរ គោរព មាតា-បិតា ដែល កំពុង រស់នៅ រីឯ ចិន-យួន គោរព ព្រលឹង បុព្វបុរស នៃ គ្រួសារ ដែល បាន ចាកស្ថាន ទៅ ហើយ។ ជនជាតិ ខ្មែរ គោរព ចំពោះ មាតា ព្រោះ ទុក ជា ខ្លឹម នៃ គ្រួសារ រីឯ ជនជាតិ ចិន-យួន គោរព បូជា ចំពោះ បុព្វបុរស ព្រោះទុក ជា ទំនាមទំលាប់ នៃ គ្រួសារ។

តែ មក ដល់ សម័យ ពុទ្ធសាសនា ហីនយាន[14] មាន ឫទ្ធិ គឺ ចាប់ ពី សតវត្សរ៍ ទី១៤ មក គេ ឃើញ ថា ប្រព័ន្ធ នៃ មេគោឃ្យកា ចុះ ថយ ឥទ្ធិពល ជា ខ្លាំង នៅ ក្នុង សង្គម ខ្មែរ រហូត លុបបាត់ តែ ម្តង។ បុព្វហេតុ គឺ ជំនឿ លើ ពុទ្ធសាសនា ហីនយាន ដែល ក្លាយ ជា សាសនា ជា ផ្លូវការ របស់ រដ្ឋ ខ្មែរ។ តាម ការសរសេរ របស់ លោក ថាច់ ទាន់ ថា ពួក សាសនិក ទុក ស្ត្រី ជា ប្រភព នៃ តណ្ហា ហើយ តណ្ហា ជា ប្រភព នៃ ទុក្ខ របស់ មនុស្សលោក ដែល ត្រូវតែ កំចាត់ ចោល។ ចំពោះ ពុទ្ធសាសនិក យល់ ថា មនុស្ស តែង តែ មាន បាបចិត្ត ជា ច្រើន នាំ អោយ ជាប់ អន្ទាក់ ទុក្ខ គ្រប់ បែប យ៉ាង ហើយ អន្ទាក់ ដែល មាន គ្រោះថ្នាក់ ច្រើន

14 ពុទ្ធសាសនាហីនយាន ជាលទ្ធិនាំមកពី លង្កា មិនត្រឹមតែមានជ័យជំនះលើ សាសនាព្រាហ្មណ៍ គឺលើ ពុទ្ធសាសនាមហាយានទៀត។

ជាង គេ គឺ ឧបាយ របស់ ស្ត្រី នោះ ឯង។ យើង ពុំ យល់ ស្រប នឹង ការយល់ឃើញ បែប នេះ ព្រោះ នៅ ក្នុង ពុទ្ធសាសនា ហីនយាន វា គ្មាន ឱវាទ ណា មួយ ទុក ស្ត្រី ជា ចារី នៃ បាបកម្ម កំណាច បំផុត ដែល នាំ អោយ សាសនិក ទុក ស្ត្រី ជា អន្តរាយ នោះឡើយ។ ចំពោះ យើង ការចុះថយ មតេយ្យកា នៅ ក្នុង សង្គម ខ្មែរ គឺ ជា វិវត្តន៍ ចិត្តគំនិត ពី មតេយ្យកា ជា របប សង្គម ទៅ ជា អតិថិជម៌[15] ធម្មតា តែ ប៉ុណ្ណោះ។ ដូច នេះ ជន ជាតិ ខ្មែរ នៅ តែ គោរព ស្ត្រី ព្រោះ មិន ដែល ទុក ស្ត្រី ជា ភេទ ទុនខ្សោយ តែ ជា ស្តំ មួយ សំរាប់ ទ្រទ្រង់ គ្រួសារ ស្មើភាព នឹង បុរស ដែល មាន នៅ ក្នុង ធាតុដើម នៃ ការគោរព ចំពោះ មេ-បា នោះ ឯង។

គួរ កត់ សំគាល់ ថា ក្នុង ការវិវត្តន៍ នៃ ព្រហ្មញ្ញ សាសនា ពី ការ ទុក ព្រះឥន្ទ្រ ជា អាទិទេព ធំ មក យក ព្រះព្រហ្ម ជា សារណៈ ធំ ចម្បង ដោយ សារ តែ ព្រះឥន្ទ្រ ឈ្លក់ ស្រវឹង កាម ឈ្លប់ មុខ ដើរ លួច ប្រពន្ធ គេ ឯង ដូច្នេះ សាសនិក នាំ គ្នា បង្កើត ទេព តា ព្រះព្រហ្ម កុំ អោយ មាន រូប ពោល ថា កុំ អោយ មាន ប្រពន្ធ មាន តែ ម្នាក់ ឯង ដូច្នេះ បាន ជា កើត ប្រពៃណី ឡើង ថា « ស្ត្រីជាទោស នៃ ព្រហ្មចរិយៈ »។ ប្រាស្នា ថា តើ ការវិវត្តន៍ នេះ វា អាច មាន ចលនា ទៅ លើ ការ ចុះ ថយ មតេយ្យកា នៅ ក្នុង

[15] សុជីវធម៌។

សង្គម ខ្មែរ ដូច្នេះ ទេ ដឹង ? ព្រោះ ថា បើ ទុក ស្ត្រី ជា ធំ ហេតុ អ្វី ត្រូវ ហាម ខាត់ ទេពតា ព្រះ ព្រហ្ម មិន អោយ មាន ប្រពន្ធ ?

## ភូមិ ខ្មែរ

ខ្មែរ ហៅ ភូមិ ខ្លួន ថា « ស្រុកខ្ញុំ » ដូច ហៅ នគរ ថា ស្រុកខ្មែរ នោះ ដែរ។ ភូមិ ខ្មែរ ជា ទី ប្រជុំជន តូច មាន ប្រជាជន ភាគ ច្រើន ជា កសិករ រស់នៅ ក្បែរ ដី ស្រែ របស់ ខ្លួន។ ភូមិ គ្មាន រចនាសម្ព័ន្ធ សង្គម រៀបចំ ច្បាស់លាស់។ អ្នក ភូមិ ម្នាក់ៗ រស់ នៅ ក្នុង គំនិត ឯកា ផង និង សហការ ផង ដែល អាស្រ័យ ទៅ លើ ករណី នីមួយៗ។ តួយ៉ាង សហការ ជា កិច្ចការ សង្គម (services sociaux) : ជិក ស្រះ ទុក ជា ភោគសម្បត្តិ រួម[16] ក្នុង ភូមិ។ តួយ៉ាង សហការ ជា សាមគ្គីភាព រវាង អ្នក ភូមិ : ជួយ ស្ទូងជួយ ច្រូតស្រូវ, ជួយ សង់ ផ្ទះ ។ល។

នៅ ក្នុង ភូមិ គ្មាន មេ ភូមិ តែងតាំង ទេ តែ មាន អ្នក ណែនាំ ដែល អ្នក ភូមិ ទាំងឡាយ ទទួល ស្គាល់ នៅ ក្នុង ចិត្ត ព្រោះ ទុក គាត់ ជា ព្រឹទ្ធាចារ្យ។ ជន នោះ ដឹកនាំ ភូមិ នៅ ក្នុង គំនិត ណែនាំ ច្រើន ជាង បង្គាប់ ព្រោះ ខ្លួន គ្មាន អំណាច ជា ផ្លូវការ ទេ។ ដូច្នេះ ការសំរេច ស្ថិត នៅ ក្នុង យោបល់ រួម តែ ការអនុវត្ត ន៍ ពុំមាន លក្ខណៈ ជា កាតព្វកិច្ច នោះឡើយ សំរាប់ អ្នក ភូមិ ទាំងឡាយ។ ដូច នេះ គេ អាច សន្និដ្ឋាន បាន ថា មាន សាមគ្គី

[16] ភោគសម្បត្តិរួម ; biens communs។

ភាព រវាង អ្នក ភូមិ តែ គ្មាន សិទិទ្ធពល សង្គម នៅ ក្នុង ភូមិ។ បាតុភូត នេះ នាំ អោយ ភូមិ ខ្មែរ មាន គ្រឹះ ស្រួយ នៅ ចំពោះ មុខ ការរុករុល គ្រប់ បែប យ៉ាង មក ពី ក្រៅ។ គួរ កត់ សំគាល់ ថា ភូមិ ខ្មែរ មាន ភាព នៅ ដាច់ ស្រយាល ពី មជ្ឈមណ្ឌល រដ្ឋបាល ផង និង នៅ ឆ្ងាយ ពី គ្នា ផង។ ដូចនេះ ពន្ធនាការ ជាមួយ រដ្ឋ គឺ នៅ ត្រឹមតែ ការទាក់ទង នៃ ប្រព័ន្ធ ពន្ធដារ ដែល សាមី ខ្លួន ជា ម្ចាស់ របស់ ត្រូវ បង់ ជូន រាជការ ដូចយ៉ាង ពន្ធដី, ពន្ធ ស្រូវ, ពន្ធ ទូក, ពន្ធ ទាស និង ពន្ធ ខ្លួន។

## ជំនឿ និង សាសនា

ជនជាតិ ខ្មែរ មាន ជំនឿ ដើម មុន ទទួល យក សាសនា បរទេស មក ទុក ជា សាសនា របស់ ខ្លួន គឺ ព្រហ្មញ្ញ សាសនា និង ពុទ្ធ សាសនា។ ជំនឿ ដើម នេះ ហើយ ជា មូលដ្ឋាន គ្រឹះ នៃ ជនជាតិ ខ្មែរ។ ដូច នេះ អ្វី ដែល ខ្មែរ ទទួល យក ពី បរទេស ទាំង សាសនា ក្តី ភាសា ក្តី អក្សរ ក្តី អក្សរសិល្ប៍ ក្តី សិល្បៈ ក្តី ខ្មែរ តែងតែ រក្សា មូលដ្ឋាន គ្រឹះ របស់ ខ្លួន ជា និច្ច ក្នុង គំនិត ពុំ ទុក គំនិត បរទេស ទាំង ដុល នោះឡើយ ដូច នេះ ខ្មែរ តែងតែ យក គំនិត បរទេស មក កែឆ្នៃ លក្ខណៈ អោយ ទៅ ជា ខ្មែរ ដើម្បី ស្របស្រួល មក នឹង ចំណង់ ចំណូល ចិត្ត របស់ ខ្មែរ។

ជំនឿ ដើម ខ្មែរ គឺ ការគោរព ចំពោះ មេ-បា, ការគោរព ចំពោះ នាង គង្ហីង និង ក្រពើ នូវ ការគោរព ចំពោះ អ្នកតា។

## ការគោរព ចំពោះ មេ-បា

ជនជាតិ ខ្មែរ គោរព មេ-បា ដែល ខ្មែរ យក ឈ្មោះ មក ដាក់ អោយ ប្រាសាទ ទាំងឡាយ ដូចយ៉ាង មេបុណ្យ, បាយ័ន, បាពួន ។ល។ រីឯ ឈ្មោះ បា ខ្មែរ យក មក ដាក់ ឈ្មោះ អោយ ប្រាសាទ ឬ ទីកន្លែង ដែរ ដូច ជា បាខែង, បាដែង, បាតើ, បារិយា, បាណាម។

លោក វ៉ាន់ ឌីកាអុន, បញ្ញវន្តខ្មែរ ល្បីល្បាញ មួយ រូប, ពន្យល់ ពាក្យ មេ បា ថា[17] : ‹*នៅ ក្នុង គ្រួសារ នីមួយៗ សមាជិក គ្រួសារ គ្មាន ឯកភាព គ្រប់គ្រាន់ ក្នុង ការសម្រេច ចិត្ត ដោយ ខ្លួន ឯង ឡើយ ទោះ រឿង ស្នេហា ដែល ជា រឿង ផ្ទាល់ ខ្លួន សុទ្ធសាធ នោះ ក៏ ដោយ។ បើ កម្លោះ ក្រមុំ ស្រឡាញ់ គ្នា គេ ត្រូវ សួរ ចិត្ត មេ បា សិន ថា តើ ព្រម ឬ មិន ព្រម។ បើ ស្រឡាញ់ គ្នា យ៉ាង ណា ក៏ ដោយ តែ បើ មេ បា មិន ព្រម ក៏ ពុំ អាច ស្រឡាញ់ គ្នា កើត ដែរ*›។ ការគោរព នេះ វា ជា ការគោរព ចាស់ ទុំ ដូច មាន ចែង នៅ ក្នុង ច្បាប់ ល្បើក របស់ ព្រះភិរម្យ ភាសា អ៊ូ ហៅ ងុយ ថា : ‹*រៀន បទ រៀន បាទ កុំ កោង ហួស ខ្នាត កុំ ភ្លាត់ ខុស ផ្លូវ កុំ ព្រហើន ភ្លេច ម៉ែ កុំ ប្រែ ហួស ឱ ឃើញ ចាស់ សក់ ស្កូវ កុំ ត្រូវ មើល ងាយ*›។

17 ដកស្រង់ចេញពី អត្ថបទ របស់លោក វ៉ាន់ ឌីកាអុន មានចំណងជើងថា សង្គម សក្តិភូមខ្មែរ នៅក្នុងរឿងទុំទាវ។

លោក វ៉ាន់ ឌីការអុន យល់ ឃើញ ថា ការគោរព មេ បា តាម ដំបូន្មាន និច្ច័យ (le sens morale) បើ មាន លក្ខណៈ តឹងតែង ពេក វា ជា ការកាច់ ៗ បាក់ ជា ផ្ទត់ នៃ អក្សកិរិយា របស់ មនុស្ស ម្នាក់ៗ ៗ រស់ តាម ទំនៀមទម្លាប់ តឹងរ៉ឹង នោះ ឯង។ ដើម្បី រក្សា ទំនាម ទម្លាប់ ៗ បាន គង់វង់ សមាជិក នៃ សង្គម មាន មេ បា ជា សក្ការៈ ដាច់ ខាត ត្រូវ តែ បោះ បង់ចោល នូវ គំនិត រិះគន់ ពុំ នោះ សោត គេ ទុក ជា មនុស្ស ពាល ដែល គេ ឈប់ រាប់ អាន។

តាម ទស្សនៈ លោក កេង វ៉ាន់សាក់ ‹ការគោរព មេ បា› ជា ប្រព័ន្ធ នៃ ចិត្តគំនិត ខ្មែរ មាន ជម្រៅ ជ្រៅ ណាស់ គឺ ប្រៀប ផ្ទៀប ទៅ នឹង រូបភាព នៃ មនុស្ស សាប គ្រាប់ពូជ ៗ ចេញ ពន្លក នៅ និទាឃ រដូវ, វិកសិត[18] ជា បុប្ផា នៅ វស្សាន រដូវ, មាន ផ្លែ នៅ សរទ រដូវ, សំរាប់ រក្សា គ្រាប់ ពូជ នៅ ហេមន្ត រដូវ។ គឺ ជា វាល វែង វដ្តសង្សារ (cycle de vie) នៃ ធម្មជាតិ ឬ មនុស្សជាតិ។ គឺ ជា ចិត្តគំនិត ជា ថាមពល ចេះ គ្រោង ផែនការ នៅ ក្នុង សង្គម ខ្មែរ សំរាប់ អនាគត។ ពាក្យ **មេ** ជា ឧត្តម ចិត្តគំនិត មាន ប្រភព ចេញ ម កពី សហ អរិយធម៌ ទាំងឡាយ នៃ ក្រុម មនុស្ស ផ្សេងៗ គ្នា ដើម្បី កសាង អរិយធម៌ ថ្មី ៗ វិតតែ ខ្ពង់ខ្ពស់ និង កាន់ តែ មាន ថាមពល ខ្លាំងក្លា ថែម ទៀត ពោល ថា បង្កើត ជា ប្រជាជាតិ មួយ ដែល មាន

[18] វិកសិត : រីក ; s’épanouir។

សមាជិក ម្នាក់ៗ ស្គាល់ ជាក់លាក់ នូវ សិទ្ធិ និង ករណីយកិច្ច របស់ខ្លួន។ រឿង ព្រះថោង និង នាងនាគ ជា ឧទាហរណ៍ មួយ បញ្ជាក់ នូវ សហ អរិយធម៌ នេះ ឯង។ នៅ ក្នុង ពាក្យ **បា** ហៅ ថា ‹ផ្លូវ› មាន សញ្ញាណ បី យ៉ាង : ព្រះ, ថៅ និង តា។ បា ជា គំនិត នៃ គំរោង នៃ សង្គមមួយ ដែល មាន គោលដៅ ច្បាស់លាស់ សំរាប់ ការរស់នៅ។ គំរោង នៃ សង្គម នោះ គឺ **ព្រះ** ក្នុង នោះ មាន អ្នក ដឹកនាំ ជា ទីស្នេហា[19] គឺ ថៅ, ដែល ជា អ្នក ដឹង មាន ក្បួន ដឹកនាំ គឺ តា។ ដូច នេះ **ព្រះ** ជា ព្រលឹង ជាតិ, **ថៅ** ជា អ្នក ដឹកនាំ ជាតិ ចេះ បង្រួបបង្រួម ប្រជារាស្ត្រ នៅ ក្នុង គំនិត បំរើ និង ការពារ, **តា** ជា ប្រភព នៃ ច្បាប់ ដឹកនាំ និង ការពិសោធ របស់ បុព្វបុរស ជាតិ នោះ ឯង។ ការគោរព មេ បា នេះ ជា មូលដ្ឋាន វប្បធម៌ ដើម របស់ ជនជាតិ ខ្មែរ ដែល អាច តទល់ បាន នឹង ឥទ្ធិពល អរិយធម៌ ឥណ្ឌា ដែល ហូរ ចូល មក ក្នុង ស្រុកខ្មែរ។ នៅ ចំពោះ មុខ ការតទល់នេះ តម្រូវ ឲ ពួក ព្រាហ្មណ៍ ព្រឹទ្ធបណ្ឌិត នៅ ស្រុកខ្មែរ ធ្វើ សិថិលភាព[20] ជា ច្រើន ដើម្បី កុំ ឲ មាន ការប៉ះទង្គិច ទាំង កម្រោល រវាង ទ្រឹស្តី សាសនា របស់ ពួក ខ្លួន នឹង ជំនឿអាយ ដែល ជា ជំនឿ មាន គ្រឹះ ច្បាស់លាស់ រួច មក ហើយ។ លោក កេង វ៉ាន់សាក់ មិន ដែល បញ្ជាក់ ថា ការគោរព មេ បា នេះ ជា វិសិដ្ឋភាព ខ្មែរ លើ ព្រហ្មញ្ញ សាសនា និង ពុទ្ធ សាសនា នោះ ទេ តែ ជា ចិត្តគំនិត

[19] អ្នកដឹកនាំជាទីស្នេហា ; un dirigeant charismatique។
[20] សិថិលភាព : ដំណើរធូរថយ ឬ បន្ធូរបន្ថយ។

ខ្មែរ អំពី សង្គម ដែល ពួកព្រាហ្មណ៍ ព្រឹទ្ធបណ្ឌិត ត្រូវ យក មក សម្របសម្រួល ជា មួយ នឹង សាសនា ខ្លួន ដើម្បី ឲ ប្រជាជន អោយ អាច រើសយក សាសនាថ្មី នេះ ជា ជំនឿ រួម បាន។

## ការគោរព ចំពោះ នាង គង្ហីង និង ក្រពើ

មាន នៅ ក្នុង រឿងព្រេង ខ្មែរ ថា ស្រុកខ្មែរ ដើម ដំបូង ជា ជលសា។ ក្រោយ មក លេច ចេញ ទេវតា ស្រី ម្នាក់ ឈ្មោះ គង្ហីង ឈរ លើ ក្រពើ យក ដៃ ច្បូត សក់ វែង របស់ ខ្លួន បង្កើត បាន ជា ពុសធា។ លើ ពសុធា នោះ ឯង ដែល អាច អោយ មនុស្ស ខ្មែរ មក រស់នៅ បាន។ ខ្មែរ ហៅ ទេវតា ស្រី នោះ នាង គង្ហីង ជា និមិត្តរូប នៃ ពសុធា, រីឯ ក្រពើ ជា និមិត្តរូប ជលសា។ គូ ទេវតា ស្រី និង ក្រពើ នោះ ជា តូតិម នៃ ជនជាតិ ខ្មែរ និង ទឹកដី ខ្មែរ។ រូប តំណាង នៃ តូតិម នាង គង្ហីង-ក្រពើ គឺ មាណវី[21] និង សត្វ ក្រពើ។ នៅ ស្រុកខ្មែរ សព្វថ្ងៃ នៅ គ្រប់ បូជនីយដ្ឋាន ទាំង ព្រាហ្មញ្ញ សាសនា ពុទ្ធ សាសនា និង ជំនឿ ផ្សេងៗ ទៀត គេ តំណាង ក្រពើ ជា ទង់ ហៅ ថា ‹ទង់ ក្រពើ› ឬ ‹ទង់ រលក› ដែល គ្រើន រំឭក នូវ ធម្មជាតិ ជា បាយាប[22] នៃ ក្រពើ។ គេ ឃើញ នៅ មុខ ផ្ទះ ណា មាន មនុស្ស ស្លាប់ ដោត ទង់ ក្រពើ មាន ពណ៌ ស នាំ អោយ គេ ហៅ ទង់ នោះ ថា ‹ទង់ ព្រលឹង›។ តែ ពួក អ្នក

[21] មាណវី, ស្រីនៅវ័យក្មេង, jeune fille។
[22] បាយាប, អ្នកតាទឹក, génie des eaux។

ប្រឆាំង នឹង ជំនឿ នោះ នាំ គ្នា ហៅ ទង់ នោះ ថា ‹ទង់ ខ្មោច› គួរ កត់ សំគាល់ ថា ក្រពើ ក៏ ជា តំណាង នៃ ជន ក្បត់ ឬ ជន រមិលគុណ។ ទស្សនៈ នេះ មាន អ្នក ខ្លះ ថា ចេញ ពី ប្រភព ពុទ្ធ សាសនា ព្រោះ ទុក ជំនឿ ដើម ខ្មែរ ជា សត្រូវ នឹង ខ្លួន ដូច មាន នៅ ក្នុងរឿង ក្រពើ នេន ធុន : នេន ធុន ព្រោះ តែ ក្បត់ នឹង ពុទ្ធ សាសនា បាន ជា ពុំ អាច ប្រែ ខ្លួន មក ជា មនុស្ស វិញ បាន។

មួយ វិញ ទៀត ពុទ្ធសាសនិក តែងតែ ប្រដូច នាង គង្ហីង ទៅ នឹង នាង មារា ដែល មាន ចារ ក្នុង ពុទ្ធ រឿងព្រេង មាន ចំណង ជើង ថា ‹បាប ចិត្ត នៃ នាង មារា› : ដើម្បី ធ្វើ អោយ អាក់ខាន ព្រះសក្យមុនី បាន ត្រាស់ ដឹង។ នាង មារា មក ពី ឋាន យក្ស ជា មួយ នឹង កងទ័ព របស់ នាង មក ទាមទារ អាស នៈ ដែល ព្រះអង្គ កំពុង គង់ លើ។ ដើម្បី ទប់ទល់ នឹង បាប ចិត្ត នោះ ព្រះដ៍មានព្រះភាគ ព្រះអង្គ យក ដៃ ស្តាំ ពាល់ ដី ហើយ បួងសួង ដល់ ព្រលឹង ព្រះពសុធា អោយ ជួយ ព្រះអង្គ ឯកា នៅ ចំពោះ មុខ ទ័ព យក្ស នាំ អោយ រញ្ជួយ ដី ប្រាំ មួយ យ៉ាង អាច កំចាត់ នាង មារា បាន។ តាម របៀប និទាន រឿងខ្មែរ វិញ គឺ នាង គង្ហីង ជា អ្នក ជួយ ព្រះសម្មាសម្ពុទ្ធ ទៅ វិញ គឺ ថា ដោយ ច្បូត សក់ របស់ នាង បង្កើត ជា ជលសា នាំ អោយ លិចលង់ ទ័ព នាង មារា។ កុសលកម្ម នោះ ឯង ដែល ខ្មែរ នៅ តែ គោរព នាង គង្ហីង មក ដល់ សព្វថ្ងៃ តែ ពុំ ទុក ជា ទេវតា ស្រី ធំ ចម្បង ទៀត នោះឡើយ។

## ជំនឿ ចំពោះ អ្នកតា

អ្នកតា ជា ព្រលឹង ស្ថិត នៅ ក្នុង រុក្ខជាតិ, ក្នុង ភ្នំ និង ទី កន្លែង ដទៃ ទៀត។ ខ្មែរ យក ដុំ ថ្ម ជា តំណាង រូប អ្នកតា យក ទៅ ដាក់ ក្រោម គល់ ដើម ឈើ។ ជូន សង់ កូន ខ្ទម ទ្រ ដោយ សសរ សំរាប់ ដំកល់។ នេះ ជា ជំនឿ ព្រលឹង និយម : ក្នុង រឿង ព្រះបាទ ហ៊ុន ទៀន និង ព្រះនាង លីវ យី កាល ជន ហ៊ុន ទៀន ឬ កៅណ្ឌិន្យ នៅ ឥណ្ឌា យល់សប្តិ ឃើញ អ្នកតា ឬ ទេវតា រក្សា ខ្លួន ប្រគល់ ធ្នូ ទិព្វ អោយ ហើយ បញ្ជា អោយ ឡើង ជិះ សំពៅ ជំនួញ ដ៏ ធំ មួយ ដើម្បី ធ្វើ ដំណើរ មក ស្រុកខ្មែរ ច្បាំង យក រាជសម្បត្តិ (នៅពាក់កណ្តាល ស.វ. ទី៣ ក.គ.ស.)។ ដូច្នេះ ខ្មែរ តែងតែ ទុក ព្រះបាទ ហ៊ុន ទៀន ជា ស្ថាបនិក ក្សត្រ នគរ ហ្វូណន។

ព្រលឹង អ្នកតា ជា អ្នក ការពារ អ្នក ភូមិ ទាំងឡាយ ហើយ ជួយ ដល់ ជន ណា ដែល បន់ស្រន់ ដល់ លោក សូម អោយ ជួយ ខ្លួន។ អ្នកតា ក៏ ជា អ្នក ថែរក្សា ប្រចាំ ទីកន្លែង មួយ។ ទំនាក់ទំនង រវាង មនុស្ស នឹង ព្រលឹង អ្នកតា គឺ ងាយស្រួល បំផុត គឺ គ្រាន់ តែ ធ្វើ ការបន់ស្រន់ ថ្វាយ ដង្វាយ ដូច ជា បាយ, មាន់ អាំង, ទឹក ដូង ឬ ចេក ដើម្បី សូមពរ ពី អ្នកតា អោយ ខ្លួន បាន សំរេច នូវ បំណន់ ខ្លួន។ តែ កាល ណា បាន សំរេច ដូច ប្រាថ្នា ត្រូវ តែ អ្នក បន់ នោះ ធ្វើ ពិធី លា បំណន់ ជា ដាច់ ខាត ពុំ នោះ សោត គឺ ច្បាស់ ជា ព្រលឹង អ្នកតា ធ្វើ ទោស។ អ្នក ណា មួយ

សើច ដោយ ឮ សំដី របស់ ជន ម្នាក់ និយាយ ឡកឡឺយ ដល់ អ្នកតា គឺ អ្នកសើច ជា អ្នក ទទួល ទោស ពុំ មែន អ្នក និយាយ ចំអក នោះ ទេ ដូចយ៉ាង ធ្វើ ឱ្យ អ្នក សើច នោះ ឈឺ ពោះ ក្រៃលែង។ លុះ ត្រាតែរៀបចំ ធ្វើ ពិធី លាង ទោស ទើប អាច បាត់ ឈឺ ពោះ។

ជំនឿ លើ អ្នកតា របស់ ប្រជាពលរដ្ឋ ខ្មែរ មាន លក្ខណៈ ពីរ យ៉ាង :

១. ជា ការសំម្តែង គំនិត នៃ ថាមពល ធរណី ដែល ដី ឃុំ ស្រុក ខេត្ត មាន ពហុ ផលភាព មាន វិបុលភាព ដោយសារ អ្នកតា ប្រចាំ ឃុំ ស្រុក ខេត្ត នីមួយៗ នោះ ឯង។ ហេតុ នេះ ឯង រៀង រាល់ ឆ្នាំ អ្នក ស្រុក នាំ គ្នា ធ្វើ ពិធី សែន ដែល គេ ហៅ ថា បុណ្យ លើក អ្នកតា ដើម្បី សូម សេចក្តីសុខ និង សេចក្តីចំរើន ពី ព្រះ ធរណី នេះ។

២. ជា ការសំដែង គំនិត នៃ ការទុក អ្នកតា ជា ទីកន្លែង តែម្តង ដោយ យក ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ និង អនុស្សាវរីយ៍ របស់ អ្នក ស្រុក នៅ ទីកន្លែង នោះ មក បញ្ជាក់ ថា ជំនឿ នេះ គឺ ជា ការពិត ដូចយ៉ាង អ្នក ស្រុក នៅ ខេត្តពោធិសាត់ ទុក អ្នកតា ឃ្លាំងមឿង ជា ខេត្តពោធិសាត់ តែ ម្តង។ ដើម ដំបូង នៃ ជំនឿ នេះ គឺ ក្នុង សតវត្ស ទី១៦ មាន មេ ទ័ព ខ្មែរ ម្នាក់ ឈ្មោះ ឧកញ៉ា ឃ្លាំងមឿង លោក សុខចិត្ត បូជា ជីវិត លោក ដោយ សម្លាប់ ខ្លួន ឯង ដើម្បី ការពារ ពញាចន្ទ ដែល ជាប់

ក្នុង បន្ទាយ ជ័យ ពី ការឡោមព័ទ្ធ របស់ កងទ័ព របស់ ស្ដេច កន។ ការបូជា ជីវិត របស់ ឧកញ៉ា ឃ្លាំងមឿង ចៅហ្វាយ ខេត្ត ពោធិសាត់ មាន គោលបំណង ទៅ កែន ទ័ព ខ្មោច ៤ មក ជួយ វាយ រំដោះ ពញា អង្គចន្ទ ពី ការឡោមព័ទ្ធ របស់ សត្រូវ។ ចំណេរកាល តៗ មក អ្នក ស្រុក នៅ ខេត្ត ពោធិសាត់ ក៏ នាំ គ្នា ជឿ ថា ព្រលឹង ខ្មោច ឧកញ៉ា ឃ្លាំងមឿង ក្លាយ ទៅ ជា អ្នកតា រក្សា ទឹកដី ខេត្ត ពោធិសាត់ ហើយ មក ដល់ បច្ចុប្បន្នកាល រាល់ ខែ មេសា គ្រប់ មន្ត្រី ប្រចាំ នោះ និង អ្នក ស្រុក នាំ គ្នា ធ្វើ ពិធី បន់ស្រន់ ដល់ អ្នកតា ឃ្លាំងមឿង ដើម្បី សូម សេចក្ដីសុខ សប្បាយ ពី ម្ចាស់ ទឹកដី។

ជំនឿ បែប នេះ គេ ឃើញ មាន ដែរ នៅ ស្រុក ត្បូងឃ្មុំ នៅ ក្នុង ខេត្ត កំពង់ចាម, គ្រប់ ចៅហ្វាយ ស្រុក ថ្មី ត្រូវ តែ ធ្វើ ពិធី បន់ស្រន់ ដល់ អ្នកតា អជូន នៅ ភូមិ អជូន ដែល ជា ម្ចាស់ ទឹកដី ទី នោះ ដើម្បី សូម សេចក្ដីសុខ។ ត្រូវ ដឹង ថា អជូន ជា អតីត ចៅហ្វាយ ខេត្ត ត្បូងឃ្មុំ ក្នុង សតវត្ស ទី១៦ ដែល ព្រះរាជា កាត់ ទោស ប្រហារ ជីវិត ពី បទ ធ្វើ ឃាតកម្ម ដោយ ចេតនា បំពាន អាជ្ញា ស្ដេច លើ បុគ្គល ទុំ។ ចំណេរកាល តៗ មក អ្នក ស្រុក ត្បូងឃ្មុំ មាន ជំនឿ ថា ព្រលឹង អជូន ក្លាយ ជា អ្នកតា រក្សា ទឹកដី ហើយ នាំ គ្នា ធ្វើ ការបន់ស្រន់ ដើម្បី សូម សេចក្ដីសុខ។ រឿង អជូន នេះ ខ្មែរ ភាគ ច្រើន ដឹង ច្បាស់ ដោយសារ មាន អ្នក និពន្ធ ខ្មែរ ម្នាក់ បាន ដកស្រង់ ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ នេះ មក

តែង ជា ប្រលោមលោក ដ៏ ល្បី ដែល មាន ចំណងជើង ថា « រឿង ទុំ ទាវ» ឬ ទាវ ឯក។

## ព្រហ្មញ្ញ សាសនា

ព្រហ្មញ្ញ សាសនា ទំនង ហូរ ចូល ស្រុកខ្មែរ តាម រយៈ ពួក ឈ្មួញ ឥណ្ឌា ដែល ធ្វើ ដំណើរ តាម សំពៅ ទាក់ទង លក់ដូរ ជា មួយ អ្នក ស្រុក។ មាន ឈ្មួញ ខ្លះ ជា អ្នក ចេះដឹង ខាង ព្រហ្មញ្ញ សាសនា ជួន បាន រៀបការ ជា មួយ ស្ត្រី ខ្មែរ ក៏ នាំ អោយ មាន ឥទ្ធិពល ទៅ លើ ជនជាតិ ខ្មែរ។ ម្យ៉ាង ទៀត គេ ដឹង តាម ប្រវត្តិសាស្ត្រ ថា កាលណោះ ស្រុកខ្មែរ គ្រប់គ្រង ដោយ ព្រះ នាង លិវ យី ហើយ មាន ស្តេច ឥណ្ឌា ព្រះ នាម ហ៊ុន ទៀន បាន លើក ទ័ព មក ច្បាំង ដណ្តើម យក ទឹកដី ខ្មែរ។ ក្រោយ ដែល បាន ជ័យជំនះ ព្រះអង្គ ក៏ បាន រៀបអភិសេក ជា មួយ ព្រះ នាង លិវ យី ហើយ បាន ប្រកាស តាំង ខ្លួន ជា ស្តេច គ្រងរាជ្យ ព្រម ទាំង បាន រៀបចំ ស្រុកខ្មែរ តាមទស្សនៈ បែប ព្រហ្មញ្ញ សាសនា ថែម ទៀត។ ម្លោះហើយ ឥទ្ធិពល លទ្ធិព្រាហ្មណ៍ ក៏ រីក ដុះដាល ឡើង ជា លំដាប់ នៅស្រុក ខ្មែរ ហើយ ក្លាយ ជា សាសនា ជាតិ តែ ម្តង ជា ពិសេស នៅ ក្នុង មជ្ឈដ្ឋាន ពួក អ្នក ដឹកនាំ រហូត ដល់ សតវត្សរ៍ ទី១៤។ នៅ ស្រុកខ្មែរ គេ និយម គោរព ព្រះឥសូរ ជា ធំ, ឯ ព្រះវិស្ណុ, ព្រះហរិហរៈ (ឥសូរ និង នារាយណ៍ រួម គ្នា), ព្រះ ព្រហ្ម ក៏ មានគេ គោរព ខ្លះៗ ដែរ។

## ពុទ្ធ សាសនា

ពុទ្ធ សាសនា ចែក ជា ពីរ និកាយ : មហា យាន និង ហីនយាន។ និកាយ ហីនយាន ចែក ចេញ ទៅ ទិស ខាង ត្បូង នៃ ប្រទេស ឥណ្ឌា (ទក្ខិណ និកាយ) ជា យាន តូច ចង្អៀត ផ្ទុក សត្វលោក ទៅ កាន់ និព្វាន បាន ចំនួន តិច ពោល គឺ ក្រ បាន សំរេច និព្វាន ព្រោះ វិន័យ តឹងតែង ម៉ត់ចត់។ និកាយ ហីនយាន និយម ចាស់ គឺ គោរព ប្រតិបត្តិ តាម ពុទ្ធោវាទ ដែល ព្រះពុទ្ធ ទ្រង់ បាន សំដែង រួច មក ហើយ (ក្នុង គម្ពីរ ត្រៃបិដក) និកាយ នេះ គោរព ព្រះពុទ្ធ សមណគោតម ដែល ត្រាស់ ដឹង សម្មាសម្ពោធិញ្ញាណ ហើយ ដែល បាន ចូល បរិនិព្វាន ទៅ ហើយ។ សព្វថ្ងៃ ប្រទេស ដែល និយម ពុទ្ធសាសនា និកាយ ហីនយាន មាន ប្រទេស ខ្មែរ-សៀម-លាវ-ភូមា-នេប៉ាល់-សិរីលង្កា ។ល។

ឯ និកាយ មហាយាន ចែកចេញ ទៅ ទិស ខាង ជើង (ឧត្តរ និកាយ) ជា យាន ធំ អាច ផ្ទុក សត្វលោក បាន ច្រើន គ្នា ទៅ កាន់ គោលដៅ ត្រឹម ពោធិសត្វ ដែល អាច ជួយ ណែនាំ ប្រោស សត្វលោក បាន។ និកាយ មហាយាន និយម ធម៌ ថ្មី គឺ ធម៌ ដែល មាន ន័យ ធូរ ស្រាល ហើយ គោរព ប្រតិបត្តិ តាម លទ្ធិ អាចរិយវាទ (តាម គ្រូ អាចារ្យ របស់ ខ្លួន តៗ គ្នា) ពុំ មែន តាម ពុទ្ធោវាទ ដូច និកាយ ហីនយាន ឡើយ។ ដូច នេះ និកាយ មហា យាន ពុំ គោរព ព្រះពុទ្ធ ជា ធំ ទេ តែ គោរព ពោធិសត្វ ដូច ជា

ពោធិសត្វ អវលោកិតេស្វរៈ ឬ លោកកេស្វរៈ មញ្ញស្រី អែតរេយ ប្រាជ្ញា បារមិតា ជា ដើម។ សព្វថ្ងៃ ប្រទេស ដែល និយម ពុទ្ធ សាសនា មហាយាន មាន ប្រទេស យួន-ជប៉ុន-ទីបេ-ឥណ្ឌូណេ ស៊ី ។ល។

នៅ សតវត្ស ទី៣ មុន គ.ស. ក្នុង រជ្ជកាល ព្រះបាទ អសោក ពុទ្ធ សាសនា ត្រូវ បាន ផ្សព្វផ្សាយ ពាសពេញ ទាំង ប្រទេស ឥណ្ឌា ទាំង ក្រៅ ប្រទេស។ តាម ប្រវត្តិសាស្ត្រ គេ ដឹង ថា នៅ ពុទ្ធ សត វត្ស ទី៣ (ព.ស. ២៣៤) គឺ តាំង ពី មុន គ.ស. ៣០០ ឆ្នាំ ម្លេះ ព្រះបាទ អសោក ពុទ្ធសាសនិក ដ៏ ឆ្នើម ក្នុង ប្រទេស ឥណ្ឌា បាន បញ្ជូន សមណទូត ពីរ អង្គ គឺ ព្រះ សោណត្ថេរ និង ព្រះ ឧត្ត រត្ថេរ អោយ នាំ យក ពុទ្ធ សាសនា ថេរវេទ (ហីនយាន) មក ផ្សាយ នៅ សុវណ្ណភូមិ (អាស៊ីអាគ្នេយ៍)។ តាម សិលាចារឹក រ៉ូកាញ់ (នៅ ស្រុកយួន ខាង ត្បូង) ទំនង ជា ពុទ្ធសាសនា ចូល មក ប្រតិស្ឋាន ក្នុង ស្រុកខ្មែរ នៅ សតវត្ស ទី២ នៃ គ.ស. ក្នុង រជ្ជកាល ព្រះបាទ ស្រីមារៈ ឬ ហ្វាន់ថេម៉ន។

# វិវត្តិន៍ នៃ ព្រហ្មញ្ញ សាសនា និង ពុទ្ធ សាសនា

## ក. សម័យ នគរ ភ្នំ (ស.វ. ទី១ ដល់ ទី៦)

នៅ សម័យ នោះ ខ្មែរ ខ្លះ គោរព ព្រហ្មញ្ញ សាសនា ខ្លះទៀត គោរព ពុទ្ធ សាសនា។ ពុទ្ធ សាសនិក ពេញចិត្ត នឹង ពុទ្ធ សាសនា ថេរវាទ (និកាយ ហីនយាន)។ នៅ សតវត្ស ទី២ ពុទ្ធ សាសនា ចំរើន លូតលាស់ ជាង ព្រហ្មញ្ញ សាសនា។

## ខ. សម័យ ចេនឡា (ស.វ. ទី៦ ដល់ ទី៨)

មក ដល់ សម័យ ចេនឡា ព្រហ្មញ្ញ សាសនា លូតលាស់ ជាង ពុទ្ធ សាសនា រហូត ដល់ ស.វ. ទី១២។ ប៉ុន្តែ ពុទ្ធ សាសនា ហីនយាន មិន សាបសូន្យ ភ្លាម ទេ ជា ភស្តុតាង គេ ប្រទេះ ឃើញ ព្រះពុទ្ធ រូប នៅ ព្រៃកប្បាស ដែល បាន សាង ឡើង នៅ ស.វ. ទី៧ និង សិលាចារឹក ជា ច្រើន ទៀត។ នៅ ចុង សតវត្ស ទី៧ និកាយ មហាយាន ក៏ ផ្សាយ ចូល មក ដល់ ស្រុកខ្មែរ ហើយ លូតលាស់ រហូត ដល់ ស.វ. ទី១៣ ប៉ុន្តែ មិន សូវ ឃើញ មាន រូបបដិមា ពោធិសត្វ លោកេស្វរៈ ទេ, គេ ប្រទះ ឃើញ មាន រូប មួយ នៅ

ក្រមួន ស (កម្ពុជាក្រោម) និង រូប មួយ ទៀត នៅ ប្រាសាទ តាក្រៀម (សៀមរាប)។ ដល់ ស.វ. ទី៨ ព្រហ្មញ្ញ សាសនា នៅ តែ លូតលាស់ ទៀត។

## គ. សម័យ មហា នគរ (ស.វ. ទី៨ ដល់ ទី១៥)

នៅ ស.វ.ទី៩ ព្រហ្មញ្ញ សាសនា កាន់ តែ លូតលាស់ ព្រោះ ព្រះបាទ ជ័យវរ្ម័ន ទី២ ទ្រង់ សព្វ ព្រះទ័យ កាន់ ព្រហ្មញ្ញ សាសនា និយម ព្រះឥសូរ ជា ធំ។ ព្រះអង្គ ទ្រង់ បាន ចាត់ចែង អោយ អញ្ជើញ ព្រាហ្មណ៍ ដ៏ ប្រសើរ ម្នាក់ ឈ្មោះ ហិរណ្យនាម ជា អ្នក ប្រាជ្ញ ចេះចប់ ត្រៃវេទ មក ជួយ រៀបចំ ធ្វើ ពិធី ទេវរាជ (culte du roi-dieu) ដើម្បី ប្រកាស ឯករាជ្យ ដល់ ប្រទេស កម្ពុជា ហើយ ធ្វើ ព្រះរាជា អោយ ទៅ ជា ព្រះរាជចក្រវាល នៅ លើ ភ្នំ គូលែន។ ព្រះអង្គ អោយ គេ សាង លិង្គ ព្រះឥសូរ តំកល់ ក្នុង ប្រាសាទ ភ្នំ ទុក ជា ទីគោរព។ នៅ សតវត្ស ទី៩ (គ.ស. ៨៨៩) ព្រះបាទ យសោវរ្ម័នទី១ ទ្រង់ បាន ឡើង សោយរាជ្យ បន្ត ទៀត ហើយ ទ្រង់ ប្រកាន់ ព្រហ្មញ្ញ សាសនា និយម ព្រះឥសូរ ជា ធំ ប៉ុន្តែ ព្រះអង្គ ទ្រង់ ប្រោស ប្រាណ ពុទ្ធ សាសនា ដែរ, ជា ភស្តុតាង ព្រះអង្គ បាន សាង អាស្រម ជា ច្រើន កន្លែង សំរាប់ ឱ្យ អ្នក កាន់ សាសនា ទាំង បី ប្រភេទ (ពុទ្ធ សាសនា ហីនយាន ពុទ្ធ សាសនា មហាយាន និង ព្រហ្មញ្ញ សាសនា) ទៅ រៀន អំពី សាសនា នារហូត ដល់ ទៅ ទស្សនវិជ្ជា នៅ ទីកន្លែង នោះ។

លុះ ដល់ ស.វ. ទី១២ ក្នុង រាជ្យ ព្រះបាទ សុរិយាវរ្ម័ន ទី២ (គ.ស. ១១១៣) មាន ការប្រែប្រួល ខ្លះ ក្នុង ព្រហ្មញ្ញ សាសនា គឺ ព្រះរាជា អង្គ នេះ ជា ព្រាហ្មណ៍ សាសនិក គោរព ព្រះវិស្ណុ ជា ធំ។ នៅ ចុង ស.វ. ទី១២ គេ បាន សង្កេត ឃើញ មាន ការវិល មក រក កាន់ ពុទ្ធ សាសនា។ មក ដល់ ស.វ. ទី១៣ ពុទ្ធ សាសនា ចំរើន លូតលាស់ ម្តង វិញ។ ព្រះបាទ ជ័យវរ្ម័ន ទី៧ ជា ពុទ្ធសាសនិក ដ៏ ឆ្នើម ទ្រង់ កាន់ ពុទ្ធ សាសនា មហាយាន គោរព ព្រះពោធិសត្វ លោកកេស្វរៈ និង ប្រាជ្ញា បារមិតា តាម ព្រះប្រពៃណី ព្រះវរបិតា។ ព្រះអង្គ ទ្រង់ ផ្លាស់ ប្រពៃណី ដែល ធ្លាប់ គោរព ទេវរាជ តាំង ពី ព្រះបាទ ជ័យវរ្ម័ន ទី២ មក ហើយ មក គោរព ពុទ្ធរាជ (culte du roi-Bouddha) វិញ។ ទោះ បី ព្រះអង្គ ជា ពុទ្ធសាសនិក មុតមាំ ក៏ ដោយ ក៏ ព្រះអង្គ នៅ តែ ប្រោសប្រាណ ព្រហ្មញ្ញ សាសនា ដែរ។ ព្រះអង្គ បាន សាង ប្រាសាទ ជា ច្រើន ដើម្បី ឧទ្ទិសថ្វាយ ព្រះពុទ្ធ សាសនា មាន ប្រាសាទ បាយ័ន ជា ដើម ហើយ ទ្រង់ បាន សាង ពុទ្ធបដិមា ជា តួអង្គ ពុទ្ធរាជ តំកល់ ក្នុង ប្រាសាទ បាយ័ន ដើម្បី ទុក ជា តំណាង ព្រះអង្គ បន្ទាប់ ពី ទ្រង់ ចូល ទីវង្គត ទៅ។ តែ ក្រោយ រជ្ជកាល ព្រះបាទ ជ័យវរ្ម័ន ទី ៧ ព្រះរាជា ដែល សោយរាជ្យ ជា តំណ រាជវង្ស ត្រឡប់ មក កាន់ ព្រហ្មញ្ញ សាសនា គណៈ ព្រះឥសូរ វិញ។ គេ ឃើញ មាន ប្រតិកម្ម នៃ ព្រហ្មញ្ញ សាសនា ដោយ មាន ការបំផ្លាញ ព្រះពុទ្ធរូប (វាយ បំបែក ខ្លះ រឺដាប់ យក ពុទ្ធរូប ចេញ)។ លុះ មក ដល់ ចុង ស.វ. ទី១៣ ពុទ្ធ សាសនា មហាយាន ក៏ សាបរលាប ទៅ ហើយ មក

ដល់ ស.វ. ទី១៤ ព្រហ្មញ្ញ សាសនា ក៏ បាត់បង់ ទៅ ទៀត នៅសល់ តែ ពិធី ខ្លះ ក្នុង រាជវាំង។ ចំណែក ឯ ពុទ្ធ សាសនា ភាសា បាលិ (ដែល នាំ ចូល មក នៅ ស.វ. ទី១២) ក៏ បាន លូតលាស់ ដុះដាល ចំរើន យ៉ាង ក្រៃលែង រហូត មក ដល់ សម័យ បច្ចុប្បន្ន នេះ។

អាស្រ័យ ដោយ ខ្មែរ បាន ទទួល កាន់ ព្រហ្មញ្ញ សាសនា និង ពុទ្ធ សាសនា ច្រើន សតវត្ស មក ហើយ ហើយ ទោះ បី ព្រហ្មញ្ញ សាសនា និង ពុទ្ធ សាសនា មហាយាន សាបរលាប ទៅវិញ ក៏ ដោយ ក៏ ឥទ្ធិពល នៃ សាសនា ទាំង ពីរ នោះ បាន ចាក់ ឫស យ៉ាង មាំ ក្នុង សន្តាន ចិត្ត ខ្មែរ និង ក្នុង សង្គម ខ្មែរ។ ពុទ្ធ សាសនា ថេរវាទ (និកាយ ហីនយាន) ប្រជួស និកាយ មហាយាន ចាប់ ពី សតវត្ស ទី១៤ មក ហើយ និកាយ ថ្មី នេះ មិន គ្រាន់ តែ ជា សាសនា ចំពោះ ពុទ្ធសាសនិក ប៉ុណ្ណោះ ទេ គឺ បន្ត ក្រោយ មក ក្លាយ ទៅ ជា របប ជីវិត សំរាប់ ការរស់នៅ របស់ ប្រជារាស្ត្រ ខ្មែរ តែ ម្តង។ ក្រោយ មក ទៀត ពុទ្ធ សាសនា ថេរវាទ នៅ ស្រុកខ្មែរ បែក ជា ពីរ គណៈ : ធម្មយុត្តិក និកាយ និង មហានិកាយ រហូត មក ដល់ សព្វថ្ងៃ។

# ភាសា ខ្មែរ

ជនជាតិ ខ្មែរ មាន ភាសា សំរាប់ ប្រាស្រ័យ ទាក់ទង គ្នា ទៅ វិញ ទៅ មក នៅ ក្នុង សង្គម ជាតិ របស់ ខ្លួន តាំង ពី កំណើត ជាតិ សាសន៏ ខ្មែរ មក ម្លេះ (៣000 ឆ្នាំ មុន គ.ស.)។ នៅ ក្នុង សាកល លោក សព្វថ្ងៃ មាន អំបូរ ភាសា ធំៗ ចំនួន ២០។ ភាសាវិទូ បាន បញ្ចូល ភាសា ខ្មែរ ទៅ ក្នុង អំបូរ ខ្មែរ-មន ដែល ជា អំបូរ ភាសា ធំ មួយ ជាង គេ ក្នុង បណ្តា ភាសា នៅ អាស៊ី ភាគ ខាង ត្បូង ដូចយ៉ាង អំបូរ ភាសា អូស្ត្រូ អាស៊ី, ម៉ាឡាយូ-ប៉ូលីនេស៊ី និង អំបូរ ភាសា ថៃ-វៀតណាម។ ភាសា ខ្មែរ មាន វិវត្តន៏ បី កាល ធំៗ : ភាសា ខ្មែរ បុរាណ (តាំង ពី កំណើត មក ដល់ សតវត្សរ ទី ១៥ - ភាសា ខ្មែរ កណ្តាល (ស.វ. ទី១៦ ដល់ ស.វ. ទី ១៨) - ភាសា ខ្មែរ បច្ចុប្បន្ន។ លក្ខណ: ពិសេស នៃ ភាសា ខ្មែរ ទៅ នឹង ភាសា ខ្លះទៀត ជា ពិសេស ភាសា បាលី-សំស្រ្កឹត គឺ នៅ ត្រង់ ភាសា ខ្មែរ  ពុំ មាន សម្លេង ឡើង ចុះ ឬ លើក ដាក់ ខ្ពស់ ទាប ទៅ តាម សញ្ញា ដាក់ ពី លើ ពាក្យ ដែល នាំ អោយ ផ្លាស់ ប្តូរ ន័យ របស់ ពាក្យ នោះ ទេ។ នេះ ជា ចំណុច សំខាន់ មួយ ដែល បង្ហាញ នូវ សភាព ប្លែក គ្នា រវាង ភាសា ខ្មែរ-មន និង ក្រុម ភាសា ចិន-យួន-សៀម-លាវ ដែល ជា ភាសា ភ្ជាប់ ងាយ ទៅ នឹង ស ម្លេង ខ្ពស់ ទាប ឬ ចុះ ឡើង (langues toniques)។ ចំណុច

ពិសេស នេះ ក៏ អាច បញ្ជាក់ ថា ភាសា ខ្មែរ មាន លក្ខណៈ ពិសេស ខ្លួន ពោល គឺ ពុំ មែន កើត ចេញ ពី ភាសា ណា មួយ ឡើយ។ ទំនាក់ទំនង រវាង ខ្មែរ និង បរទេស ធ្វើ អោយ មាន ល្បាយ ភាសា បរទេស ក្នុង ភាសា ខ្មែរ ពិត មែន ក៏ ប៉ុន្តែ ការ ទទួល ឥទ្ធិពល ភាសា បរទេស នេះ តែង ប្រព្រឹត្ត ទៅ ដោយ ការ ប្រែសំរួល អោយ ស្របស្រួល ទៅ នឹង ភាសា ជាតិ ជា ដរាប តួយ៉ាង ដូច ជា ខេមរនីយកម្ម ចំពោះ ភាសា បាលី-សំស្ក្រឹត។

# អក្សរ ខ្មែរ

អក្សរ ខ្មែរ ដែល ខ្មែរ យក គំរូ តាម អក្សរ ឥណ្ឌា ខាង ត្បូង មក ប្រើប្រាស់ ក្នុង សម័យ បុរាណ ពុំ ដូច គ្នា នឹង អក្សរ សម័យ បច្ចុប្បន្ន នេះ ទេ គឺ ត្រូវ បាន កែប្រែ ទ្រង់ទ្រាយ ចំនួន ១០ ដង រួច មក ហើយ ទើប បាន ជា រូបរាង ពិត ប្រាកដ ដូច តួ អក្សរ ដែល ខ្មែរ ប្រើប្រាស់ សព្វថ្ងៃ។ អក្សរ ខ្មែរ ក៏ ពុំ មែន ជា សញ្ញា ដាច់ ចេញ ពី គ្នា ដែល គេ ចេះ តែ យក មក កត់ សំគាល់ ស ម្លេង នោះ ឡើយ។ តែ ជា អក្សរ មាន កម្រង សញ្ញា ដែល ទាក់ទង គ្នា ជា ក្បួន ទៅ លើ មូលវិធី ពិត ប្រាកដ។ ខ្មែរ បាន យក លំនំ តាម អក្សរ ឥណ្ឌា មក ប្រើប្រាស់ ជា លើក ដំបូង ក៏ ពិត មែន ក៏ ប៉ុន្តែ បន្ទាប់ មក ខ្មែរ មាន ទេពកោលសល្យ ខាង ឆ្នៃ អោយ បាន សមសួន ខាង បង្កើត ថ្មី អោយ សម្បូរ គ្រប់ គ្រាន់ ព្រម ទាំង អោយ មាន ក្បួន ខ្នាត មាន វិធី ច្បាស់លាស់ សំរាប់ ជាតិ ខ្មែរ យក ទៅ ប្រើការ បាន យ៉ាង ងាយ ក្នុង ការ កត់ត្រា គំនិត មនោសញ្ចេតនា ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ ។ល។ ខ្មែរ បង្កើត វចនានុក្រម នៅ ឆ្នាំ ១៩១៥[23] ដើម្បី សម្រួល ដល់

[23] ជាស្នាដៃរបស់គណកម្មការមួយក្រុមធំ អោយរៀបចំ។ គណកម្មការនោះ បាន ប្រឹក្សាយ៉ាងយូរ ក៏មូលមតិគ្នាជាឯកច្ឆន្ទ ក្នុងការសេសេរអក្សរខ្មែរ ជាផ្លូវការ។ ក្រោយមក មានការស្នើ សុំការឧបត្ថម្ភ សំរាប់បោះពុម្ពគ្រាទី៥ ពីគណកម្មការ នៃ ពុទ្ធសាសនាបណ្ឌិត្យ ដល់ សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ ជួន ណាត ជោត

ការសរសេរ ជា ផ្លូវការ អោយ ឈ្មោះ ថា វចនានុក្រម ខ្មែរ របស់ រាជការ ប៉ុន្តែ កាល ដែល បោះពុម្ព គ្រាទី១ ជា ដំបូង បង្អស់ អស់ លោក កុង្សីយ៍ សេនាបតី ក្នុង សម័យ នោះ សុំ ថា អោយ ដាក់ ឈ្មោះ ត្រឹមតែ វចនានុក្រម ភាគ ទី១ ភាគ ទី២ កុំ ដាក់ ពាក្យ ថា របស់ រាជការ ព្រោះ បើ ដាក់ ឈ្មោះ ថា របស់ រាជការ ក៏ ទៅ ជា បង្ខំ អោយ គេ ប្រើ តាម ទាំងអស់ គ្នា ដោយ ដាច់ ខាត, ដោយ ហេតុនេះ ត្រូវ ទុក ឱកាស អោយ គេ ទៅ សិន បើ អ្នក ណា គេ មិន ត្រូវ ការប្រើ តាម ក៏ ឥត មាន កំហុស អ្វី ឡើយ, យូរៗ ទៅ គង់ តែ នឹង ប្រើ តាម ទាំងអស់ គ្នា ឯងៗ ទៅ ទេ។

---

ញ្ញាណោ   អោយព្រះអង្គជួយកែសម្រួលអោយបានគ្រាន់បើជាងពីមុនដោយអន្លើងៗ ព្រោះ វចនានុក្រមនេះ ជាស្នាដៃថ្មីគំនិតចាស់របស់ព្រះអង្គ។

# អក្សរសិល្ប៍ ខ្មែរ

គេ ស្គាល់ អក្សរសិល្ប៍ ខ្មែរ តិច ជាង សិល្បៈ ខ្មែរ ទោះ បី មាន កំណើត ក្នុង ពេលវេលា ជា មួយ គ្នា ក្តី។ គ្រប់ មហា ក្សត្យស្ថាបនិក មហា នគរ ខ្មែរ ព្រះអង្គ បាន ចារ ទុក អត្ថបទ ជា ច្រើន លើ ផ្ទាំង ប្រាសាទ លើ ស្លឹក ត្នោត ជា ហូរហែ បន្តគ្នា មាន នៅ ក្នុង មហា រយៈពេល នៃ ប្រវត្តិសាស្ត្រ ខ្មែរ ដែល ជា ការបញ្ជាក់ អំពី អត្ថិភាព នៃ អក្សរសិល្ប៍ ខ្មែរ ទោះ បី អក្សរសិល្ប៍ ទាំងឡាយ នោះ គ្មាន រូបី ជា **ទិស្សមាន**[24] ដូច មហា ប្រាសាទ អង្គរ ដែល ទាក់ទាញ អារម្មណ៍ អ្នក សិក្សា វិជ្ជា ខាង បូព៌ា ប្រទេស, តែ ចំណារ ដែល មាន ចារ ទុក ជា ទូទៅ នោះ អាច ជា ជំនួយ សំរាប់ បំភ្លឺ អំពី ប្រវត្តិសាស្ត្រ, វប្បធម៌ និង អារ្យធម៌ ខ្មែរ បាន ដូច រូបភាព នៃ ប្រាសាទ នោះ ដែរ។

ហេតុ ដូច្នេះ មន្ទិល អំពី អត្ថិភាព នៃ អក្សរសិល្ប៍ ខ្មែរ ទុក ជា មោឃភាព។ តែ បញ្ហា នៅ មាន ចោទ គឺ ថិន នៅ លើ សំណួរ សួរ ថា តើ អក្សរសិល្ប៍ ខ្មែរ ជា វិទ្យាស្សង្ស ដែរ ឬទេ ដែល មាន ចារ ទុក ក្នុង ប្រវត្តិសាស្ត្រ របស់ ខ្លួន។ តែ ប្រវត្តិសាស្ត្រ អក្សរសិល្ប៍ ខ្មែរ ជា វិទ្យាសង្ស មិន ដូច ជា វិទ្យាសង្ស ដែល គេ យក មក សិក្សា នៅ មស្ចឹម ប្រទេស នោះឡើយ។ ហើយ ចុះ បើ វិទ្យាសង្ស នៃ អក្សរសិល្ប៍ នេះ ទៀត ទើប តែ ចាប់ ផ្តើម មាន

[24] ទិស្សមាន= អាចមើលឃើញ ; visible។

ក្រោយ កំណើត នៃ អត្ថបទ ចំណារ រឿង និទាន រឿង ព្រេង កំណាព្យ អណ្ដែត អណ្ដូង អត្ថបទ ជា ឧបទេស រឿង ល្ខោន ប្រលោមលោក សសេរ សាកល្បង មាន លក្ខណៈ ជា សាសនា ក្ដី ជា ទស្សនវិជ្ជា ក្ដី បញ្ចេញ ឲ ដឹង នូវ មនោសញ្ចេញនា របស់ ខ្មែរ តាំង ពី យូរយារ មក ហើយ។

អក្សរសិល្ប៍ មាន កំណើត ស្មើ នឹង ប្រវត្តិសាស្ត្រ ខ្មែរ ដែរ ព្រោះ គេ បាន ដឹង តាំង ពី យូរលង់ ណាស់ មក ហើយ អំពី ការរស់នៅ នៃ របប គ្រប់គ្រង ព្រឹត្តិការណ៍ ផ្សេងៗ នៃ សង្គម ជា ដើម ក៏ ដោយសារ អត្ថបទ សរសេរ ឬ ចារ ទុក តាំង ពី ពេល នោះ ម្លេះ។ ជា ភស្តុតាង គឺ អត្ថបទ ចារ លើ ផ្ទាំង សិលា ដែល មាន ចំណា ស់ៗ ហើយ ដែល សរសេរ សល់ គង់វង់ រហូត មក ដល់ សព្វថ្ងៃ នេះ។ ក្រៅ ពី សិលាចារឹក នៅ មាន អត្ថបទ អក្សរសិល្ប៍ ជា ច្រើន ទៀត ដែល កត់ត្រា បន្ត បន្ទាប់ នៅ លើ សម្ភារៈ ផ្សេងៗ ដូច ជា : ស្បែក សត្វ ស្លឹករឹត ក្រាំង ក្រដាស។ អក្សរសិល្ប៍ ក៏ ដូច អក្សរ ខ្មែរ ដែរ តែង បាន ទទួល ឥទ្ធិពល បរទេស ផ្សាយ ចូល មក ជា ហូរហែ។ ឯ អក្សរសិល្ប៍ បរទេស មាន ឥទ្ធិពល ខ្លាំង ជាង គេ គឺ អក្សរសិល្ប៍ សាសនា និយម មាន អក្សរសិល្ប៍ ព្រហ្ម ញ្ញ សាសនា និង អក្សរសិល្ប៍ ពុទ្ធ សាសនា នេះ ឯង។

ចំពោះ អក្សរសិល្ប៍ ខ្មែរ គេ សង្កេត ឃើញ ថា មាន វិវត្តន៍ យ៉ាង ខ្លាំង ទៅ តាម សម័យ កាល ធំៗ នៃ ប្រវត្តិសាស្ត្រ របស់ ស្រុកខ្មែ រ។ នៅ សម័យ អង្គរ គេ បាន ដឹង ច្បាស់ ថា មហិទ្ធិឫទ្ធិ ខ្មែរ

បាន ឡើង ដល់ កំរិត ជា កំពូល រីឯ អក្សរសិល្ប៍ ក៏ រីកចំរើន ខ្លាំងក្លា ដែរ ប៉ុន្តែ ចុះ ថយ វិញ នៅ ពេល ដែល ស្រុកខ្មែរ ត្រូវ ឈ្លានពាន ពី សំណាស់ បរទេស។ លុះ មក ដល់ ស.វ. ទី១៨ និង ១៩ ស្នាដៃ អក្សរសិល្ប៍ ក៏ ស្ទុះងើប ឡើង បន្តិច ប៉ុន្តែ ត្រូវ ថយ ឥទ្ធិពល ម្តង ទៀត នៅ ពេល ដែល ខ្មែរ ធ្លាក់ ខ្លួន នៅ ក្រោម អាណាព្យាបាល បារាំង រួច ទើប លូតលាស់ ចំរើន ឡើង ជា ថ្មី នា សម័យ ខ្មែរ បាន ឯករាជ្យ។ នៅ សម័យ ដឹកនាំ ដោយ របប កុម្មុយនិស្ត (ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៩១) អក្សរសិល្ប៍ ចុះ ថយ ឥទ្ធិពល ជា ថ្មី រហូត មក ដល់ សព្វថ្ងៃ ព្រោះ ស្រុកខ្មែរ ទោះ បី ក្លាយ មក វិញ ជា របប រាជានិយម អាស្រ័យ រដ្ឋធម្មនុញ្ញ តែ ពួក អ្នក ដឹកនាំ សព្វថ្ងៃ ជា ពួក អតីត កុម្មុយនិស្ត ដ៏ដែល។ ជា ពិសេស ស្រុកខ្មែរ សព្វថ្ងៃ រស់ នៅ ក្រោម ឥទ្ធិពល ខ្លាំងក្លា យួន-ចិន ដែល ពួក នេះ គេ នាំ ចូល មក ស្រុកខ្មែរ ទាំង ប្រជាជន គេ ច្រើន ក្រៃលែង ផង និង អរិយធម៌ ខ្លាំងក្លា របស់ គេ ផង។ អក្សរសិល្ប៍ ខ្មែរ សព្វថ្ងៃ ក្លាយ ជា អក្សរសិល្ប៍ បន្ទាប់បន្សំ សំរាប់ ខ្មែរ នៅ ក្នុង ស្រុកខ្មែរ ដែល ជា  ទីលំហ (espace) ដែល យួន-ចិន គេ ដណ្តើម បាន និង នៅ ក្នុង ឥទ្ធិពល នៃ សាកលលោកូបរិយកម្ម នោះ ឯង។

# សិល្បៈ ខ្មែរ

ភស្តុតាង ជា រូបភាព ពិត នៃ ប្រាសាទ ដ៏ វិចិត្រ ទាំងឡាយ បញ្ជាក់ នូវ ទេពកោសល្យ នៃ បុព្វបុរស ខ្មែរ ដែល លោក ចែក ទុក ជា កេរ្តិ៍ ដល់ ខ្មែរ ជំនាន់ ក្រោយ បន្ត មក រហូត មក ដល់ សព្វថ្ងៃ។ ដូច នេះ តើ ខ្មែរ បច្ចុប្បន្ន មាន សមត្ថភាព អាច ថែ រក្សា នឹង ធ្វើ វិក្រិតការ មរតក រួម ទាំង នោះ បាន ដែរ ឬទេ ?

នៅ ទីនេះ យើង មិន យក ផ្នែក សិល្បៈ ខ្មែរ មក ពិពណ៌នា យ៉ាង ពិស្តារ នោះ ទេ ព្រោះ វា មាន ទំហំ ធំ ណាស់ ពោល ថា បើ ចង់ អធិប្បាយ ត្រូវ សរសេរ ជា សៀវភៅ មួយ តែ ម្តង។ មួយ វិញ ទៀត ក៏ ពុំ មែន ជា គោលដៅ ចម្បង របស់ ការសាកល្បង របស់ យើង នោះ ដែរ។ តែ បើ អ្នកអាន មាន ចំណង់ ចង់ ដឹង អំពី ភូមិ សិល្បៈ ខ្មែរ អ្នកអាន អាច រក អាន សៀវភៅ ជា ច្រើន ដែល សរសេរ ដោយ ប្រវត្តិវិទូ បរទេស និង ខ្មែរ។

# ស្ថាប័ន ជាតិ ខ្មែរ

តាម អ្នក ស្រាវជ្រាវ គេ មិន ឃើញ មាន លំអាន នៃ របៀប បក ស្រាយ ជា ភាសារ ខ្មែរ ស្តី ពី ក្បួន នយោបាយ ឥណ្ឌា តែ គេ ឃើញ មាន ចំណារ ជា ច្រើន ជា ភាសារ សំស្ក្រឹត ក្នុង ចារឹកសាស្ត្រ ខ្មែរ កំណត់ អំពី នយោបាយវិទ្យា ដូចយ៉ាង ប្រើ ពាក្យ : arthaçâstra, râjadharma, dandanîti, nîtiçastra, etc.

ព្រះមហាក្សត្យ ខ្មែរ ត្រូវ សិក្សា ច្បាប់ dandanîti ហើយ យក គោលការណ៍ ទាំងឡាយ របស់ វា មក អនុវត្ត ក្នុង កិច្ចការ រដ្ឋ បាល ព្រោះ ថា ច្បាប់ នេះ គឺ ជា មធ្យោបាយ សំរាប់ ព្រះអង្គ បំពេញ ករណីយកិច្ច របស់ ព្រះអង្គ ជា មហាក្សត្រ នោះ ឯង។ វិញ្ញាតិ râjavidyâ កំណត់ រាជ្យវិទ្យា (science royale) ដែល ព្រះ មហាក្សត្រ ខ្មែរ ទុក ជា វិទ្យាគត (science héréditaire) សំរាប់ ទាយាទ នៃ រាជ្យសម្បត្តិ។ nîtiçâstra ឬ វិទ្យាសីលគន្ធ (science conduite) ទំនង ជា វិទ្យា មាន ប្រជាប្រិយភាព ណាស់ ព្រោះ ប្រជារាស្ត្រ តែងតែ សរសើរ លើក តម្កើង ព្រះមហាក្សត្រ អំពី ចរិយាសម្បត្តិ របស់ ព្រះអង្គ គឺ ថា ព្រះមហាក្សត្រ ល្អ គឺ ជា ព្រះ មហាក្សត្រ មាន សីលគន្ធ។

គឺ គ្មាន អ្វី ជា មន្ទិល ថា រឿង វីរភាព (épopée) Mahâbhârata និង Râmâyana ឥណ្ឌូ គ្មាន អត្ថភាព នៅ ស្រុកខ្មែរ នោះឡើយ ព្រោះ គេ ឃើញ មាន ចំណារ លើ សិលាចារិក មួយ នៅ សតវត្ស ទី៦ ស្ដីពី អំណោយ សាត្រា ស្លឹករឹត Sambhava ដល់ វិហារ មួយ ឈ្មោះ ប្រាសាទ ព្រះថាទ និង ព្រាហ្មណ៍ Somaçarman នៅ សតវត្ស ទី៧ ប្រគេន សាត្រា គ្រប់ លេខ Mahâbhârata, Râmâyana និង Purânas ជូន ព្រះ សំរាប់ ទុក ធ្វើ បាឋកថា រៀងរាល់ ថ្ងៃ។ នៅ ប្រាសាទ អង្គរវត្ត មាន ក្បាច់ រំលេច រៀបរាប់ ពី រឿង Mahâbhârata, រឿង Harivamça និង រឿង ស្រដៀង គ្នា នឹង រឿង Mahâbhârata។

ប៉ុន្តែ រឿង វីរភាព ឥណ្ឌូ មិន មែន មាន ទិដ្ឋភាព ត្រឹម តែ ជា ប្រលោមលោក មានិត នោះឡើយ គឺ នៅ ក្នុង សាច់រឿង វា ជា មូលដ្ឋាន សំខាន់ នៃ ព័ត៌មាន លើ ប្រភព នៃ ស្ថាប័ន នយោបាយ អធុនាគត[25]; វា បង្ហាញ អំពី ទស្សនៈ ឥណ្ឌូ ស្ដីពី រាជាធិបតេយ្យ ផង ដែរ។ ដូច្នេះ សេវនៈ[26] របស់ ខ្មែរ ជា មួយ មហា រឿង វីរភាព ទាំង ពីរ នោះ វា រួម បញ្ចូល ផង ដែរ ចំណេះ ចេះដឹង ពិត ប្រាកដ អំពី ស្ថាប័ន និង ចិត្តគំនិត នយោបាយ ឥណ្ឌា។ បុព្វបុរស ខ្មែរ ច្បាស់ ជា បាន អាន ពី បរិយាយ អំពី រជ្ជកាល គតិបណ្ឌិត របស់ ព្រះរាជា Dusyanta ដែល ទ្រង់ ចេះ

[25] ស្ថាបន នយោបាយ អធុនាគត ; instutions politiques contemporaines.
[26] សេវនៈ : ការរាប់រក ; familiarité។

រក្សា សណ្តាប់ធ្នាប់ នៃ វណ្ណៈ សង្គម និង ការដឹកនាំ នគរ តាម សិក្ខាបទ នៃ ធម៌។

បុព្វបុរស ខ្មែរ ស្គាល់ ផង ដែរ dharmaçâstra ព្រោះ មាន ចារ លើ សិលាចរឹក អំពី សេចក្តីសរសើរ ដល់ ព្រះមហាក្សត្រ សូរ្យវរ្ម័ន ទី១ (១០០២-១០៥០) ដោយ ប្រៀប ប្រដូច បញ្ញា និង សញ្ញាគ្គ របស់ ព្រះអង្គ ផ្នែក អវៈយវៈ ជា វិទ្យាសាស្ត្រ ផ្សេងៗ ហើយ ព្រះកេសី ជា dharmaçâstra។ នៅ សតវត្ស ទី៧ ព្រាហ្មណ៍ Jaimini បង្កើត សាលា pûrvamîmâmsâ ក្នុង គោល បំណង សំខាន់ គឺ ដើម្បី សិក្សា វែកញែក អំពី វិធាន នៃ dharmaçâstra។ អត្ថភាព នៃ សាលា នោះ ស អោយ ឃើញ ថា ការសិក្សា នៃ dharmaçâstra មាន ជម្រៅ ខ្លាំង ក្នុង សម័យ បុរាណ ខ្មែរ។ គួរ កត់ សំគាល់ ថា នៅ ក្នុង dharmaçâstra មាន ខណ្ឌ អភិប្រាយ អំពី ព្រះរាជ ករណីយកិច្ច (râjadharma) និង រដ្ឋបាល នៃ តុលាការ។

## ទ្រឹស្តី នៃ វត្ថុធាតុ ៧ យ៉ាង ទុក ជា បតិដ្ឋាប័ន នៃ រដ្ឋ

ទ្រឹស្តី នៃ វត្ថុធាតុ ៧ យ៉ាង ទុក ជា បតិដ្ឋាប័ន នៃ រដ្ឋ[27] មាន នៅ ក្នុង ទ្រឹស្តី ឥណ្ឌូ គឺ : svâmin (ប្រមុខរដ្ឋ), amâtya (នាយទាហាន), janapada (ប្រជាជន និង ដែនដី), durga (បន្ទាយ បូរី), koça (ឃ្លាំង ទ្រព្យ), danda (កងទ័ព) និង mitra (សម្ពន្ធ

[27] La théorie des sept éléments constitutifs de l'Etat.

មិត្ត)។ នៅ ក្នុង ចំណារ ខ្មែរ ក៏ ដូច នៅ ក្នុង ក្បួន ឥណ្ឌូ គេ កំណត់ វត្ថុធាតុ ទាំង ៧ យ៉ាង ក្នុង លក្ខខណ្ឌ ពាក្យ (termes) anga និង prakrti : លក្ខខណ្ឌ ពាក្យ ទី១ គឺ សំដៅ លើ វត្ថុធាតុ ៧ យ៉ាង ទុក ជា បតិដ្ឋាប័ន នៃ រដ្ឋ។ លក្ខខណ្ឌ ពាក្យ ទី២ គឺ មាន អត្ថន័យ ជា គំនិត ល្អិតល្អន់ និង ជា និមិត្តហេតុ (nuancé) ដែល ព្រាហ្មណ៍ Aparâka ពន្យល់ ថា ‹ចេញ ពី prakrti នេះ ឯង ដែល មាន សញ្ញាតអនុភាព[28] ជា និយតភាព ដូច ជា មាស ដែល ជាង ទង យក មក ឆ្លាក់ ធ្វើ ជា ក្រវិល ដ៏ សុវិចិត្រ។

ក្នុង ចំណោម វត្ថុធាតុ ទាំង ៧ ក្បួន ខ្មែរ និង ឥណ្ឌា ទុក svâmin (ប្រមុខរដ្ឋ) ជា វត្ថុធាតុ ចម (pradhâna prakrti) ដូច មាន នៅ ក្នុង ចំណេរ របស់ ព្រាហ្មណ៍ Kautilya : ‹ព្រះមហាក្សត្រ មាន អភិសមាចារ[29] អាច អោយ វត្ថុធាតុ ដទៃ ទៀត ដែល គ្មាន ការ រីកចំរើន ក្លាយ បាន ជា វត្ថុធាតុ បំណិន..›។

មូលដ្ឋាន សំខាន់ នៃ ចិត្តគំនិត នៃ នយោបាយវិទ្យា ស្ដីពី ទ្រឹស្ដី នៃ វត្ថុធាតុ ៧ យ៉ាង ជា បតិដ្ឋាប័ន នៃ រដ្ឋ មាន នៅ ក្នុង បុព្វសម័យ អង្គរ ដែល បុព្វបុរស ខ្មែរ ចេះ ឆ្នៃ ជា ជម្រៅ អោយ ក្លាយ ជា ទ្រឹស្ដី ខ្មែរ ពិត សំរាប់ ធ្វើ ជា ក្បួន សំខាន់ សំរាប់ ដឹកនាំ ជាតិ។ ការបំប្លែក ដ៏ មាន សម្ថភាព នេះ ឯង ដែល ទុក ជា ទេពកោសល្យ នៃ បុព្វបុរស ខ្មែរ។

28 សញ្ញាតអនុភាព; អនុភាពដែលកើតឯង។
29 អភិសមាចារ គឺ មានមារយាទល្អក្រៃ ឬ ការប្រព្រឹត្តរៀបរយគួរអោយពេញចិត្ត។

តាម ការសិក្សា របស់ លោក Jean IMBERT[30] ជនជាតិ បារាំងសែស ជា អតីត ព្រឹទ្ធសាស្ត្រចារ្យ មហាវិទ្យាល័យ ច្បាប់ និង វិទ្យាសាស្ត្រ សេដ្ឋកិច្ច នៅ ភ្នំពេញ លោក ចែក វិវត្តិន៍ នៃ ស្ថាប័ន ខ្មែរ ជា បី កាល :

កាល ទី១ : ចាប់ពី ឆ្នាំ ៨០២ គឺ ជា ឆ្នាំ ឡើង គ្រង រាជសម្បត្តិ ព្រះបាទ ជ័យវរ័ន្ទ ទី២ រហូត ដល់ឆ្នាំ ១៥៩៣ ជា ឆ្នាំ សៀម វាយ បែក បន្ទាយ លង្វែក។ អំឡុង កាល នោះ ស្ថាប័ន ខ្មែរ មាន ចរឹត លក្ខណៈ ជា ស្ថាប័ន យុគ កណ្ដាល។ មាន សេចក្ដីរុងរឿង នៅ សម័យ មហា នគរ តែ ចាប់ ពី ប្រមាណ ឆ្នាំ ១៣០០ នៅ ក្នុង វស្សបវត្តិ (les annales) ខ្មែរ ចាប់ មាន ការច្របូកច្របល់ ហើយ លែង ស្រប គ្នា នឹង ឯកសារ ចិន និង សៀម។ ព្រឹត្តិការ ណ៍ បី នោះ អាច នឹង ពន្យល់ បាន អំពី បំលាស់ប្តូរ នោះ :

- តើ មក ពី ការរុករាន ប្រទេស សៀម មក ក្នុង ស្រុកខ្មែរ និង វិវត្តន៍ នៃ ពុទ្ធសាសនា ដល់ ការវិនាស នៃ ព្រហ្មញ្ញ សាសនា មក ពី ឥទ្ធិពល សៀម ដែល ជា នគរ គោរព ពុទ្ធ សាសនា ម៉ឺងមាត់ ?
- តើ មក ពី ការប្តូរ សន្តតិវង្ស មហា នគរ មក តាត្រសក់ ផ្អែម ជា រាស្ត្រ សាមញ្ញ ជា ឧឡានបាល របស់ ព្រះរាជា ដែល នាំ អោយ បាត់ កិត្យានុភាព នៃ ស្រុកខ្មែរ ?

[30] Histoire des institutions khmères par Jean IMBERT (1961).

- តើ មក ពី ពលក្ការ សៀម[31] កាន់ តែ ខ្លាំង ឡើងៗ ចំពោះ ស្រុកខ្មែ ដែល នាំ អោយ មហាក្សត្រ ខ្មែរ បោះបង់ ទីក្រុង មហា នគរ មក តាំង នៅ ស្រុកស្រីសន្ធ បន្ទាប់ មក នៅ ភ្នំពេញ (១៤៣៤ ឬ ១៤៤៦) ?

កាល ទី២ : ពី ឆ្នាំ ១៥៩៣ ដល់ ឆ្នាំ ១៨៦៣ ឆ្នាំ ដែល បារាំង ទទួល ការពារ ស្រុកខ្មែរ តាម ការស្នើ ពី ព្រះរាជា ខ្មែរ នៅ ក្នុង ក្របខណ្ឌ កតិកាសញ្ញា អាណាព្យាបាល ខ្មែរ-បារាំង ដែល បារាំង គេ តែង ទុក ជា ការសង្គ្រោះ ប្រជាជាតិ ខ្មែរ ពី មហិច្ឆិត តា ទឹកដី នៃ ប្រទេស ជិត ខាង ខ្មែរ មាន សៀម និង យួន ដែល កំពុង នាំ គ្នា ចែក ទឹកដី ខ្មែរ ជា ពីរ។ អំឡុង ពេល នោះ ស្រុកខ្មែរ ជួបប្រទះនឹង វិបត្តិ ធំ ចម្បង គឺ អស្ថិរភាព នយោបាយ ក្នុង ប្រទេស ដែល នាំ អោយ ស្រុកខ្មែរ លែង មាន មុខ មាត់ នៅ អាស៊ី អាគ្នេយ៍។

កាល ទី៣ : ចាប់ ពី ឆ្នាំ ១៩០៧ ឆ្នាំ ដែល ចាប់ មាន អនុភាព វិជ្ជមាន ពី ការកំណែទំរង់ របស់ បារាំង នៅ ស្រុកខ្មែរ (១៨៨៤ និង ១៨៩៧) អោយ មាន ស្ថាប័ន ទំនើប ខ្លះៗ ទាំង ផ្នែក រដ្ឋបាល និង យុត្តិធម៌ ដែល នាំ អោយ មាន ការរីកចំរើន សេដ្ឋកិច្ច។ ក្រោយ ពី ស្រុកខ្មែរ ទទួល បាន ឯករាជ្យ បរិបូណ៌ នៅឆ្នាំ ១៩៥៣, ជា ប្រទេស មាន ស្ថាប័ន ទំនើប រួច ខ្លះ ហើយ, អ្នក ដឹកនាំ ខ្មែរ បន្ត កែ ឆ្នៃ នូវ ស្ថាប័ន ជាតិ នោះ អោយ កាន់ តែ

[31] ពលក្ការសៀម, ការគំរាមសៀម ; menace thaïlandaise.

ទំនើប និង កាន់ តែ ប្រសើរ ដែល ខ្លួន ត្រូវការ សំរាប់ អភិវឌ្ឍន៍ គ្រប់ វិស័យ ជាតិ។

# ភាពទូទៅ នៃចិត្តគំនិត

## សង្គមពហុវិជ្ជា

តែ ត្រូវ ដឹង ដែរ ថា នៅ ក្នុង បច្ចុប្បន្នកាល ការទទួល ព័ត៌មាន ច្រើន ហួស ប្រមាណ តាម រយៈ ឧបករណ៍ អសន្សាណូ[32] វា នាំឲ យើង មាន ការលំបាក កាន់ តែ ច្រើន សំរាប់ ធ្វើ បរិបទកម្ម, រៀប ចំចាត់ចែង, ស្វែ រក ការពិត ស្ទើរ តែ មិន អាច ធ្វើ ទៅ រួច ក្នុង ការយល់ និង គិតគូរ អំពី បញ្ហា គ្រឹះ និង ទាំងអស់ នៃ ចំណេះដឹង។ ជំនាញ ខ្ពង់ខ្ពស់ ហួសហេតុ វា នាំ បំបែក មិស្ស ជាលិកា (tissu complexe) នៃ ការពិត ហើយ លំនាំ វិសិដ្ឋភាព ដែល មិន កំរិត បាន វា គ្រប បាំង ភាព ពិត ជាក់ ស្តែង នៃ ជីវភាព រាល់ ថ្ងៃ របស់ មនុស្ស។ ជា ឧទាហរណ៍ នៅ ស្រុកខ្មែរ សព្វ ថ្ងៃ វា មាន អតិផរណា នៃ ក្រុម បណ្ឌិត គ្រប់ មជ្ឈដ្ឋាន គ្រប់ វិស័យ ដែល វា គ្រប បាំង ភាព ពិត កម្រិត នៃ ចំណេះដឹង របស់ ប្រជាពលរដ្ឋ ព្រោះ ស្ទើរ គ្រប់ ការផ្តល់ យោបល់ និង ធ្វើ វិភាគ ទាំងអស់ សុទ្ធ តែ ធ្វើ ឡើង ក្នុង ការប្រើ នាម ជា បណ្ឌិត ជា អ្នក ជំនាញ នៅ ក្នុង លំនាំ ខ្ពស់ បំផុត ដែល ជា ការខាឃាំង ចង់ ឬ មិន ចង់ ដល់ អ្នក ដទៃ ជា បថុជ្ជន មិន ឱ្យ បញ្ចេញ

32 អសន្សាណូ : អេឡិចត្រូនិច។

មតិ បាន និង ចូលរួម ពិភាក្សា ព្រោះ មាន ហីនមានះ នៅចំពោះ មុខ លោក ឬ ឯកឧត្តម បណ្ឌិត ដ៏ ច្រើនក្រៃ។

ម្យ៉ាង មួយ ទៀត វិធី នៃ ការបែកចែក ចំណេះដឹង ជា ចំណែកៗ ដាច់ គ្នា ផលិត នូវ ភាព ល្ងង់ខ្លៅ ទាំងអស់ ទៅ វិញ បើសិន ជា វា គ្មាន សំយោគ តំណ គ្នា ដើម្បី ឱ្យ មាន ខ្សែ នាយកនៃ គំនិត គ្រឹះ ដែល អាច ទុក បាន ជា ចំណេះដឹង ទាំងមូល។ មួយ វិញ ទៀត វិធី នៃ ការគិត កាត់ ភាគ ខ្លះ ចេញ ក៏ នាំ ឱ្យធ្វើ សកម្មភាព ជា ភាគៗ នាំ ឱ្យ ខ្វះ ចក្ខុវិស័យ រួម ដែល តម្រូវឱ្យ មាន សំរាប់ ដំណើរការ នៃ សកម្មភាព រួម ឱ្យ រលូន។

វិធី ទាំង ពីរ នេះ បង្រួប ដែន កំណត់ ជា ច្រើន ដូច យ៉ាង : ១. ឬក៏ ជា ការបន្ថយ និយម ( ដែល បន្ថយ ចំណេះដឹង ជា ឯកភាព នៃ មិស្ស គំនិត[33] ឲ ទៅ ជា វត្ថុធាតុ ដែល សន្មត់ ថា វាសាមញ្ញ ដែល បង្ក បង្កើត ចំណេះដឹង ដោយ ធ្វើ ការសន្មត់ ថាវា ដូច្នេះ ឯង) ; ២. ឬក៏ ជា ការ ធ្វើ បដិយោគ ទ្វិភាគ និយម (binarisme) ដែល ជា របៀប បំបែក ធាតុ នៃ ឯកភាពទាំងឡាយ ទៅ ជា ពីរ ភាគ ជំទាស់ គ្នា គឺ ពិត/មិន ពិត ; ទំនាក់ទំនង ហេតុ និង ផល នៃ បន្ទាត់ ត្រង់ (causalité linéaire) ដែល មិន រលំ នឹង រង្វិលជុំ (boucle) ប្រតិសកម្ម (rétroactif)

[33] មិស្សគំនិត : pensée complexe។ យើងប្រើវាក្យសព្ទ មិស្ស (complexe) ដែលខ្មែរយើងប្រើ ដូចយ៉ាង មិស្សភាគ (nombre complexe), មិស្សូស្សាហកម្ម (complexe industriel)។ វាក្យសព្ទនេះ វាប្រសើរជាងពាក្យ ស្មុគ្រស្មាញ ឬ ចម្រូងចម្រាស់ ដែលវាឱ្យអត្ថន័យ ជាអវិជ្ជមាន។

ដូច យ៉ាង បដិយោគ នៃ កុសល និង អកុសល (manichéisme) ដែល វា មិន អាច ឱ្យ មើល ឃើញ នូវ ទំនាក់ទំនង ប្រតិសកម្ម រវាង កុសល និង អកុសល នេះ ដែល ជា ទំនាក់ទំនង មាន អត្ថប្រយោជន៍ ផង និង វិជ្ជមាន ផង។

## កំណែទម្រង់ជាសាកល

ការពិនិត្យ កត់ត្រា នេះ ឯង ដែល នាំ ឱ្យ អ្នកប្រាជ្ញ មួយ ចំនួន ស្នើ ធ្វើ កំណែទម្រង់ នៃ ចំណេះដឹង សព្វ ថ្ងៃ។ កំណែទម្រង់ នេះ ហៅ រក កំណែទម្រង់ នៃ ចិត្តគំនិត នោះឯង។ កំណែទម្រង់ នៃ ចិត្តគំនិត ហៅ រក ការគិត នៃ ការចងភ្ជាប់ គំនិត ដែល បន្តៗ ភ្ជាប់ គ្នា, ភ្ជាប់ ផ្នែក និមួយ ទៅនឹង ទាំងអស់, ភ្ជាប់ ទាំងអស់ ទៅនឹង ផ្នែក និមួយៗ និង អាច ឲ យល់បាន ទំនាក់ទំនង នៃ សាកល ទៅនឹង មូលដ្ឋាន, មូលដ្ឋាន ទៅនឹង សាកល។ វិធី នៃ ការគិត របស់ មនុស្ស យើង ត្រូវ បញ្ចូល ការឡើង និង ចុះ ទៀងទាត់ នៃ ការគិត ជួនកាល វា ជា គំនិត ខ្ពស់ ជួនកាល វា ជា គំនិត ទាប តែ រវាង ខ្ពស់ និង ទាប នោះ វា មាន កំពស់ មធ្យម របស់វា ដែល អាច ទុក ជា គំនិត វិជ្ជមាន។

មួយ វិញ ទៀត កំណែទម្រង់ នេះ តម្រូវ ឲ មាន លក្ខណ: នៃ ការពិចារណា បែប គោលការណ៍ វិទ្យាសាស្ត្រ និង ឆ្លុះត្រឡប់[34]។ ការ

[34] ឆ្លុះត្រឡប់: réflexion។

ពិចារណា បែប គោលការណ៍ វិទ្យាសាស្ត្រ នេះ គឺ ប្រដូស គំរូ នៃ ការស្រាវជ្រាវ បែប វិទ្យាសាស្ត្រ ដែល បង្ខំ អោយ ទទួល ស្គាល់ តាម ការញែក ចេញ ពី គ្នា និង ការជួប គ្នា។ ការបញ្ចូល ឡើង វិញ នៃ ការឆ្លុះត្រឡប់ វា តម្រូវ ឱ្យ មាន ការវិលត្រឡប់ នៃ ស្វ័យ ពិនិត្យ និង ស្វ័យទិតៀន ជា អចិន្ត្រៃយ៍ នៃ ស្មារតី របស់ ខ្លួន ឯង ផ្ទាល់។

មួយ វិញ ទៀត យើង ត្រូវ បំបាត់ ចោល នូវ ការស្រមើស្រមៃ ដែល ប្រផ្នា ថា ការគិត របស់ មនុស្ស យើង នឹង អាច ឈាន ទៅ ដល់ សង្គម នៃ ចំណេះដឹង ទាំងអស់។ តាម ការណ៍ពិត យើង គ្រាន់ តែ អាច ឈាន ទៅ ដល់ សង្គម នៃ ចំណេះដឹង ទាំងឡាយ ដាច់ ចេញ ពី គ្នា ពី មួយ ទៅ មួយ ទៀត។ ការដាច់ ចេញ នេះ ឯង ដែល នាំ ឱ្យ យើង មិន អាច ភ្ជាប់ វា បាន ដើម្បី យល់ អំពី បញ្ហា គ្រឹះ នីមួយៗ និង ទាំងអស់ នៃ ជីវិត ផ្ទាល់ ខ្លួន និង វាសនា រួម បាន នោះ ឡើយ។

ទី បញ្ចប់ យើង ត្រូវ បំបាត់ ចោល ដែរ ការស្រមើស្រមៃ ទុក ជា ការពិត ដាច់ខាត ដោយ យោង តាម ចំណេះដឹង យើង រួម ទាំង ចំណេះដឹង វិទ្យាសាស្ត្រ ដែល យើង នឹកស្មាន ថា មាន ការ រៀបចំ ប្រកប ទៅ ដោយ វិចារណាភាព (rationalité) ពេញលេញ។ ជា ការពិត វិចារណាភាព វា មាន ទម្រង់ ផ្សេងៗ គ្នា ដូច ជា : វិចារណាភាព ទិតៀន ដែល ប្រើ ការសង្ស័យ ; វិចារណាភាព ទ្រឹស្តី ដែល ស្ថាបនា ទ្រឹស្តី ទាំងឡាយ យក វា មក អនុវត្ត ជា វិធី

ជាប់លាប់ ស្រប ជា មួយ បាតុភូត ទាំងឡាយ ; វិចារណាភាព ស្វ័យទិតៀន ដែល យល់ដឹង អំពី គំរិត របស់ វា និង វិការភាគ នៃ វិចារណាភាព ទៅ ជា អវិចារណភាព (ទស្សនៈ សមហេតុ សមផល ដែល មាន នៅ ក្នុង ចិត្ត, តែ វា មិន ស្របគ្នានឹង មូលដ្ឋាន ដែល អាង លើ ការពិសោធ ណា មួយ ; ហេតុផល ឧបករណ៍ ដែល បំរើ អំពើ គ្រោះថ្នាក់, ឧក្រិដ្ឋ និង វិកលចរិត ដូច យ៉ាង ពួក ណាស៊ី យក មក អនុវត្ត នៅ ជំរំ ប្រមូល ផ្តុំ ជនជាតិ ហ្សីហ្វ និង របប ខ្មែរ ក្រហម យក ប្រទេស ធ្វើ ជា គុក សំរាប់ កែ ជា ដាច់ខាត ចិត្តគំនិត នៃ ប្រជាជនខ្មែរ)។

ដូច្នេះ ភាពខ្វាក់ គឺ អាច ទុក ជា លទ្ធផល នៃ ចំណេះដឹង ចែក ជា ភាគ និង កំចាត់កំចាយ, ដែល ជា របស់ ផ្ទាល់ នៃ ចក្ខុវិស័យ បរិមាត្រ ទោល លើ គ្រប់ របស់ ទាំងឡាយ ដែល វា ដើរ ទន្ទឹមគ្នា នឹង ភាពច្របូកច្របល់ ក្នុង សង្គម នៃ ចំណេះដឹង និង ការប្រើ គ្រប់ បែប យ៉ាង នៃ វិចារណាភាព។

បើ សិន ជា ស្មារតី យើង វា ស្ថិត នៅ ក្រោម ប្រការ មួយ តាម ការកាត់ ភាគ ខ្លះ និង អរូបិយ ដើម្បី ស្គាល់ តាម អសមត្ថភាព ក្នុង ការចាប់យក ការពិត នៅ ក្នុង ភាព មិស្ស គំនិត និង ភាព ទាំងអស់ របស់ វា, បើ សិន ជា ការគិត បែប ទស្សនវិជ្ជា បែរ ជា ងាក ចេញ ពី ពិភពលោក ហើយ មិន ប្រឈមមុខនឹង

វា ដើម្បី យល់ អំពី បញ្ហា, ដូច្នេះ, ដោយ ប្រតិមតិ[35], បញ្ហា យើង វា ធ្វើ ឱ្យ យើង ខ្វាក់ នោះ ឯង។

ពិត ណាស់ ហើយ ថា ប្រពៃណី នៃ ការគិត វា ចាក់ ឫស ជ្រៅ នៅ ក្នុង វប្បធម៌ មនុស្ស យើង និង ក្រង ជា ស្មារតី តាំង ពី នៅ សាលា កុមាដ្ឋាន ដែល ត្រូវ បាន គេ បង្រៀន យើង ឱ្យ ស្គាល់ លោកា របស់ យើង តាម « គំនិត ច្បាស់លាស់ » ; ប្រពៃណី នេះ វា រំលឹក ដាស់តឿន យើង ឱ្យ បន្ថយ ពី មិស្ស គំនិត ទៅ ជា គំនិត សាមញ្ញ, ពោល ថា បំបែក អ្វី ដែល ពាក់ព័ន្ធ, បង្រួម ទៅ ជា សាមញ្ញ, ទម្លាក់ ចោល អ្វី ដែល នាំ មក នូវ ការច្រឡំបល់ ឬ ផ្ទុយ គ្នា នៅ ក្នុង បញ្ហា។ តែ ថា បញ្ហា សំខាន់ នៅ សម័យ របស់ យើង ដែល កំពុង រស់នៅ គឺ ជា ការចាំបាច់ នៃ ការគិត ល្មម នឹង សើយឡើង នូវ បញ្ហា ប្រឈមមុខ នៃ ភាព មិស្ស គំនិត នៃ ការពិត, ពោល ថា ចាប់ យក ការប្រមូល រួមផ្លាប់, អន្តរកម្ម និង ការចូលរួម ទៅវិញ ទៅ មក, បាតុភូត ពហុ បរិមាត្រ, ភាព ពិត ទាំង សាមគ្គីភាព និង ជម្លោះ។ ការពិត ទាំងឡាយ ព្រមគ្នា នឹង សាមគ្គីភាព និង ទំនាស់ (ដូច ប្រជាធិបតី ខ្លួន ឯង, ប្រព័ន្ធ ដែល ចិញ្ចឹម បដិបក្ខ និយម ទាំងឡាយ ដោយ ធ្វើ និយ័តកម្ម[36] វា)។

[35] ប្រតិមតិ : paradoxalement.
[36] និយ័តកម្ម : alternative.

ការពិត គ្រប់ វិទ្យាសាស្ត្រ ឈានមុខ, ដូច យ៉ាង វិទ្យាសាស្ត្រ នៃ ផែនដី, បរិស្ថានវិទ្យា, លោកវិទ្យា គឺ ជា វិទ្យាសាស្ត្រ ដែល កំទេច ជាមួយ នឹង គំណ នៃ បន្ថយ និយម របស់ ការពន្យល់ តាម បែប ងាយ បំផុត : វិទ្យាសាស្ត្រ នេះ ទុក ប្រព័ន្ធ មិស្សគំនិត ក្នុង នោះ ភាគ ទាំងឡាយ និង ទាំងអស់ បង្កើត គ្នា ទៅ វិញ ទៅ មក និង រៀបចំ គ្នា ទៅ វិញ ទៅ មក, និង, នៅ ក្នុងករណី នៃ បរិស្ថានវិទ្យា, ទុក ភាព មិស្ស គំនិត លើស ពី គ្រប់ ប្រព័ន្ធ ទៅ ទៀត។

លើស ពី នេះ ទៅទៀត, គោលការណ៍ នៃ ភាព វៃឆ្លាត ទាំងឡាយ ដែល កើត រួច ហើយ, ល្មម នឹង យល់ អំពី ស្វ័យភាព, សញ្ញាណ នៃ ប្រធានបទ, មើល ឃើញ សេរីភាព, អ្វី ដែល មិន អាច ធ្វើ បាន តាម គំរូ នៃ វិទ្យាសាស្ត្រ បវេណី។ ការពិនិត្យ រិះគន់ នៃ តក្កភាព[37] (logique) នៃ គោលការណ៏ បុរាណ នៃ ភាព វៃឆ្លាត របស់ យើង វា ចាប់ ផ្តើម នៅ ពេល ជាមួយ គ្នា : វិចារណាភាព និង វិទ្យាសាស្ត្រកម្ម ត្រូវ កំណត់ ឡើងវិញ និង ធ្វើ ឱ្យ កាន់ តែ មាន មិស្ស គំនិត ដើម្បី នឹង អាច ពិនិត្រ គ្រប់ ជ្រុង នៃ បញ្ហា ដូច ខ្មែរយើង តែ និយាយ ថា « កុំ គិត ងាយ ពេក វា អាច នាំ ឱ្យ ច្រឡំ »។ មែនទែន កិច្ចការ នៃ កំណែទម្រង់ នេះ វា មិន ទាក់ទង នឹង បញ្ញវន្ត ឬ ជា មុខការ របស់ បញ្ញាជន នោះ

[37] តក្កភាព យើងប្រើក្នុងន័យពាក្យបារាំង logique។ ពាក្យ ខ្ញុំ បង្កើត ជា ការសន្មត់ ដើម្បី ចៀសវាង ប្រើ ភាសា បរទេស ដូច្នេះ សូម អក្សរវិទូ ទាំងឡាយ មេត្តា អភ័យទោស បើ ការបង្កើត នេះ វា មាន លក្ខណ: ខុស ពី ក្បួន នៃ វេយ្យាករណ៍ខ្មែរ។

ឡើយ ; តែ វា ទាក់ទង នឹង វប្បធម៌ របស់ មនុស្សយើង តែ ម្តង : អ្វី គ្រប់ យ៉ាង ដែល ត្រូវ បាន ធ្វើ ក្នុង នាម ពិចារណាកម្ម (rationalisation) ហើយ ជា ការគិត ដែល នាំ ឱ្យ ផ្ទេរ សិទ្ធិ ខ្លួន ឯង ឱ្យ អ្នក ដទៃ, សួរ ថា តើ វា មាន ពិចារណាភាព ឬទេ ? តើ វា មិនមែន ជា រឿង បន្ទាន់ ដែល បញ្ចូល ឡើងវិញ នូវ មូល ហេតុ ដែល បង្កើត សត្រូវ ដ៏ អាក្រក់ បំផុត នៅ ក្នុង គំនិត របស់ ខ្លួន ឯង ទៅវិញ ឬទេ ?

ចំណេះដឹង ត្រូវតែ ចេះ ធ្វើ បរិបទកម្ម, ធ្វើ សរុបកម្ម (globaliser), ធ្វើ ឱ្យ មាន ភាព មិស្សគំនិត។ ការគិត តែ មួយ លួម នឹង យល់ដឹង អំពី ភាព មិស្ស គំនិត វា មិន ត្រឹមតែ មាន នៅ ក្នុង ជីវិត របស់ យើង, វាសនា របស់ យើង, ការប្រាស័យ ទាក់ទង បុគ្គល/សង្គម/ប្រភេទ តែ ក៏ មាន នៅ ក្នុង គ្រហយុគ (ère planétaire) ដែល វា អាច សាកល្បង ធ្វើ រោគវិនិច្ឆ័យ លើ ដំណើរ នៃ អនាគត របស់ យើង និង កំណត់ ទម្រង់ ទាំងឡាយ ដែល មាន សារៈសំខាន់ ដើម្បី ផ្លាស់ ប្តូរ ផ្លូវ។ មាន តែ ការគិត បែប មិស្ស គំនិត ទេ ដែល អាច បំពាក់ អាវុធ ដល់ យើង ដើម្បី រៀបចំ ធ្វើ ឱ្យ មាន ការប្រែប្រួល សង្គម, បុគ្គល និង នរវិទ្យា ព្រមគ្នា។

ចំណេះដឹង ត្រូវ យល់ ដឹង អំពី ភាព ផ្ទុយ គ្នា មាន តក្កភាព ដែល យើង ត្រូវ ប្រឈរ មុខ :

- សណ្តាប់ធ្នាប់ ក៏ មាន អសណ្តាប់ធ្នាប់ (ការច្រឡំបល់) ;

- វិទ្យាសាស្ត្រ បំភ្លឺ ការល្ងង់ខ្លៅ ;
- វប្បធម៌ ក៏ មាន អនារ្យធម៌ នេះ ដែរ ;
- ហេតុផល បរិសុទ្ធ ក៏ វា អាច មិន សមហេតុផល ;
- ហេតុផល និង តណ្ហា ត្រូវ ការ គ្នា ទៅ វិញ ទៅ មក ;
- របស់ តែ មួយ ក៏ មាន អនេកគុណ ផ្ទាល់ ខ្លួន របស់ វា។

ការគិត នៃ មិស្ស គំនិត ដែល យើង បាន កំណត់ គោលការណ៍ របស់ វា វា ជួយ បណ្ដុះបណ្ដាល នូវ សម្បទា (aptitude) ក្នុង ប្រតិកម្ម តាម របៀប ជាក់ច្បាស់ នៅ ចំពោះ មុខ ស្ថានភាព ថ្មី។ ដូច ដែល គេ បាន និយាយ ថា « ការ មិនចេះ អក្សរ នៅ សតវត្ស ទី ២១ មិន មែន ជា ពួក អ្នក ដែល មិន ចេះ អាន និង សរសេរ នោះ ទេ តែ ជា ពួក អ្នក ដែល មិន អាច រៀន បាន, មិន អាច នឹង មិន រៀន បាន និង អាច នឹង រៀន ឡើងវិញ បាន »

## ចំណេះដឹងថ្មី នៃវិទ្យាសាស្ត្រ

គ្រប់ កំណែទម្រង់ នៃ ចំណេះដឹង និង ការគិត វា មិន អាច ទុក បដិវត្ត វិទ្យាសាស្ត្រ ធំ ពីរ កើត ឡើង នៅ សតវត្សរ៍ ទី២០ ដែល គេ ទុក វា ជា ការរីកចំរើន នៃ មនុស្សជាតិ ថា ជា កំណែទម្រង់ គ្រប់គ្រាន់ និង ចប់ សព្វ គ្រប់ បាន នោះឡើយ។ រហូត មក ដល់ សតវត្ស ទី ១៩ វិទ្យាសាស្ត្រ ចាក់ឫស សំណង់ របស់ ខ្លួន លើ

សសរស្តម្ភ បី : សសរ ទី ១ គឺ ជំនឿ លើ តម្លៃ របស់ វិទ្យាសាស្ត្រ នៅ ក្នុង សេចក្តី ប្តេជ្ញា ដាច់ខាត ថា ជា តម្លៃ នៃ សច្ចៈភាព ; សសរ ទី ២ គឺ លើ ការបំបែក វិជ្ជា ទាំងឡាយ ដោយ ឡែក ពី គ្នា។ អ្នក វិទ្យាសាស្ត្រ យល់ ឃើញ ថា ដើម្បី អាច ស្គាល់ វត្ថុ មួយ វា គ្រាន់ តែ បំបែក វា ឱ្យ ចេញ ពីមជ្ឈដ្ឋាន ដើម របស់ វា ដោយ យក វា ទៅ ដាក់ នៅ ទី កន្លែង សិប្បនិម្មិត ដើម្បី សំគាល់ ប្រតិកម្ម របស់ វា នៅ ទី កន្លែង នោះ។ សសរ ទី ៣ គឺ ជឿ លើ ការ ឱ្យ តម្លៃ នៃ ភស្តុតាង ដាច់ខាត ដែល ជា វិសេសានុមាន (induction) និង អនុមាន (déduction) តាម ការពិសោធ ផ្តល់ ឱ្យ។

តាម ទង្វើ បដិវត្ត វិទ្យាសាស្ត្រ លើក ទី ១ ចាប់ ផ្តើម ពី រូបសាស្ត្រ វិទ្យា តាម គោលការណ៍ ទី ២ នៃ ឧណ្ហកម្មនា[38] ហើយ បញ្ចប់ បាន សម្រេច ជា មួយ នឹង មីក្រូ រូបសាស្ត្រវិទ្យា និង លោកធាតុ រូបសាស្ត្រវិទ្យា។ ចំណែក ឯ បដិវត្ត វិទ្យាសាស្ត្រ លើក ទី ២ វិញ ទទួលបាន ជ័យជំនះ លើ សសរស្តម្ភ ទី ១ គឺ : គោលការណ៍ នៃ បច្ច័យនិយម (déterminisme) បន្ត ទៅ មុខ ត្រូវ តែ រួម ជា មួយ នឹង គោលការណ៍ នៃ មិស្សូ គំនិត ហើយ និង គោលការណ៍ នៃ ព័ន្ធភាព (relativité) ផង ដែរ។

បដិវត្ត វិទ្យាសាស្ត្រ លើក ទី ២ នេះ ឯង ដែល វា សំដែង ឡើង នៅ ពាក់ កណ្តាល សតវត្ស៍ ទី ២០, ដែល ជា ដំណើរការ នៃ អន្តរ

[38] ឧណ្ហកម្មនា : thermodynamique.

ទំនាក់ទំនង រវាង វិជ្ជា ទាំងឡាយ ដែល ពី មុន មក វា មាន ដំណើរការ ដាច់ ឡែក ពី គ្នា។ ដូចយ៉ាង វិទ្យាសាស្ត្រ នៃ ផែនដី, លោកវិទ្យា និង ជា ពិសេស បរិស្ថានវិទ្យា ដែល ត្រូវ មាន ទំនាក់ ទំនង នឹង ចំណេះដឹង រូបសាស្ត្រ, ភូមិសាស្ត្រ ឧត្តុនិយមវិទ្យា ទៅ នឹង ចំណេះដឹង ជីវវិទ្យា (ជីវវិទ្យានៃ អតិសុខុមប្រាណ, ជីវវិទ្យា នៃ សត្តវិទ្យា) ដែល វា រួម ផង ដែរ ជាមួយ ចំណេះដឹង នៃ សង្គម វិទ្យា ដ្បិត មនុស្សជាតិ ប្រែ ប្តូរ កាន់ តែ ច្រើន ទៅ រក ប្រព័ន្ធ បរិស្ថាន និង ជីវមណ្ឌល (biosphère)។

ប៉ុន្តែ ការបដិវត្តន៍ ទាំង ពីរ ទោះបី មាន បញ្ចូល នូវ មិស្ស គំនិត នៅ តែ មិន ទាន់ ចប់ សព្វ គ្រប់ ព្រោះ គេ យល់ ឃើញ ថា បដិវត្តន៍ ដែល ទុក ចំណេះ វិទ្យាសាស្ត្រ ជា វត្ថុ (épistémologie) វា មិន ទាន់ ចប់ សព្វ គ្រប់ វា គ្រាន់ តែ ជា បដិវត្តន៍ មាន ការ រៀបចំ គំនិត របស់ អ្នក ប្រាជ្ញ ធំៗ ដូច មាន គំនិត រៀបចំ ពី លោក Héraclite (« ភ្ញាក់ នៅ ពេល គេ សម្រាន្ត », « រស់ ពី ការ ស្លាប់ », « ស្លាប់ នៃ ការរស់ »), ពី លោក Pascal (ជាលិកា នៃ ភាពផ្ទុយ គ្នា ដែល ជា ជាតិ មនុស្ស), ពី លោក Hegel ( ការគិត របស់ យើង ត្រូវ ក្រសោប ភាព ផ្ទុយ គ្នា), ពី លោក Marx ( វិទ្យា សាស្ត្រ នៃ មនុស្ស ត្រូវ ក្រសោប វិទ្យាសាស្ត្រ នៃ ធម្មជាតិ)។ វិទ្យា សាស្ត្រ នេះ ចាប់ ផ្តើម ចូល ទៅ ក្នុង វិទ្យាសាស្ត្រ ទាំងឡាយ ជាមួយ នឹង ចំណេះដឹង ដែល លោក Niels Bohr យក វា មក ធ្វើ លើ តែ សញ្ញាណ នៃ ការផ្ទុយ គ្នា ពីរ យ៉ាង - រលក (onde) និង ទេហាណូ (corpuscule) - វា ត្រូវ រួម គ្នា ជា ការចាំបាច់ នៅ

ក្នុង ទស្សនៈ នៃ ធម្មជាតិ មិស្ស គំនិត នៃ ចុណ្ណភាព (particule)។ វា កើតឡើង នៅ ក្នុង រូបវិទ្យា និង លោកវិទ្យា ដើម្បី ពិចារណា អំពី សាកលលោក និង ធម្មជាតិ ដែល ជា របស់ ពិត។ វិទ្យាសាស្ត្រ នេះ វា ជា ស្នូល នៃ ការទាក់ទង លំហ-បុគ្គល-សង្គម, ជា ស្នូល នៃ ជីវវិទ្យា និង នរវិទ្យា។

សព្វ ថ្ងៃ កង្វះ នៃ ការសិក្សា ថ្មី នៃ វិទ្យាសាស្ត្រ គឺ ការបញ្ចូល នៃ ការឆ្លុះត្រឡប់កម្ម (réflexivité) ដើម្បី ចោទ សួរ ជា និច្ច នូវ ពំនិត នៃ ចំណេះដឹង នៃ វិទ្យាសាស្ត្រ។ ជា ការពិត អ្នក វិទ្យាសាស្ត្រ ក្នុង នាម ជា មនុស្ស គឺ ជា បុគ្គល-ប្រធានបទ លេច ចេញ មក ពី វប្បធម៌ ដែល ខ្លួន បាន ទទួល ឥទ្ធពល, ទោះបី អ្នក វិទ្យាសាស្ត្រ នឹកស្មាន ថា គាត់ បាន បង្កើត មធ្យោបាយ ល្អ វិសុទ្ធ និង ចម្រាញ់ ច្បាស់លាស់ ដើម្បី ស្គាល់ លោក ខាង ក្រៅ, ប៉ុន្តែ ចំពោះ ខ្លួន គាត់ វិញ គាត់ ស្ថិត នៅ ជា មនុស្ស ខ្វាក់ លើ ខ្លួន ឯង ជា និច្ច ដូច គ្នា នឹង ភាព ខ្វាក់ អំពី អនាគត នៃ វិទ្យាសាស្ត្រ ដែរ។ កង្វះ នេះ វា នឹង អាច ជា ការចាំបាច់ នាំ ឱ្យ អ្នក វិទ្យាសាស្ត្រ សព្វ ថ្ងៃ និង ជំនាន់ បន្តៗ បង្កើត នូវ វប្បធម៌ ថ្មី មួយ ដែល រួម បញ្ចូល នូវ ការងារ នៃ ទស្សនវិជ្ជា ដែល ទុក ជា វិទ្យាសាស្ត្រ នៃ មនុស្សសាស្ត្រ ដែល ជា វិទ្យាសាស្ត្រ ថ្មី មួយ នៅ ក្នុង សង្គម នៅ ក្នុង ប្រវត្តិសាស្ត្រ នៃ មនុស្សជាតិ សំរាប់ យល់ ដឹង អំពី ការ ប្រែប្រួល កើត ពី ការអភិវឌ្ឍន៍ ដ៏ អស្ចារ្យ នៃ វិទ្យាសាស្ត្រ មាន ទៅ លើ សង្គម និង ប្រវត្តិសាស្ត្រ នៃ មនុស្សជាតិ។

នៅ ទី បញ្ចប់ ការបំបែក ចេញ ពី គ្នា ដែល ត្រូវ ធ្វើ ចាំបាច់ នៅ ក្នុង សតវត្ស ដើម នៃ វិទ្យាសាស្ត្រ លោក ខាង លិច រវាង វិទ្យាសាស្ត្រ និង គុណធម៌ មិន អាច រក្សា ទៀត បាន ឡើយ យោង តាម បញ្ហា ជម្រៅ រវាង គុណធម៌ និង នយោបាយ ដែល ចោទ ឡើង ពី ការអភិវឌ្ឍន៍ សហសម័យ នៃ វិទ្យាសាស្ត្រ ទាំងឡាយ។ ករណីកិច្ច សាស្ត្រ ថ្មី នៃ វិទ្យាសាស្ត្រ តម្រូវ ឱ្យ មាន បញ្ចូល នូវ គុណធម៌ ជា ចាំបាច់ សំរាប់ រូបវិទ្យា តាំង ពី អាវុធ បរមាណូ (១៩៤៥), សំរាប់ ជីវវិទ្យា តាំង ពី ការ រកឃើញ នៃ ADN (១៩៥០), ការ ធ្វើ ឱ្យ មាន កូដ នៃ សិប្បនិម្មិត (១៩៧៣), ការបង្កើត គំនិត រវើរវាយ (១៩៧៤), ទារក នៅ ក្នុង កែវ បំពង់ (១៩៧៨), ក្លូនកម្ម និង រៀបចំ កោសិកា ដើម។

លើ ការទំនាក់ទំនង នៃ កំណែទម្រង់ មនុស្សសាស្ត្រ យើង បាន បង្ហាញ គោលការណ៍ ទាំងឡាយ ដែល អនុញ្ញាត ស្វ័យពិនិត្យ របស់ អ្នក ស្រាវជ្រាវ, ការយល់ដឹង ថា មនុស្ស ដែល ជា វត្ថុធាតុ នៃ ការស្រាវជ្រាវ មិន មែន ជា មនុស្ស មាន វប្បធម៌ ឆ្លាត តែ ជា ជន រៀបបំរុង ការចេះដឹង របស់ ខ្លួន ផ្ទាល់ ; ជា ជន អាច ធ្វើ ការ លើ ការពិត និង កិច្ចការ មិស្ស គំនិត ផង ដែរ, និង បង្ហាញ វិធីសាស្ត្រ ដែល ត្រូវ ធ្វើ ដើម្បី ពិនិត្យ ព្រឹត្តិការណ៍ និង ព័ត៌មាន ឱ្យ យល់ ដឹង ច្បាស់លាស់ នៅ លើ ពិភពលោក សព្វថ្ងៃ ដែល ជា លោក មួយ ប្រកប ដោយ ការ ស្មុញស្មាញ ជា ទី បំផុត។

# ចិត្តគំនិតខ្មែរ

សព លោក បុណ្ណ ចន្ទម៉ុល កាល នៅ មាន ជីវិត លោក បាន សរសេរ សៀវភៅ[39] ក្នុង នោះ លោក បាន ធ្វើ ការ វិភាគ ទៅ លើ ចរិត ខ្មែរ ហើយ ស្នើ សុំ ឱ្យ ខ្មែរ កែ ចរិត អវិជ្ជមាន របស់ ខ្លួន ដើម្បី ចៀសវាង អំពើ អកុសល គ្រប់ បែប យ៉ាង និង ដើម្បី កសាង សង្គម ដ៏ ប្រសើរ មួយ ដែល ជា ការ ចាំបាច់ សំរាប់ ការ រស់រាន មាន ជីវិត របស់ ប្រជាជាតិ ខ្មែរ លើ មាគ៌ា នៃ វឌ្ឍន ភាព និង សុភមង្គល។

លោក ស្រី Marie Alexandre Martin , ស្ត្រី បារាំងសែស ម្នាក់ ជា ជម្មជាតិវិទូ និង ជាតិពិន្ទុវិទូ, គាត់ ធ្លាប់ បាន រស់ នៅ ស្រុក ខ្មែរ មួយ រយៈកាល, បាន សរសេរ សៀវភៅ បោះ ផ្សាយ នៅ ប្រទេស បារាំង នៅ ឆ្នាំ ១៩៨៩ ស្តី អំពី « អកុសល ខ្មែរ »។ សៀវភៅ នេះ ជា ផលា នៃ ដំណើរ សិក្សា របស់ លោក ស្រី នៅ ទស្សវត្សរ៍ ៦០  នៅ ស្រុកខ្មែរ និង សម្ភាសន៍ នៅ ទស្សវត្សរ៍ ៧០ ជា មួយ បញ្ញាវន្ត ខ្មែរ មួយ ចំនួន រស់ នៅ ស្រុក បារាំង។ នៅ ទី នេះ

[39] បុណ្ណ ចន្ទម៉ុល ជា ប្រធានពុទ្ធិសមាគមមជ្ឈមណ្ឌលសាធារណរដ្ឋខ្មែរ, តំណាងរាស្ត្រ មណ្ឌលភ្នំពេញ, ប្រធានគណៈកម្មការវប្បធម៌ និង ធម្មការនៃសភាជាតិ: ចរិតខ្មែរ បោះពុម្ពផ្សាយនៅឆ្នាំ ១៩៧៣។ លោក ក៏បាន សរសេរសៀវភៅមួយក្បាលទៀត ដែរមានចំណងជើងថា គុកនយោបាយ ក្នុងនោះលោក រៀបរាប់អំពីជីវិតលោក និង ភិក្ខុ ហៀម ជាវ នៅក្នុងគុកកោះត្រឡាច នៅសម័យអាណានិគមបារាំងសែស។

យើង លើក យក ផ្នែក មួយ នៅ ក្នុងសៀភៅ មាន ចំណង ជើង ថា « សិក្សា ខ្មែរ » ក្នុង នោះ លោក ស្រី ដកស្រង់ យក គំនិត របស់ បុគ្គល មួយ ក្រុម មាន ខ្មែរ និង បរទេស ដែល លោក ស្រី បាន ធ្វើ សម្ភាសន៍ ឬ បាន អាន អត្ថបទ ឬ សៀវភៅ របស់ អ្នក ទាំង នោះ ដូច មាន លោក សម សុខ (សម្ភាសន៍) និង ខ្មែរ ផ្សេង ទៀត, វេជ្ជបណ្ឌិត Pannetier និង A. Pavie[40]។ គោល បំណង ចម្បង របស់ លោក ស្រី គឺ វិភាគ លើ ចិត្តគំនិត ខ្មែរ មួយ ចំនួន ដែល គាត់ ទុក ជា អកុសល ដល់ ប្រជាជាតិ ខ្មែរ។ តើ សៀវភៅ របស់ លោក បុណ្ណ ចន្ទម៉ុល និង លោក ស្រី Marie Alexandre Martin វា ជា ការ មើលឃើញ គ្រប់គ្រាន់ សំរាប់ យល់ ដឹង អំពី ចិត្តគំនិត ខ្មែរ ដែរ ឬទេ ?

នៅ សម័យ ប្រជាជាតិ ខ្មែរ មាន វិបុលភាព ជា មហា នគរ ក្នុង ដំបន់ អាស៊ី, ស្រុក ខ្មែរ នាកាល នោះ មាន អារ្យធម៌ និង វប្បធម៌ ខ្ពង់ខ្ពស់ ដែល មាន ស្នាម រូបបី ជា ភស្តុតាង គឺ ប្រាង្គ ប្រាសាទ ជា ច្រើន ដែល រំលេច ចេញ នូវ រស្មី ត្រចេះត្រចង់ នៃ ចំណេះដឹង នៃ បុព្វបុរស ខ្មែរ ដែល គ្មាន នរណា អាច លុប ចោល បាន។ វប្បធម៌ នោះ មាន ឈ្មោះ ល្បីល្បាញ នៅ លើ ពិភពលោក ទោះបី គេ ទុក ជា វប្បធម៌ បាន ទទួលឥទ្ធិពល ពី វប្បធម៌ ឥណ្ឌា តែ បុព្វបុរស ខ្មែរ ជា អ្នក ប្រាជ្ញ បាន យក មក ឆ្នៃ ប្រឌិត នៅ ក្នុង ស្មារតី ខ្មែរ អោយ ក្លាយ ជា វប្បធម៌ ដ៏ ពិសេស។ ស្នាដៃ

40 សៀវភៅទសងពីរនេះ សរសេរនៅសម័យអណាព្យាបាលបារាំងសែស។

ប្រកប ដោយ បញ្ញា នេះ បង្ហាញ អោយ យើង អំពី ភាព វៃឆ្លាត មុត ស្រួច របស់ បុព្វបុរស ខ្មែរ ដែល ជា ស្ថាបត្យករ កសាង មហា នគរ ខ្មែរ។ តែ គ្រប់ វប្បធម៌ ត្រូវ ចាំបាច់ មាន ការវិវត្តន៍ ដើម្បី ឆ្លើយ តប នឹង សេចក្តីត្រូវការ របស់ សង្គម ក្នុង ចរភាព ជា ចិរ កាល។ ការ ប៉ះទង្គិច គ្នា រវាង វប្បធម៌ និង វប្បធម៌ នៅ លើ ពិភពលោក ផ្តល់ នូវ ទស្សន វិស័យ ថ្មី ដល់ មនុស្សជាតិ នៅ ក្នុង ដំណើរ ឈាន ទៅ រក ការ រីកចំរើន គ្រប់ វិស័យ។ កង្វះ របស់ អ្វី នៅ ក្នុង វប្បធម៌ មួយ ត្រូវ បាន បំពេញ បន្ថែម ដោយ ធម្មជាតិ តាម ការ ហូរ ចូល នៃ វប្បធម៌ មួយ ទៀត។ តែ ការ ប៉ះទង្គិច នាំ អោយ មាន ការ លាយ នៃ វប្បធម៌ ជា វិជ្ជមាន តែ ក៏ អាច ជា ការ ទទួល យក ជា អវិជ្ជមាន និង ជា អំពើ ឃាតកម្ម របស់ អ្នក ខ្លាំង ទៅ លើ អ្នក ខ្សោយ នោះ ដែរ។ តែ វប្បធម៌ បិទ ជិត នៅ ក្នុង សហគមន៍ ឬ សង្គម មួយ គ្មាន ការ វិវត្តន៍ សោះ ក៏ វា អាច នឹង ស្លាប់ ជា ធម្មជាតិ ដោយ ខ្លួន ឯង ផង ដែរ។

សួរ ថា តើ ចិត្តគំនិត ខ្មែរ តាំង ពី សម័យ ស្រុកខ្មែរ រុងរឿង មក ដល់ សព្វ ថ្ងៃ មាន ការ វិវត្តន៍ បន្តៗ គ្នា គ្មាន ដាច់ ឬ ក៏ មាន ការ កាត់ផ្តាច់ ពី ដំណាក់ការ មួយ ទៅ ដំណាក់ការ មួយ ទៀត គ្មាន មាន ខ្សែ តំណ ត ផ្ទាប់ គ្នា ដែល នាំ មិន អាច ឱ្យ មើល ឃើញ ចំណង នៃ ចិត្តគំនិត ខ្មែរ ទាំងមូល ? តើ ចិត្តគំនិត របស់ ខ្មែរ រស់ នៅ ប្រទេស ថៃ និង កម្ពុជាក្រោម ក្នុង ប្រទេស យៀកណាម ច្រើន ជំនាន់ មក ហើយ ហើយ ក្លាយ ទៅ ជា ប្រជា

ជន របស់ គេ និយាយ ភាសា របស់ គេ នៅ មាន ចិត្តគំនិត ដូច ខ្មែរ រស់ នៅ ក្នុង ទឹក ដី ខ្មែរ បច្ចុប្បន្ន ដែរ ឬ ទេ ?

## មូលដ្ឋានគ្រឹះ នៃជាតិខ្មែរ

### ប្រពៃណី

ខ្មែរ តែង តែ យក វត្ថុធាតុ បី យ៉ាង ទុក ជា គ្រឹះ នៃ ប្រជាជាតិ ខ្លួន គឺ: ប្រពៃណី, ភាសា និង ពុទ្ធ សាសនា។ កត្តា ទាំង បី នេះ ខ្មែរ ទុក ជា អាវុធ សំរាប់ បង្ហាញ អត្តភាព នៃ ប្រជាជាតិ របស់ ខ្លួន។ គ្រប់ ទី កន្លែង ដែល មាន ខ្មែរ រស់ នៅ និង ទៅ រស់ នៅ ខ្មែរ តែង តែ រក្សា ប្រពៃណី ខ្លួន ជា និច្ច ដូច យ៉ាង នៅ ក្នុង ពិធី ធ្វើបុណ្យ ទាំងឡាយ, អាពាហ៍ពិពាហ៍ ទោះ បី នៅ ក្នុង សម្ពន្ធ ជា មួយ ជន បរទេស ក៏ ដោយ។ សញ្ញា ដែល អាច មើល ឃើញ ជាក់ស្តែង នៃ ប្រពៃណី ខ្មែរ គឺ សំលៀកបំពាក់ ជា ពិសេស សំលៀក បំពាក់ របស់ ស្ត្រី ខ្មែរ ដែល អាច ឱ្យ ស្គាល់ ភ្លាម ថា ជា ជន ខ្មែរ ដែល ខ្លួន ខំ ថែ រក្សា នៅ ក្នុង គ្រប់ ពិធី បុណ្យ ប្រពៃណី។ ប្រពៃណី នេះ ឯង ដែល ជា កត្តា នៃ ការ បង្រួបបង្រួម ខ្មែរ នៅ ក្នុង ស្មារតី រួម មួយ គឺ ស្មារតី **អភិរក្ស និយម**។ ការ រស់ នៅ របស់ ខ្មែរ គឺ នៅ ក្រោម ច្បាប់ ប្រពៃណី ដូច យ៉ាង ច្បាប់ ស្រី, ច្បាប់ ប្រុស, ច្បាប់ កូនចៅ ។ល។ ហើយ ការរស់នៅ ណា ដែល ឃ្លាត ចេញ ពី ផ្លូវ ច្បាប់ នោះ ខ្មែរ តែង ទុក អ្នក ដែល បាន

ប្រព្រឹត្ត អំពើ ខុស ឆ្គង នោះ ជា ជន វង្វេង បឹង ឬ ជន ពាល តែ
ម្ដង។ ស្មារតី អភិរក្ស និយម ជា ផ្នត់ គំនិត តឹងរ៉ឹង របស់ ខ្មែរ
ដែល ត្រូវ តែ មាន ជា ចាំបាច់ នៅ ក្នុង ការរស់នៅ របស់ គ្រួសារ
ខ្មែរ គឺ កូន ត្រូវ តែ កោត គោរព មាតា បិតា, ប្អូន ត្រូវ តែ កោត
គោរព បង។ ដូច្នេះ សង្គម ខ្មែរ ជា **សង្គម ឋានានុក្រម** មាន ស
ណ្ដាប់ធ្នាប់ តាម ថ្នាក់ អាយុ ពី ចាស់ ទៅ ក្មេង ដូច ជា : តា
យាយ, ពុក ម៉ែ មា មីង, បង ប្អូន និង ចៅ[41]។ ខុស ពី លទ្ធិ
សាសនា ហិណ្ឌូ ដែល បែង ចែក សង្គម ជា វណ្ណៈ [42] ដែល វរៈ ជន
ខ្មែរ នៅ សម័យ ព្រហ្មញ្ញ សាសនា យក មក ធ្វើ ជា លទ្ធិ ដឹកនាំ
ហើយ បង្ខំ ឱ្យ ប្រជានុរាស្ត្រ ខ្មែរ ទទួល ស្គាល់ ដាច់ខាត វណ្ណៈ ពីរ
គឺ ក្សត្រិយៈ និង ព្រាហ្មណៈ ជា វណ្ណៈ ដឹកនាំ គំណ វង្ស និង ពូជ,
មួយ ជា វណ្ណៈ ដឹកនាំ នយោបាយ, មួយ ទៀត ជា វណ្ណៈ ដឹកនាំ សា
សនា។ ប៉ុន្តែ ស្ដេច ស្ថាបនិក នៃ រាជានិយម ហិណ្ឌូ និយម នៅ
ស្រុកខ្មែរ គឺ ព្រះបាទ ហ៊ុន ទៀន ទ្រង់ មិន បាន បង្ខំ ឱ្យ ប្រជានុ
រាស្ត្រ ខ្មែរ ប្ដូរ ជំនឿ ដើម របស់ ខ្លួន នោះ ឡើយ ដែល នាំ ឱ្យ គ្មាន
ការបង្កើត ដាច់ខាត វណ្ណៈ វៃស្សៈ និង សូទ្រៈ នៅ ក្នុង សង្គម ខ្មែ
រ។ ដូច្នេះ នៅ ក្រោម វណ្ណៈ ដឹកនាំ គឺ មាន តែ វណ្ណៈតែ មួយ គឺ
ប្រជានុរាស្ត្រ ដែល ព្រះមហាក្សត្រ ទ្រង់ ហៅ ថា ចៅ ជា រាស្ត្រ
(sujet) ស្ថិត នៅ ក្រោម អំណាច របស់ ព្រះអង្គ ជា ព្រះចៅ ដែល

41 ពាក្យ « ចៅ » មានអត្ថន័យច្រើនយ៉ាង : អ្នក, នាយ ; ម្ចាស់ ; យសរបស់អាណាប្រជានុរាស្ត្រដែលឥតបណ្ដាស័ក្តិ ; កូនរបស់កូន។ អាតីតកាល ស្ដេច មានបន្ទូលទៅកាន់ប្រជានុរាស្ត្រថា ដោយហៅថា ចៅ។

42 ក្សត្រិយៈ, ព្រាហ្មណៈ, វៃស្សៈ, សូទ្រៈ។

ជា ម្ចាស់ ដាច់ មុខ របស់ រាស្ត្រ។ ទស្សនៈ នៃ រាជាធិបតេយ្យ និយម បែប នេះ វា មិន រំខាន លើ ចិត្តគំនិត ខ្មែរ នោះឡើយ ផ្ទុយ ទៅវិញ វា សម្រប ខ្លួន បាន ល្អ ទៅ វិញ ព្រោះ នៅ ក្នុង ចិត្ត គំនិត ទុក គ្រួសារ ជា ក្រុមឋានានុក្រម ដែលមាន មាតា បិតា ជា ម្ចាស់ ដាច់ មុខ នៃ គ្រួសារ។ ដូច្នេះ ព្រះមហាក្សត្រ ជា ម្ចាស់ ដាច់មុខ របស់ប្រជានុរាស្ត្រ វា គ្រាន់ តែ ជា ការ ទុក ប្រទេស ជា មហា គ្រួសារ តែ ប៉ុណ្ណោះឯ ង ដែល មាន ព្រះ ចៅ ជា ម្ចាស់ របស់ ប្រទេស និង ប្រជានុរាស្ត្រ។ ព្រោះ ថា រាស្ត្រ គ្មាន ចោទ ជា សំនួរ អ្វី ស្តីពី អត្តភាព ពេញសិទ្ធិ នៃ ព្រះមហាក្សត្រ ជា ម្ចាស់ លើ ខ្លួន នោះឡើយ ក្រៅ តែ ពី ទុក ព្រះអង្គ ជា បិតា ជា ធម្មជាតិ របស់ ខ្លួន តែ ប៉ុណ្ណោះ ព្រោះ អត្តភាព នៃ របប រាជានិយម, ខ្មែរ ទុក ជា វត្ថុធាតុ ចម្បង របស់ ប្រពៃណី ខ្មែរ ហើយ វា ធ្វើ បូរណកម្ម ដោយ ធម្មជាតិ ទៅ ក្នុង ជាតិ ខ្មែរ។ ដូច្នេះ សញ្ញាណ នៃ ជាតិ ខ្មែរ គឺ ជា ប្រជានុរាស្ត្រ ខ្មែរ គោរព ដាច់ខាត ប្រពៃណី របស់ ខ្លួន ដែល មាន ព្រះមហាក្សត្រ ជា ម្ចាស់ ហៅ ថា ព្រះ ចៅ ឬ ម្ចាស់ នៃ ក្រុងកម្ពុជា។

## ភាសា និង អក្សរ

ខេមរៈ ភាសា, ខ្មែរ ទុក ជា គ្រឹះ របស់ ជាតិ សាសន៍ ខ្មែរ។ ភាសា នេះ ឯង ដែល បញ្ចេញ ចិត្តគំនិត តាម សំនៀង។ វា ជា មធ្យោបាយ នៃ ការ ទំនាក់ទំនង គ្នា រវាង បុគ្គល និង បុគ្គល នៅ ក្នុង សង្គម។ ដូច្នេះ គេ អាច ឆ្លុះ មើល សង្គម នីមួយៗ បាន តាម ភាសា។ ជា ថ្មី ម្តង ទៀត ភាសា ខ្មែរ បញ្ជាក់ បង្ហាញ អំពី

រចនាសម្ព័ន្ធ បញ្ឈរ របស់ សង្គម ខ្មែរ ព្រោះ នៅ ក្នុង ភាសា ខ្មែរ វា មាន ឋានានុក្រម នៃ ពាក្យ សំដី ពី ក្រោម ទៅ លើ ផង ពី លើ មក ក្រោម ផង និង ក្នុង មជ្ឈដ្ឋាន នីមួយៗ ផង។ ដូច ជា មាន ភាសា សំរាប់ រាជវង្សានុវង្ស, ភិក្ខាវោ, មន្ត្រី សេនាធិបតី និង ប្រជានុរាស្ត្រ។ ពី ក្រោម ទៅ លើ គឺ ថា អ្នក នៅ ក្នុង មជ្ឈដ្ឋាន ទាប បើ ចង់ និយាយ ស្ដី ទៅ រក អ្នក នៅ ក្នុង មជ្ឈដ្ឋាន ខ្ពស់ ត្រូវ តែ ចេះ ពាក្យ សំដី របស់ អ្នក ធំ ឬ លោក ពុំ នោះ សោធ គេ ទុក ជា មនុស្ស ល្ងើយ ឬ អត់ ពូជ ហើយ វា ប្រហែល ជា អាច ទុក ជា ការ ប្រមាថ ព្រះ ចេស្ដា បើ សិន ជា រាស្ត្រ និយាយ ទៅ កាន់ ស្ដេច ដោយ មិន បាន ប្រើ រាជ ភាសា។ អ្នក ដែល ចេះ និយាយ គួរ ដល់ ប្រមាណ ឬ ចេះ និយាយ ស្ដី ល្អ, ខ្មែរ យើង ហៅ ថា មិតភាណី។ តែ ជញ្ជាំង ខាន់ នៃ ភាសា ពី មជ្ឈដ្ឋាន មួយ ទៅ មួយ ទៀត វា មិន បិទ ជិត ស្លុង នោះ ឡើយ ព្រោះ មាន ខន្តី ច្រើន នៅ ក្នុង សង្គម ខ្មែរ ចាប់ ពី សម័យ ពុទ្ធ សាសនា មក។ ត្រូវ ដឹង ថា នៅ សម័យ ដើម យុវជន ខ្មែរ ចេះ រាជ ភាសា ព្រោះ ធ្លាប់ បាន បួស រៀន សូត្រ ពុទ្ធ ធម៌ ហើយ នៅ ក្នុង ធម៌ នោះ មាន ប្រើ រាជ ភាសា ច្រើន ណាស់ ព្រោះ ព្រះសម្មាសម្ពុទ្ធ ជា ម្ចាស់ ព្រះអង្គ មាន ដើម កំណើត នៅ ក្នុង វណ្ណៈ ក្សត្រិយ:។ ចំណុច នេះ ឯង ទុក បាន ថា ជា ចម្លើយ នឹង សំនួរ ថា បើ រាជ ភាសា មិន បាន យក មក បង្រៀន នៅ ក្នុង សាលារៀន ចុះ ហេតុ អ្វី បាន ជា ជនខ្មែរ ភាគ ច្រើន ចេះ ភាសា នេះ ? ចេះ រាជ ភាសា ព្រោះ ខ្មែរ ជា អ្នក កាន់ព្រះពុទ្ធ សាសនា នោះ ឯង។ ត្រូវ ដឹង ដែរ ថា

ភាសា ខ្មែរ មាន ប្រភព ចេញ ពី ភាសា បាលី និង សំស្ក្រឹត មួយ ចំនួន ច្រើន ដែល ជា ពុទ្ធ សាសនា ភាសា។ ភាសា នេះ ឯង ដែល អ្នក ប្រាជ្ញ អក្សរសាស្ត្រ ខ្មែរ ពី ជំនាន់ មួយ ទៅ ជំនាន់ មួយ ទៀត យក មក ឆ្នៃ ប្រឌិត នៅ ក្នុង ស្មារតី ធ្វើ ខេមរៈយាន កម្ម ដើម្បី យក មក ប្រើ ជា ភាសា បញ្ញា[43] បែក ចេញ ពី ភាសា សាសនា ដែល ខ្មែរ ប្រើ រហូត មក ដល់ សព្វ ថ្ងៃ នេះ នៅ ក្នុង មជ្ឈដ្ឋាន អ្នក ចេះ ដឹង។ ដូច្នេះ ខេមរៈ ភាសា មិន មែន ជា ភាសា ស្លាប់ និង និច្ចល នោះ ឡើយ តែ ជា ភាសា ប្រាជ្ញា[44] រស់ រវើក ហើយ មាន ការវិវត្តន៍ ជា និច្ច នៅ តាម ពេល វេលា នៃ ពិភពលោក និង មនុស្សជាតិ[45]។

ជាតិ សាសន៍ ខ្មែរ មិន ត្រឹម តែ មាន ភាសា តែ ក៏ មាន អក្សរ សំរាប់ សរសេរ ផ្សាយ គំនិត និង កត់ទុក ចិត្តគំនិត, ប្រវត្តិសាស្ត្រ និង វិជ្ជា គ្រប់ បែប យ៉ាង សំរាប់ ខ្មែរ ជំនាន់ ក្រោយ។ អក្សរ នេះឯង ជា ភស្តុតាង នៃ អត្តភាព នៃ បុរាណកាល ជា នគរ

43 ភាសាបញ្ញា : langue intellectuelle.

44 ភាសាប្រាជ្ញា : langage savant. ពាក្យ ប្រាជ្ញា ប្រើជាគុណនាម។

45 សុំរកអានសៀវភៅ មានចំណងជើងថា «ភាសាខ្មែរ» និពន្ធដោយ លោក អៀវ កើស បោះពុម្ពផ្សាយឡើងវិញរបស់ពុទ្ធសាសនបណ្ឌិត្យ នៅ ព.ស. ២៥៣៩ (គ.ស. ១៩៩៥)។ លោក អៀវ កើស (១៩០៥-១៩៥០) ជា នយៈជន (អ្នកនយោបាយ) ដ៏ល្បីម្នាក់នៅសតវត្សទី២០ នៅក្នុងសម័យផ្ដើមឯករាជ្យជាតិ ដែលត្រូវគេសម្លាប់នៅឆ្នាំ ១៩៤៩ ជាឃាតកម្មនយោបាយ ព្រោះលោក ជាសមាជិកស្ថាបនិក នៃគណបក្សប្រជាធិបតេយ្យ ដែលជាគណបក្សឈ្នះឆ្នោត បានទទួលបានអាសនៈភាគច្រើនដាច់ខាត នៅក្នុងសភាធម្មនុញ្ញនៅឆ្នាំ ១៩៤៦ ហើយត្រូវជាប់ឆ្នោតជាប្រធានសភានោះ ពីឆ្នាំ ១៩៤៧ ដល់ ឆ្នាំ ១៩៤៩។

ខ្មែរ រុងរឿង ដូចយ៉ាង អត្ថភាព នៃ មហាប្រាសាទ នានា ផង ដែរ។ ដោយសារ អក្សរ នេះឯង ដែល បុព្វបុរស ខ្មែរ ចារ លើ សិលា ជា អត្ថបទ ខ្លីៗ ជាប់ ទាក់ទង និង កំណើត ប្រាសាទ និង ទេវរាជ ដើម្បី បំភ្លឺ ការស្រាវជ្រាវ លើ បុរាណវិជ្ជា ហើយ និង អត្ថបទ អក្សរសាស្រ្ត ឯទៀតៗ ដែល មាន ច្រើន ឥតគណនា ដែល ជា ដំណាង ចំណេះ ចេះ ដឹង មួយ ចំនួន ធំ នៃ ប្រជាជាតិ ខ្មែរ។ ការសិក្សា ស្រាវជ្រាវ លើ តែ បុរាណវិជ្ជា ខ្មែរ វា មិន គ្រប់ មុម ដើម្បី ឱ្យ ស្គាល់ យល់ វប្បធម៌ និង អារ្យធម៌ ខ្មែរ បាន នោះ ឡើយ បើ គ្មាន ការសិក្សា បន្ថែម លើ អក្សរសាស្រ្ត ខ្មែរ។ ដូច្នេះ ឯង ក្រោយ ពី ស្រុកខ្មែរ ទទួល បាន ឯករាជ្យ ពី បារាំង មាន ការ ស្រាវជ្រាវ លើ អត្ថបទ អក្សរសាស្រ្ត ជា ច្រើន ដែល នាំ ឱ្យ មាន សន្ទុះ និង ដង្ហើម ឡើង វិញ ដល់ តម្លៃ នៃ អក្សរសាស្រ្ត ជាតិ នៅ ក្នុង វប្បធម៌ ខ្មែរ។ ដូច សព លោក កេង វ៉ាន់សាក់ បាន សរសេរ នៅ ក្នុង អត្ថបទ នៃ ការសិក្សា[46] លើ អក្សរសាស្រ្ត ខ្មែរ ថា វា មាន លក្ខណៈ សំខាន់ អាច អោយ យល់ ដឹង ច្បាស់ ពិត ប្រាកដ អំពី តួ នាទី  នៃ អក្សរសាស្រ្ត នៅ ក្នុង សង្គម ខ្មែរ និង អាច បំភ្លឺ អោយ ឃើញ ថា អ្វី ជា ចិត្តគំនិត របស់ ខ្មែរ។

[46] ការសិក្សា របស់ សព លោក កេង វ៉ាន់សាក់ គាត់ សរសេរ ជា ភាសា បារាំង ដែល ខ្ញុំ ធ្លាប់ យក មក ប្រែ ជា ភាសា បារាំង ចុះ ផ្សាយ នៅ ក្នុង ប្លុក របស់ ខ្ញុំ នៅ ថ្ងៃ ទី ១៤ តុលា ឆ្នាំ ២០១៧។

អក្សរ ខ្មែរ ជា ការ ប្រឌិដ្ឋ ប្រាជ្ញា ដែល ជា ស្នាដៃ ដ៏ ឆ្នើម របស់ អ្នក ប្រាជ្ញ អក្សរសាស្ត្រ ខ្មែរ នៅ សម័យ បុរាណ និង បន្ត បន្ទាប់ មក។

ទាំង ភសា និង អក្សរសិល្ប៍, ភាសាវិទូ បាន ចែក ចង្កោម អក្សរ សិល្ប៍ តាម ការ វិវត្តន៍ នៃ ភាសា និង នរសាស្ត្រ ជា បី តំណាក់ កាល :

សម័យ បុរាណ ហៅ ថា ខ្មែរ បុរាណ ឬ ខ្មែរ ចាស់ គឺ ជា ភាសា ខ្មែរ ដែល បុព្វបុរស ខ្មែរ បាន ធ្វើ ចំណារ លើ ផ្ទាំង ថ្មដា ពាសពេញ លើ អាណាចក្រ ខ្មែរ ប្រសិទ្ធិនាម ហៅថា « សិលាចារឹក »។ ភាសា បុរាណ គឺ រាប់ ពី សតវត្ស ទី ៧ សល់ សតវត្ស ទី ១៤។

សម័យ កណ្តាល ឬ សម័យ « ភាសាខ្មែរ កណ្តាល » គឺ ជា ភាសា ខ្មែរ ដែល យើង ឃើញ លើ សិលាចារឹក ខ្លះៗ និង នៅ លើ សាស្ត្រា ស្លឹករឹត ក្រាំង គម្ពីរ ក្បួន ច្បាប់ ផ្សេងៗ ក្នុង កំឡុង សតវត្ស ទី ១៩។

សម័យ បច្ចុប្បន្នកាល គឺ ជា ភាសា សម័យ នៃ ភាសា ខ្មែរ ទំនើប ឬ ខ្មែរ ថ្មី គឺ ភាសា ដែល ខ្មែរ និយាយ សរសេរ ប្រើ ការ រហូត មក ដល់ សព្វ ថ្ងៃ នេះ ឯង គឺ តាំង ពី កណ្តាល សតវត្ស ទី ១៩ ដល់ ទី ២១ នេះ[47]។

[47] ឃិន ហុកឌី : ទិដ្ឋភាព ទូទៅ នៃ អក្សរសាស្ត្រខ្មែរ - Edition L'Harmattan.

សព្វថ្ងៃ នេះ ជាមួយ នឹង ជំនឿន នៃ ឧបករណ៍ ទំនើប សំរាប់ សរសេរ អក្សរ ខ្មែរ នាំ ឱ្យ មាន សន្ទុះ ខ្លាំង ក្នុង ការផ្សាយ គំនិត ដោយ ប្រើ អក្សរ ខ្មែរ នៅ ក្នុង ប្រព័ន្ធ អ៊ិនធឺណិត។ ការផ្សាយ នៅ ក្នុង បណ្ដាញ សង្គម ជា ខេមរភាសា តម្រូវ ឱ្យ បង្កើត ពាក្យ បច្ចេកទេស, វិទ្យាសាស្ត្រ, ទស្សនវិជ្ជា និង សង្គមវិជ្ជា ជា ច្រើន ដើម្បី ងាយ ស្រួល ប្រាស្រ័យទាក់ទង គំនិត ហើយ បំបាន ភាសា ខ្មែរ ឱ្យ ក្លាយ ជា ភាសា មាន លទ្ធភាព គ្រប់គ្រាន់ ដើម្បី សំដែង ចិត្តគំនិត ខ្ពង់ខ្ពស់ បំផុត។ ការផ្សាយ នេះ ជា ការជួយ បំពេញ កង្វះខាត នៃ បណ្ណាល័យ នៅ ស្រុកខ្មែរ។ ការងារ សំខាន់ មួយ សំរាប់ ពួក អក្សរសាស្ត្រវិទូ ខ្មែរ គឺ ធ្វើ ចរន្តការ នៃ វចនានុក្រម ខ្មែរ របស់ ពុទ្ធសាសនបណ្ឌិត្យ[48] ដែល ជា វចនានុក្រម ជា ផ្លូវ ការ របស់ ជាតិខ្មែរ។

## ពុទ្ធសាសនា

ប្រវត្តិវិទូ ទាំងឡាយ តែង សរសេរ ថា អារ្យធម៌ ខ្មែរ មាន សាសនា ជា មូលដ្ឋាន ច្បង។ ការ អះអាង នេះ វា មិន អាច ប្រកែង បាន បើ គេ ធ្លាប់ បាន ទស្សនា ប្រាង្គ ប្រាសាទ ដែល មាន ទិដ្ឋភាព ជា ទី សក្ការៈ នៃ ព្រះអាទិទេព។ នៅ ទី នោះ វា ហាក់ បី ដូច ជា មាន ការ រួបរួម រវាង ការ រស់នៅ របស់ ខ្មែរ ជា

[48] វចនានុក្រមខ្មែរៈ បោះពុម្ព ហើយ ផ្សាយ នៅ ឆ្នាំ ១៩៦៧ ត្រូវ នឹង ព.ស. ២៥១១។

មួយ នឹង ជំនឿ សាសនា និង ការ រៀបចំ សង្គម មួយ ដែល ជា ការ បន្ត នៃ ជីវិត សម្ភារៈ ទៅ ក្នុង ជីវិត គំនិត, ដូច អ្នកប្រាជ្ញ និយាយ ថា វា ជា ការ មិន អាច គិត បាន ថា មាន អង្គរវត្ត តែ គ្មាន វាល ស្រែ ហើយ មាន វាល ស្រែ តែ គ្មាន អង្គរវត្ត។ ដូច្នេះ សម្ពន្ធ នេះ មិន អាច ញែក ដាច់ ពី គ្នា ដែល ជា ការផ្សំ ជា អារ្យធម៌ ខ្មែរ។ ពី ព្រហ្មញ្ញ សាសនា ដែល សព្វ ថ្ងៃ នៅ មាន អត្ថភាព នៅ តែ ក្នុង ព្រះបរមរាជវាំង, នៅ លើ ផ្ទើ មាន ចំនួន តិចតួច ក្នុង បណ្ណាល័យ នានា, តាម វិចិត្រសាល នៃ រូប ចំលាក់ ក្នុង ប្រាសាទ ទាំងឡាយ និង ក្នុង សៀវភៅ នៃ បដិមាសាស្ត្រ, មក ដល់ ពុទ្ធ សាសនា ដែល មាន អត្ថភាព រស់ រវើង នៅ ក្នុង ការ រស់នៅ របស់ ខ្មែរ សព្វ ថ្ងៃ, តែ គេ នៅ ឃើញ មាន ការលាយ គ្នា នៅ ឡើយ ដែរ ក្នុង ជំនឿ របស់ ខ្មែរ រវាង ពុទ្ធ សាសនា ព្រហ្មញ្ញ សាសនា និង ជំនឿ លើ ធម្មជាតិ។ ដូច មាន ប្រវត្តិវិទូ ខ្លះ គេ និយាយ និង សរសេរ ថា : ព្រះ អាទិទេព នៃ ព្រហ្មញ្ញ សាសនា លោក មាន កិច្ច រវល់ ច្រើន ណាស់ នៅ ក្នុង ព្រះ បរមរាជវាំង, តែ អ្វី ដែល ខ្មែរ ទុក ជា របស់ ពិសិដ្ឋ សំរាប់ ស្រុកខ្មែរ ដែល រស់ នៅ គ្មាន រូបី នៅ លើ ភ្នំ ក្នុង ព្រៃ តាម វាល ស្រែ លើ ដើមឈើ និង នៅ ក្នុង ថ្មដា ដែល ខ្មែរ អោយ ឈ្មោះ ថា ពួក អ្នកតា ដែល រស់នៅ ក្បែរ មនុស្ស ជា និច្ច នៅ គ្រប់ ទី កន្លែង ហើយ ចាំ សង្កេត មើល គ្រប់ សកម្មភាព របស់ មនុស្ស ថា តើ មាន ធ្វើ អ្វី ខុស ខ្លះ ពី ទំនៀម ខ្មែរ ដែល អាច នឹង ដាក់ ទណ្ឌកម្ម ដល់ ជន ញុះញង់ នោះ បាន។ ដូច្នេះ មនុស្ស ត្រូវ មាន ការ ប្រយ័ត្ន

ហើយ បង្ហាញ នូវ ការ គោរព របស់ ខ្លួន តាម ការ បន់ស្រន់ ធ្វើ វន្ទា នៅ ពេល ដែល តម្រូវ ដើរ កាត់ ទី កន្លែង ពិសិទ្ធ ណាមួយ។ ធ្វើ ទ្រនឹប ថ្វាយ ជូន ចំពោះ របស់ ពិសិទ្ធ ទាំង នោះ ជា សញ្ញា គារវៈ ដើម្បី សូម សេចក្តី មេត្តា និង សុខ គ្រប់ បែប យ៉ាង នៅ ក្នុង ការរស់នៅ រៀង រាល់ ថ្ងៃ។ រីឯ ពុទ្ធ សាសនា វិញ ជា ផ្លូវ ដើរ ទៅ រក និព្វាន គឺ សំរាប់ ជីវិត កើត នៅ ជាតិ ក្រោយ ឱ្យ បាន ប្រសើរ ជាង ជីវិត នៅ ជាតិ បច្ចុប្បន្ន ៈ ធ្វើ បុណ្យ ទទួល បាន បុណ្យ, ធ្វើ បាប ទទួល បាន បាប នៅ ជាតិ ក្រោយ។ ផ្លូវ នោះ គឺ ការអប់រំ ចិត្ត ខ្លួន ឯង ដោយ ខ្លួន ឯង សំរាប់ ខ្លួន ឯង គឺ ថា ក្នុង ន័យ ថា មាន តែ ខ្លួន ឯង ទេ ដែល អាច ជួយ ខ្លួន ឯង បាន។ តែ ទស្សនៈ ពុទ្ធ សាសនា នៅ មាន ច្រើន ទៀត ដូច យ៉ាង ៈ អនិច្ច, សង្សារ, ភពចក្រ, ផល, ពៀរ ។ល។

តែ នៅ ក្នុង អក្សរសិល្ប៍ ខ្មែរ នៅ ក្នុង រឿង រេមកេរ៍[49] បាន បង្ហាញ នូវ លក្ខណៈ ពិសេស របស់ ពុទ្ធ សាសនា ខ្មែរ ដូច លោក ឃិន ហុកឌី បាន ដកស្រង់ ក្នុង វគ្គ ៥៨៩ ផ្នែក ទី ១ ថា ៈ

« លុះ បាន និព្វាន ជា បង្ហើយ គត បាន កំដឹង ឡើយ រំដោះ លេង ជាតិ ជរា។ »

រួម សេចក្តី មក គឺ ថា ព្រះ អាទិទេព គឺ សំរាប់ ការពារ និង រក្សា វណ្ណៈ ក្សត្រិយៈ, អ្នកតា ជា អ្នក អនុរក្ស សុចរិត បំផុត នៃ

[49] រាមកេរ៍ មាន ន័យ ថា ជា រឿង ឬ សេចក្តី សរសើរ ចេស្តា ល្បីល្បាញ របស់ ព្រះ រាម។

ប្រពៃណី និង ទំនៀម ខ្មែរ ចំណែក ពុទ្ធ សាសនា វិញ ជា ផ្លូវ ស្វែង រក និព្វាន ឬ ចិត្ត ដែល ចេញ ផុត ស្រឡះ ចាក វានៈ ដោយ បរិយាយ ថា អស់ មាន កម្ម[50]។

មូលដ្ឋាន គ្រឹះ ទាំង បី ប្រពៃណី ភាសា និង ជំនឿ សាសនា នេះ ផ្សំ ជា មូលដ្ឋាន នៃ ចិត្តគំនិត ខ្មែរ ដែល អាច ចែក ជា បី គោលការណ៍ ធំៗ គឺ ៈ គតិ នៃ អភិរក្ស និយម, គតិ នៃ អត្តភាព និយម និង ជំនឿ លើ សាសនា និង ធម្មជាតិ។

ប្រវត្តិវិទូ បាន ចែក ប្រវត្តិសាស្ត្រ ខ្មែរ តាម លំដាប់ សម័យ គឺ ៈ

- សម័យ មុន អង្គរ ពី សតវត្ស ទី១ ដល់ ស.គ. ទី៨
- សម័យ អង្គរ ពី ស.គ. ទី៩ ដល់ ស.គ. ទី ១៤
- សម័យ ក្រោយ អង្គរ ពី ស.គ. ទី១៥ ដល់ ស.គ. ទី១៨
- សម័យ អាណានិគម បារាំង ពី គ.ស. ១៨៦៣ ដល់ គ.ស. ១៩៥៣
- សម័យ បច្ចុប្បន្ន ពី គ.ស. ១៩៥៣ រហូត ដល់ សព្វ ថ្ងៃ។

ចំណែក ៦ ភាសាវិទូ វិញ បាន ចែក ចង្កោម អក្សរសិល្ប៍ ខ្មែរ តាម ការ វិវត្តន៍ នៃ ភាសា និង និរុត្តិសាស្ត្រ ដូច បាន សរសេរ រួច ហើយ នៅ លើ ទំព័រ ទី២៥ ខាង លើ នេះ។

50 នេះ ជា អត្ថន័យ ដូច ពាក្យ សំស្រ្កឹត។

## គតិ នៃ អភិរក្សនិយម

យើង អាច សួរ ជា សំនួរ ថា តើ នៅ ក្នុង សម័យ នីមួយៗ ទាំង តាម ការ ចែក របស់ ប្រវត្តិវិទូ និង ភាសាវិទូ ចិត្តគំនិត ខ្មែរ មាន ភាព មិន ដូច គ្នា ដែរ ឬទេ ដូច យ៉ាង គតិ នៃ អភិរក្ស និយម, គតិ នៃ អត្តភាព និយម និង ជំនឿ សាសនា ?

ពី សម័យ មុន អង្គរ មក ដល់ សម័យ បច្ចុប្បន្ន សង្គម ខ្មែរ មាន ដូរ រូបភាព ពី សង្គម មាន ជាតិ សាសន៍ តែ មួយ មក សង្គម ពហុ ជាតិ សាសន៍។ នៅ ក្នុង ដំណាក់កាល នីមួយៗ វា ច្បាស់ ជា មាន ការ ប្តូរ ចិត្តគំនិត ខ្មែរ ពី ការគិត សាមញ្ញ ទៅ រក ការ គិត មិស្ស គំនិត ដែល អាច ទុក ជា ការវិវត្តន៍ ជា វិជ្ជមាន ព្រោះ វា តម្រូវ នឹង សេចក្តី ត្រូវការ របស់ សង្គម តែ ក៏ វា អាច ទុក ជា ការវិវត្តន៍ ជា អវិជ្ជមាន ផង ដែរ បើ សិន ជា មាន អ្នក ឈ្នះ និង អ្នក ចាញ់ កើត ចេញ ពី ការ ប្រយុទ្ធ មួយ ដើម្បី ស្វែង រក ការ ចាញ់ និង ឈ្នះ។ យើង ឃើញ ថា ការប្រយុទ្ធ រវាង ព្រហ្ម ញ្ញ សាសនា និង ពុទ្ធ សាសនា នៅ ក្នុង វណ្ណៈ របស់ ពួក អ្នក ដឹកនាំ ខ្មែរ ពី សម័យ អង្គរ មក ដល់ សម័យ ក្រោយ អង្គរ គឺ ធ្វើ ឡើយ នៅ ក្នុង គោលបំណង កម្ទេច ដើម្បី លុប បំបាត់។ ជ័យ ជំនះ ជា ស្ពាន របស់ ពុទ្ធ សាសនា លើ ព្រហ្មញ្ញ សាសនា គឺ មាន រូបភាព ជា ការ ធ្វើ គុត ព្រះ មហាក្សត្រ ដែល មាន ចារ នៅ ក្នុង រឿងព្រេង តា ត្រសក់ ផ្អែម ដែល ខ្មែរ ទុក ជា ការដើម នៃ ប្រវត្តិសាស្ត្រ ក្រោយ សម័យ អង្គរ ហើយ ជា ខ្សែ បន្ទាត់ ថ្មី

នៃ ដំណើរ នៃ រាជានិយម ថ្មី ដែល ផ្ដាច់ខ្លួន ពី រាជវង្ស អង្គរ។ ការសម្លាប់ ស្ដេច នេះ ឯង ជា និមិត្តរូប នៃ ការកំទេច លុប បំបាត់ របស់ ចាស់ ដើម្បី យក របស់ ថ្មី មក ជំនួស។ ដូច្នេះ ចាស់ និង ថ្មី មិន អាច រស់នៅ ជា មួយ គ្នា បាន ជា ដាច់ ខាត។ យើង សួរ ថា តើ គំនិត បែប នេះ វា មិន ផ្ទុយ ពី គតិ នៃ អភិរក្ស និយម ដែល បាន អះអាង នោះ ឬ?

តែ គោល គំនិត បដិវត្តន៍ នៅ ក្នុង ព្រឹត្តិការណ៍ នៃ តា ត្រសក់ ផ្អែម គឺ ធ្វើ ឡើង នៅ ក្នុង គតិ នៃ អភិរក្ស និយម នោះឯង។ នៅ វេលា ដែល រាជវង្ស អង្គរ ស្គាល់ អស្តង្គត នៅ ពាក់ កណ្ដាល សតវត្ស ទី១៤ នៅ ក្នុង រាជ្យ ព្រះបាទ ជ័យវរ្ម័ន ទី៩ (១៣២៨-១៣៤០) ដែល ជា ស្ដេច ចុង ក្រោយ បង្អស់ នៃ មហាក្សត្រ អង្គរ វា មាន កើត ព្រឹត្តិការណ៍ សំខាន់ មួយ នៅ ក្នុង ប្រវត្តិសាស្ត្រ ខ្មែរ ដែល នាំ ឱ្យ មាន ការប្រេះឆា ដ៏ ឃោរឃៅ នៅ ក្នុង សង្គម ខ្មែរ។ ស្ដេច ខ្មែរ ដែល ត្រូវ បាន តា ត្រសក់ ផ្អែម ធ្វើ គុត ត្រូវ បាន ប្រវត្តិសាស្ត្រវិទូ ភាគ ច្រើន និយម ថា ជា ព្រះបាទ ជ័យវរ្ម័ន ទី៩ នោះឯង ព្រោះ អ្នក ប្រវត្តិសាស្ត្រ ទាំងនោះ ដាក់ តា ត្រសក់ ផ្អែម ជា ស្ដេច ឡើង សោយរាជ្យ បន្ត ពី អង្គ ក្សត្រ នោះ។ បើ យើង យក រាជពង្សាវតារ ស្ដីពី តា ត្រសក់ ផ្អែម, ស្ដេច ដែល ទទួល គ្រោះថ្នាក់ ដល់ មរណា ពី លំពែង របស់ តា ត្រសក់ ផ្អែម គឺ ជា ស្ដេច ដែល បោះបង់ រាជធានី នៃ មហានគរ មក តាំង រាជធានី ថ្មី នៅ ក្បែរ ភ្នំ ប្រសិទ្ធ (?)។ ទី កន្លែង នោះ វា ប្រហែល ស្ថិត នៅ ក្នុង ទឹកដី កម្ពុជាក្រោម បច្ចុប្បន្ន គឺ នៅ

ក្នុង ខេត្ត ឃ្លាំង (បាសាក់) បើ យក ក្រុម ល្ខោន បាសាក់ ដែល មាន តា ត្រសក់ ផ្អែម ជា ម្ចាស់ ផង ជា អ្នក ដឹកនាំ រឿង ផង មក ធ្វើ ជា យោង នៃ ភូមិសាស្ត្រ។ សេចក្ដីយោង មួយ ទៀត ដែល បញ្ជាក់ បន្ថែម ថា រាជធានី ថ្មី របស់ ព្រះបាទ ជ័យវរ្ម័ន ទី ៩ នៅ ក្នុង ទឹកដី កម្ពុជាក្រោម បច្ចុប្បន្ន គឺ ព្រះអង្គ នេះហើយ ដែល ចាត់ គណៈ ប្រតិភូ មួយ អោយ ទៅ ធ្វើ វន្ទន កិច្ច ចំពោះ ប្រទេស ដៃវៀត (យៀកណាម) នៅ ច្រក ភ្នំ កឿរ៉ោ នៅ ឆ្នាំ ១៣៣៥។ វន្ទន កិច្ច នោះ ប្រហែល ជា ព្រះអង្គ មក រស់ ក្បែរ ទឹកដី ប្រទេស ចំប៉ា ដែល ប្រទេស ដៃវៀត ចាប់ ផ្ដើម មាន មហិច្ឆិតា ដែនដី មក ក្នុង ប្រទេស នោះ ដូច្នេះ ព្រះអង្គ ត្រូវ ស្វែងរក មិត្តភាព ជា មួយ ព្រះមហាក្សត្រ របស់ នគរ នេះ ដើម្បី សុវត្ថិភាព របស់ ព្រះអង្គ។ គំនិត នេះ ជា ការស្មាន របស់ ខ្ញុំ ផ្ទាល់ ដោយ គ្មាន ព័ស្តុតាង ជា សម្ភារៈ ក្ដី ជា ប្រវត្តិសាស្ត្រ ក្ដី ជា រឿង ព្រេង ក្ដី តែ ខ្ញុំ មាន គោលបំណង ដោយ ចេតនា បើក ទ្វារ គំនិត ឱ្យ អ្នកប្រាជ្ញ ខ្មែរ រិះគន់ ការស្មាន នេះ ដើម្បី ស្វែង រក គំនិត អ្វី មួយ ថ្មី ដែល សមរម្យ អាច ឆ្លុះមើល ហេតុផល នៃ បរិវត្តន៍ ដែល កើត ឡើង នៅ ពេល នោះ ព្រោះ បរិវត្តន៍ នោះ ជា របត់ សំខាន់ នៃ មជ្ឈដ្ឋាន របស់ អ្នក ដឹកនាំ ខ្មែរ និង វិបរិយាស[51] ជា ផ្លូវការ នៃ លទ្ធិ សាសនា របស់ ខេមរជាតិ។ ដើម្បី មើល ឃើញ ខាង ក្នុង តម្រូវ ឱ្យ យើង ដើរ ចេញ សិន ពី ក្នុង រង់ បិទ បញ្ហា ជិត ហើយ មើល បញ្ហា ពី ខាង ក្រៅ មក វិញ

[51] វិបរិយាស : ការផ្លាស់ប្រែ, ដំណើរប្រែប្រួល។

ជាមួយ នឹង សម្បធាន[52] ថ្មី ដោយ មិន ខ្លាច នឹង ស្នើ ជា ការស្នាន សមរម្យ ដើម្បី បំបែក បញ្ហា ដែល វា ស្ថិត នៅ ក្នុង គំនិតសុញ្ញ ដើម្បី រើរុះ ការស្ទះ ប្រាជ្ញា។ ដូច្នេះ នៅ ក្នុង បដិវត្តន៍ នៃ តាត្រសក់ ផ្អែម នេះ ឯង ដែល ខ្ញុំ អូស ការឆ្លុះមើល របស់ ខ្ញុំ យូរបន្តិច ដោយ គ្មាន បំណង ធ្វើ សមិតប៉ាកា[53] ជា មួយ បញ្ញាជនទាំងឡាយ នោះឡើយ ហើយ ក៏ គ្មាន គំនិត ចង់ ធ្វើ សម្បរិវត្តន៍[54] លើ និក្ខេបបទ ដែល អ្នកប្រាជ្ញ បាន សំរេច យក ជា ផ្លូវការ រួច មក ហើយ តែ គ្រាន់ តែ ស្នើ គំនិត មួយ ថ្មី អំពី ខ្លឹមសារ នៃ បដិវត្តន៍ មាន នៅ ក្នុង រាជ្យ របស់ ព្រះបាទ ជ័យវរ្ម័ន ទី ៩ ដែល គេ ទុក តា ត្រសក់ ផ្អែម ជា មេ ដឹកនាំ។

បដិវត្តន៍ របស់ តា ត្រសក់ ផ្អែម គឺ ធ្វើ ឡើង នៅ ក្នុង គតិ នៃអភិរក្សនិយម ស្រប នឹង ចិត្តគំនិត ខ្មែរ ៈ គ្រួសារ ជា សារៈ, ការគោរព នៃ ឋានានុក្រម, សេចក្ដីប្រាថ្នា នៃ ចំណេះដឹង, ចំណង់នៃ ការខិតខំ ធ្វើការ, ប្រយោជន៍ នៃ ការសន្សំទុក នៃ ទ្រព្យ។ នៅ សម័យ មហានគរ វត្ថុធាតុ ទាំងឡាយ នោះ វា មាន នៅក្នុង គតិ នៃ ប្រជារាស្ត្រ ខ្មែរ ដែល ជា វត្ថុធាតុ ផ្សំ ជា កម្លាំង នៃខេមរជាតិ។ អត្តង្គត នៃ រាជានិយម អង្គរ ធ្វើ ឱ្យ វា បាត់បង់កម្លាំង នេះ។ ប្រវត្តិវិទូ បរទេស មួយ ចំនួន និយម បង្ហាញ ពីមូលហេតុ សំខាន់ៗ អំពី ការចុះអន់ថយ នៃ មហានគរ ខ្មែរ

52 សម្បធាន ៈ ការពិចារណា, ការគិតឈ្លេចឈ្លីរកឱ្យឃើញ។
53 សមិតប៉ាកា ៈ សង្គ្រាមប៉ាកា។ ខ្ញុំប្រើពាក្យ សមិត ជំនួស ពាក្យ សង្គ្រាម ដើម្បី បន្ថយ អត្ថន័យ ហិង្សា នៅ ក្នុង ពាក្យ សង្គ្រាម។
54 ធ្វើ សម្បរិវត្តន៍ ៈ រើរុះ។

កើត មក ពី មហន្តរាយ ធម្មជាតិ ដូចយ៉ាង ភាពស្ងួត ផង និង ទឹកលិច ផង នៅ ដំបន់ ទន្លេសាប ដែល ជា ប្រភព ធម្មជាតិ នៃ ការរីកចំរើន នៃ មហានគរ ខ្មែរ។ នៅ លើ ចំណុច នេះ ពួក អ្នកស្រាវជ្រាវ គេ មាន ភស្តុតាង វិទ្យាសាស្ត្រ ដើម្បី បញ្ជាក់ លើ ការអះអាង របស់ គេ ដែល គ្មាន នរណា អាច ប្រកែក បាន ជា ពិសេស ពួក ប្រវត្តិវិទូ ខ្មែរ ដែល គាត់ ទទួល បាន ចំណេះដឹង ពី អ្នកប្រាជ្ញ បរទេស។ ពិត ណាស់ ហើយ អ្នក ចេះដឹង ខ្មែរ គាត់ មិន សូវ ហ៊ាន ដើរ ចេញ ពី វង់ បិទ នៃ ចំណេះដឹង ដែល គាត់ បាន ទទួល នោះឡើយ ព្រោះ គាត់ ខ្លាច ពួក គ្រូ បរទេស របស់ គាត់ សើចចំអក ឱ្យ គាត់ ថា គាត់ មិន មែន ជា បញ្ញាវន្ត ។ សួរ ថា ការចេះដឹង បែប នេះ តើ វា មាន ប្រយោជន៍ ដល់ ជាតិ ខ្មែរ ដែរ ឬ ទេ បើ គាត់ មិន បន្ត យក ចំណេះ មូលដ្ឋាន ដែល គាត់ បាន ទទួល ទៅ បើក គតិ របស់ គាត់ ដើម្បី ធ្វើ ការស្រាវជ្រាវ លើ អ្វី ដែល នៅ ជា ភាព អាថ៌កំបាំង នៅ ក្នុង ប្រវត្តិសាស្ត្រ ជាតិ ដោយ រើុះ លើ អ្វី ដែល ជា ចំណុច សួរ នៅ ឡើយ មាន នៅ ក្នុង ចិត្តគំនិត ខ្មែរ។ រឿង នេះ មិន មែន ជា ការស្ដីរំឭក នោះ ឡើយ តែ គ្រាន់ ជា ការសោកស្ដាយ ជាមួយ នឹង អារម្មណ៍ ខក ចិត្ត ព្រោះ បញ្ញជន ខ្មែរ គាត់ សុទ្ធ តែ អ្នក ប្រាជ្ញា ខ្ពង់ខ្ពស់ ជា បញ្ញវន្ត ឈានមុខ សំរាប់ បំបាន បន្ថែម នូវ ចំណេះដឹក ខ្មែរ ក្នុង ផ្នែក មនុស្សសាស្ត្រ។ ខ្ញុំ នៅ ចាំ នៅឡើយ កាល ខ្ញុំ ជា និស្សិត នៅ មហាវិទ្យាល័យ អក្សរសាស្ត្រ និង មនុស្សសាស្ត្រ ផ្នែក ប្រវត្តិសាស្ត្រ និង ភូមិសាស្ត្រ មាន សាស្ត្រាចារ្យ ជា ច្រើន ជា ជន

ជាតិបារាំង គេ មក បង្រៀន អំពី មូលដ្ឋាន វិទ្យាសាស្ត្រ នៃ មុខ វិជ្ជា នោះ ដែល ជា មូលដ្ឋាន ចាំបាច់ ដូចយ៉ាង ៖ មូលដ្ឋានគោល នៃ ចំណេះដឹង នៃ ប្រវត្តិសាស្ត្រ និង ជំនួយ ដល់ ការអភិវឌ្ឍន៍ នៃ ចំណេះ រិះគន់ តាម ការផ្ដួចផ្ដើម ជា ការលើក បញ្ហា ផ្សេងៗ មក ចោទ ជា សំនួរ បញ្ហា និង គោលវិធី នៃ ការស្រាវជ្រាវ ប្រវត្តិ សាស្ត្រ។

មូលដ្ឋានគោល នៃ ប្រវត្តិសាស្ត្រ ខ្មែរ មាន ពិត ដែល អ្នកប្រាជ្ញ បរទេស គេ បាន សិក្សា និង ស្រាវជ្រាវ ជា ជម្រៅ ជា ពិសេស នៅ សម័យ មុន អង្គរ និង សម័យ អង្គរ។ នៅ សម័យ ក្រោយ អង្គរ មាន ពង្សាវតារ ខ្មែរ ដែល បុព្វបុរស ខ្មែរ សរសេរ ទុក ទោះ បី គ្មាន ភាពតឹងរឹង នៃ វិទ្យាសាស្ត្រ ក៏ អាច ទុក បាន ជា មូល ដ្ឋាន ប្រវត្តិសាស្ត្រ ជាតិ ខ្មែរ បន្ត ពី សម័យ អង្គរ។ ដូច្នេះ ខេមរ ជាតិ មាន ដំណើរ ប្រវត្តិសាស្ត្រ រលូន ពី ដើម ទី រហូត មក ដល់ សព្វថ្ងៃ នេះ។ ពិត ប្រាកដ ណាស់ ហើយ ថា មាន ចន្លោះ ខ្លះៗ ដែល មិន បាន បង្ហាញ ព្រឹត្តិការណ៍ ឱ្យ បាន ពិស្ដា តែ ការត ផ្ជាប់ ដើម្បី បន្ត ក៏ វា មាន ភាពជាប់លាប់ របស់ វា ដែល នាំ ឱ្យ ខ្មែរ យល់ បាន, ដូចយ៉ាង ប្រវត្តិសាស្ត្រ នៃ តា ត្រសក់ ផ្អែម ដែល បញ្ញជន មួយ ចំនួន ទុក ជា ព្រឹត្តិការណ៍ បដិវត្ត តែ គ្មាន អ្នកណា អាច ពន្យល់ ឱ្យ បាន ល្អិតល្អន់ អំពី មូលហេតុ នៃ បដិវត្តន៍ នោះ។ សព លោក កេង វ៉ាន់ សាក់[55] ធ្លាប់ បាន

[55] កេង វ៉ាន់ សាក់ ៖ លោក ជា បញ្ញវន្ត ខ្មែរ ម្នាក់ ល្បីល្បាញ ក្នុង ផ្នែក អក្សរ សាស្ត្រ និង មនុស្សសាស្ត្រ។

បរិយាយ រឿយៗ ធ្វើ ដោយ វាចា[56] ថា អត្តង្គត ខ្មែរ មាន មូល ហេតុ ពី ខ្មែរ បាត់ ក្បួន ដើម របស់ ជាតិ សាសន៍ ខ្មែរ គឺ ការ គោរព គ្រូ ៥ មាន ៖ មេ បា ព្រះ តា ចៅរ៍[57] (ចៅ)។ ក្បួន នោះ ជា ការកត់ត្រា ទុក ជំនឿ ខ្មែរ ដើម ដែល មាន ឈ្មោះ ថា ‹ជី[58]› ដែល គ្មាន ដំណូច និង លទ្ធិ ព្រលឹង និយម (animisme)។ ព្រោះ លទ្ធិ ព្រលឹង និយម ដែល ផ្អែក ទៅ លើ ការបន់ស្រន់ សូម សេច ក្ដីសុខ ពី ព្រលឹង អរូប រស់ នៅ ក្នុង ធម្មជាតិ ដែល មាន  រូប អ្នកតា ជា តំណាង នៃ អំណាច របស់ ធម្មជាតិ, ចំណែក លទ្ធិ ជី វិញ គឺ ការអនុវត្តន៍ ក្បួន របស់ មនុស្ស ដែល បង្កើត ឡើង ពី មនុស្ស សំរាប់ មនុស្ស។ ក្បួន កន្លោង នោះ គឺ ការគោរព គ្រូ ៥ នោះ ឯង ៖ មេ បា ជា និមិត្តរូប ទឹក និង ដី, ជា ធាតុ ស្រ្តី និង បុរស, ស្រ្តី ខ្មែរ យក រូប នាង គង្ហីង ជា និមិត្តរូប រីឯ បុរស វិញ គឺ យក សត្វ ក្រពើ។ តូតិម[59] ខ្មែរ ក្នុង លទ្ធិ ជី គឺ នាង គង្ហីង ព្រះធរណី និង ក្រពើ។ មេ បា នេះ ជា វត្ថុធាតុ ពីរ តែ រួម គ្នា តែ មួយ បង្កើត ជា កម្លាំង ទ្រទ្រង់ ទឹកដី នៃ ប្រជាជាតិ ខ្មែរ។ ព្រះ

---

[56] សូមស្ដាប់ សតិ ចងចាំ របស់ លោក កេង វ៉ាន់ សាក់ ផ្សាយ ដោយ វិទ្យុ អាស៊ី សេរី។

[57] ចៅរ៍ ជា សម្លេង ចៅ អូស វែង។

[58] ជី ៖ ពាក្យ នេះ មាន នៅ ក្នុង វចនានុក្រមខ្មែរ ពុទ្ធ សាសបណ្ឌិត មាន អត្ថន័យ ថា អ្នក, ឯង ; ពាក្យ គួរសម សំរាប់ ហៅ ក្មេង ប្រុស ដែល ទើប សឹក ពី សមណេរ និង អ្នក ចាស់ ហៅ អ្នក តូច ឬ ក្មេង ជាង ដោយ រាប់ អាន ; ស្រ្តី ដែល កោរ សក់ ស្លៀក ដណ្ដប់ សំពត់ កាន់ សីល ១០ ; ទម្ងន់ អនុភាព អំពី តម្លឹង ៖ មាស មួយ ជី ; អ្វី ដែល មាន រសជាតិ ធ្វើ ឱ្យ ដំណាំ លូតលាស់ ល្អ ; គ្រឿង ដាំ ត្បូង រាងសណ្ឋាន ស្លឹក សីមា សំរាប់ បំពាក់ កូន ក្មេង។

[59] តូតិម (Totem) : សញ្ញា លក្ខណ៍ នៃ សត្វ ដែល ជា ដើម សន្តតិវង្ស។

ជា គោលលទ្ធិ ឈរ លើ សច្ចះ[60], ភាព ខ្ពង់ខ្ពស់ ដែល គួរប្រាថ្នា។ គា ជា អ្នក ណែនាំ កិច្ចការ គ្រប់ បែប យ៉ាង ក្នុង ការរស់នៅ, ក៏ ជា ឃ្លាំង នៃ ចំណេះដឹង, ក៏ ជា គ្រូ ឬ បាគូរ[61] បង្ហាត់បង្រៀន គ្រប់ ចំណេះដឹង ដល់ ខ្មែរ គ្រប់ វ័យ ដែល ចង់ ចេះដឹង។ អ្នក ទទួល ការអប់រំ ទាំងឡាយ នោះ ឯង ដែល ហៅ ថា ចៅ (ចៅរ) បង្កើត ជា កម្លាំង ជាតិ ដើម្បី ការពារ ប្រជាជាតិ ដែល មាន មេ-បា ជា អ្នក ទ្រទ្រង់។ នេះ ជា សេចក្តីសង្ខេប នៃ លទ្ធិ ជី ដែល លោក កេង វ៉ាន់ សាក់ ជឿ ថា ជា ជំនឿ ដើម របស់ ខ្មែរ។ ទ្រឹស្តី នេះ លោក កេង វ៉ាន់ សាក់ គាត់ មិន ដែល យក មក ចង ក្រង ជា ឯកសារ សំរាប់ ឱ្យ ខ្មែរ យក មក អាន នោះឡើយ ទោះ បី លោក មាន ពេលវេលា គ្រប់គ្រាន់ នៅ ក្នុង ជីវិត របស់ គាត់ ជា អ្នក ស្រាវជ្រាវ ដ៏ ឆ្នើម ម្នាក់ ក្នុង ចំណោម អ្នក ចេះដឹង ខ្មែរ នៅ ក្នុង ភូមិ នៃ មនុស្សសាស្ត្រ។ ព្រោះ ហេតុអ្វី ? តើ នេះ ជា អាថ៌កំបាំង របស់ រឿង ចិត្ត បុគ្គល កេង វ៉ាន់ សាក់ ដែល គ្មាន អ្នក ណា អាច ដឹង នោះឡើយ ? តែ ទោះបី យ៉ាង លោក ក៏ បាន ទុក ទ្រឹស្តី កន្លោង របស់ គាត់ តាម ការធ្វើសម្ភាសន៏ ជាមួយ វិទ្យុ អាស៊ី សេរី សំរាប់ ឱ្យ ខ្មែរ ស្តាប់ នោះ ដែរ។ សគុណ របស់ លោក ទោះ បី ទ្រឹស្តី នោះ គ្មាន មូលដ្ឋាន វិទ្យាសាស្ត្រ ច្បាស់លាស់ តែ លោក មាន ជំនឿ ថា ជា ការពិត មួយ មាន នៅ ក្នុង

---

60 សច្ចះ : សេចក្តីពិត, ដំណើរទៀងត្រង់។

61 តាម ទស្សនៈ របស់ លោក កេង វ៉ាន់ សាក់ បាគូរ នេះ ជា អ្នកប្រាជ្ញ នៅ ក្នុង លទ្ធិ ជី តែ ក្រោយ មក មាន អ្នក ខ្លះ ក៏ នាំ គ្នា ចូល ព្រហ្មញ្ញសាសនា។

សង្គម ដើម របស់ ខ្មែរ ដែល ត្រូវ សាសនា បរទេស កម្ទេច ចោល គឺ មាន ព្រហ្មញ្ញ សាសនា និង ពុទ្ធ សាសនា នៅ ពេល ដែល សាសនា នោះ ហូរ ចូល មក ក្នុង ស្រុកខ្មែរ ដែល ជា ជំនឿ បើក ទ្វារ គំនិត សំរាប់ ខ្មែរ យក មក ពិចារណា បន្ថែម ដើម្បី រក ចម្លើយ ថា មហិទ្ធានុភាព នៃ ប្រជាជាតិ ខ្មែរ ស្ថិត នៅ លើ មូលដ្ឋាន អ្វី ក្រៅ ពី ប្រភព នៃ ព្រាហ្មញ្ញ សាសនា សាសនា និង ពុទ្ធ សាសនា។ ជំនឿ របស់ លោក បែប នេះ ដែល នាំ ឱ្យ អ្នកផង ទុក លោក ជា មនុស្ស គ្មាន ជំនឿ សាសនា ឬ សុញ្ញ វាទ[62] និង ជា ជនកុម្មុយនិស្ត។ ត្រូវ ដឹង ថា អត្ថភាព នៃ សាសនា ទី៣ មាន ក្បួន ពិត ប្រាកដ នោះ មាន សរសេរ នៅ ក្នុង សៀវភៅ របស់ អ្នកប្រាជ្ញ បារាំង និង ជនចិន ដែល បាន មក ស្រុកខ្មែរ នៅ សម័យ អង្គរ។ សួរ ថា តើ លោក កេង វ៉ាន់ សាក់ មាន គំនិត បិទបាំង ប្រើ អត្ថភាព នៃ សាសនា ទី៣ មាន នៅ ស្រុកខ្មែរ ពី ជំនាន់ ដើម ដើម្បី យក មក ធ្វើ អាវុធ នយោបាយ វាយ ប្រហារ របប រាជាធិបតេយ្យ និយម ដែល ជា របប ដឹកនាំ ទុក សាសនា ព្រហ្មញ្ញ សាសនា និង ពុទ្ធ សាសនា ជា ខ្លឹមសារ របស់ ខ្លួន។ ចម្លើយ ថា វា អាច នឹង មាន ព្រោះ លោក កេង វ៉ាន់ សាក់ ដើម ឡើយ គាត់ ជា នយៈជន[63] ធ្វើ នយោបាយ ដើម្បី ជំនឿន នៃ ប្រជាធិបតី, ជា អ្នក ជឿនលឿន

[62] សុញ្ញវាទ ៖ លទ្ធិ ដែល ប្រកាន់ ថា ស្លាប់ សូន្យ មិន កើត ទៀត, លទ្ធិ ដែល ប្រកាន់ ថា គ្មាន ព្រះ។
[63] នយៈជន ៖ អ្នក នយោបាយ។

និយម ឈរ លើ សច្ចៈ, ជា អ្នក ប្រឆាំង នឹង អាណានិគម និយម។ លទ្ធិ ជី ដែល លោក យក មក លើក តម្កើង វា មាន សម្លេង ជា ការតស៊ូ នៃ វណ្ណៈ គឺ ថា ការវាយ កំទេច លទ្ធិ ខ្មែរ ដើម ពី សំណាក់ សាសនា បរទេស ដែល របប រាជាធិបតេយ្យ និយម យក មក ធ្វើ ជា បូជនីយ ជំនឿ ។ នៅ ក្នុង ចិត្តគំនិត របស់ លោក, លទ្ធិ ជី ជា លទ្ធិ របស់ ប្រជារាស្ត្រ កើត ចេញ ពី ប្រជារាស្ត្រ, បង្កើត ដោយ ប្រជារាស្ត្រ សំរាប់ បំរើ ផលប្រយោជន៍ ដល់ ប្រជារាស្ត្រ។ លទ្ធិ នេះ ឯង ជា ប្រជាកម្លាំង កសាង មហានគរ ខ្មែរ ជា ឧទាហរណ៍ គ្រប់ ប្រាសាទ ខ្មែរ, ខ្មែរ មិន ដែល យក ឈ្មោះ ព្រះមហាក្សត្រ ឥណ្ឌូ និយម ឬ ពុទ្ធ និយម មក ប្រថាប់ នាម ឱ្យ នោះឡើយ ដូច យ៉ាង ប្រាសាទ ល្បីៗ មាន ប្រសាទ បន្ទាយ ស្រី, ព្រះ អង្គរ, ព្រះខាន់, បាយ័ន ។ល។ យើង ឃើញ ថា នៅ ក្នុង ការពោលអះអាង នេះ លោក មិន បាន ស្វែង រក សំយោគ លទ្ធិ សាសនា ទាំងឡាយ ដែល មាន នៅ ស្រុកខ្មែរ ថា ជា ការរួម កម្លាំង ឬ កម្លាំង បង្រួប នៃ ការកសាង មហានគរ ខ្មែរ សោះឡើយ តែ លោក ក៏ មិន បាន ទុក សាសនា ដើម ខ្មែរ ថា មាន វិសិដ្ឋភាព ដាច់ខាត លើ សាសនា ដទៃ ទៀត ដែរ តែ អត្ថភាព ពិត នៅ ក្នុង សន្តានចិត្ត ខ្មែរ វា នាំ ឱ្យ ព្រហ្មញ្ញ សាសនា ក្តី ពុទ្ធ សាសនា វាយប្រហារ មក លើ សាសនា ដើម ខ្មែរ ផង និង សម្របសម្រួល ផង ដើម្បី កម្ទេច មូលដ្ឋាន គ្រឹះ តែ រក្សា ប្រពៃណី។ សួរ ថា លើ ចំណុច ‹ កម្ទេច › នេះ តើ យើង អាច ទុក វា ជា ក្រហែង នៅ ក្នុង ទស្សនៈ របស់ លោក បាន ដែរ ឬទេ

? ព្រោះ ថា វា គ្មាន ភាពរីកចំរើន ណា មួយ ដែល យក ការបាក់បែក កម្លាំង ជា មូលដ្ឋាន នៃ ការកសាង នោះឡើយ។

បើ យោង តាម ទស្សនៈ របស់ លោក កេង វ៉ាន់ សាក់, បដិវត្តន៍ របស់ តា ត្រសក់ ផ្អែម ជា ការសង្គ្រោះជាតិ ដោយ យក លទ្ធិ ដើម ខ្មែរ មក លើក តម្កើង ឡើង វិញ។ ដូច្នេះ មិនមែន ជា បដិវត្តន៍ សំរាប់ ដូរ លទ្ធិ សសានា ដូច ការយល់ឃើញ របស់ អ្នក ប្រាជ្ញ ខ្លះ នោះឡើយ។ តើ លក្ខណៈ ណា មួយ ដែល បញ្ជាក់ អំពី ប្រត្យាស្ថាប័ន នៃ លទ្ធិ ដើម ខ្មែរ ? លោក កេង វ៉ាន់ សាក់ គាត់ និយម លើក យក គំនិតបកស្រាយ របស់ អ្នក ប្រវត្តិសាស្ត្រ ខ្មែរ[64] ថា មាន និន្នាការ ការពារ សាសនា ជា ផ្លូវការ ព្រោះ ខ្លួន ជា អ្នក កាន់ ព្រះពុទ្ធ សាសនា នៅ សម័យ ដើម ហើយ នាំ គ្នា ក្រឡៃ ព្រឹត្តិការណ៍ ដោយ គ្រាន់ តែ ទុក ឃាតកម្ម ស្ដេច ជា អំពើ ចៃដន្យ គ្មាន ការរៀបចំ ទុក ជា មុន នោះឡើយ ហើយ ការអញ្ជើញ ឃាតករ ឱ្យ ឡើង គ្រង រាជ្យ បន្ត ពី ស្ដេច គ្រង រាជ្យ ជា ជន រងគ្រោះ គឺ ធ្វើ ឡើង នៅ ក្នុង គោល ទស្សនៈ បុណ្យ និង បាប របស់ ពុទ្ធ សាសនា គឺ ថា តា ត្រសក់ ផ្អែម ជា អ្នក ទទួល បុណ្យ រីឯ ស្ដេច ជា អ្នក ទទួល បាប ពី អាតីត ជាតិ។ សួរ ថា តើ សេចក្ដីសំអាង នេះ វា មាន តក្កភាព (logique) ដែរ ឬទេ ? ចម្លើយ សមហេតុសមផល គឺ ថា ទេ, ព្រោះ ថា បើ តា ត្រសក់

64 លោក កេង វ៉ាន់ សាក់ មាន មតិ ថា រឿង ព្រះបាទ ហ៊ុន ទៀន ជា រឿង ប្រឌិត ដោយ ពួក អ្នក ប្រវត្តិសាស្ត្រ ដើម្បី ការពារ រាជាធិបតេយ្យ និយម និយម ព្រាហ្មណ៍ សាសនា។ លោក ក៏ សន្មត់ ដែរ ថា រឿង ព្រះ ថោង និង នាង នាគ ក៏ ជា រឿង ប្រឌិត ការពារ រាជានិយម នោះ ដែរ។

ផ្អែម គ្មាន ប្រជាករ គាំទ្រ ព្រោះ ទុក គាត់ ជា បាគួរ ច្បាស់ ជា គ្មាន រដ្ឋប្រហារ រំលំ រាជវង្ស មហានគរ បាន នោះឡើយ។ ពិត ប្រាកដ ណាស់ ថា រដ្ឋប្រហារ នោះ មាន សេចក្ដីទីពឹង ពី សំណាក់ មន្ត្រីរាំង មួយ ចំនួន ដែល ជា ពួក អ្នក នៅ គោរព លទ្ធិ ជី ហើយ ប្រហែល ជា ពួក ទាំង នោះ ឯង ជា ពួក អ្នក ដៃដល់ សម្លាប់ ស្ដេច ផង។ ចុះ ហេតុអ្វី បាន ជា តា ត្រសក់ ផ្អែម មាន ថ្លើមធំ ហ៊ាន ធ្វើ រដ្ឋប្រហារ ? គឺ ឆ្លៀត ឆក់ យក ឱកាស ដែល របប ដឹកនាំ និយម ព្រហ្មញ្ញ សាសនា និង ពុទ្ធ សាសនា មហា យាន លែង មាន ការគាំទ្រ ពី សំណាក់ ប្រជារាស្ត្រ និង ប្រជាប្រិយភាព របស់ ខ្លួន ដែល ប្រហែល តាំង ខ្លួន ជា បាគួរ តែ លាក់ ខ្លួន ក្នុង តួ នាទី ជា អ្នក ដឹកនាំ រឿង ខ្លួន។ រឿង ល្ខោន ដែល គាត់ តែង ប្រហែល ជា ការរិះគន់ ដោយ ប្រយោល ដល់ របប ដឹកនាំ ដែល ទាក់ទាញ ចិត្ត ពួក អ្នកស្រុក ឱ្យ មក ទស្សនា ច្រើន កុះករ និង មន្ត្រីរាំង មួយ ចំនួន ដែល យល់ ឃើញ ថា បាគួរ នេះ គាត់ នឹងអាច ជា អ្នក ដឹកនាំ បដិវត្តន៍ ប្រកប ដោយ ប្រសិទ្ធិភាព ព្រោះ គាត់ មាន គំនិត នយោបាយ ឧត្តុង្គ ឧត្តម ហើយ មាន ប្រជាប្រិយភាព ខ្លាំង ណាស់។ បន្ទាប់ ភ្លាម ឡើង គ្រង រាជសម្បត្តិ តា ត្រសក់ ផ្អែម ប្រញាប់ បង្កើត ឡើង វិញ ក្រុម បាគួរ និង ប្រញាប់ប្រញាល បញ្ជូន បាគួរ មួយ

ចំនួន ទៅ ស្វែង រក ក្បួន បុរាណ ខ្មែរ នៅ ស្រុក លាវ[65][66]។ អ្វី ដែល សរសេរ ខាង លើ នេះ វា អាច ជា ការប្រឌិត សុទ្ធសាធ ដើម្បី បង្កើត របៀបបកស្រាយ មួយ ខុស ពី រឿងព្រេង នៃ តា ត្រសក់ ផ្អែម តែ ក្រោយមក ស្រុកខ្មែរ ក្លាយ ជា ស្រុក នៃ ពុទ្ធ សាសនា, ពួក អ្នកប្រាជ្ញ ក៏ បាន នាំ គ្នា រើសយក រឿងព្រេង ជា រឿង ប្រវត្តិសាស្ត្រ ជា ផ្លូវការ ដែល មាន ចារ ទុក នៅ ក្នុង ព្រះ រាជពង្សាវតារ ខ្មែរ។ តែ សារៈសំខាន់ នៃ ការបកស្រាយ ខុស ពី ព្រះរាជពង្សាវតារ គឺ ចង់ បង្ហាញ ថា បដិវត្តន៍ របស់ តា ត្រសក់ ផ្អែម គឺ ធ្វើ ឡើង នៅ ក្នុង គតិ អភិរក្សនិយម គឺ ថា បំណង វិល ត្រឡប់ ទៅ រក ប្រភព ដើម ខ្មែរ គឺ លទ្ធិ ជី ដែល មាន មូល ដ្ឋាន : គ្រួសារ ជា សារៈ, ការគោរព នៃ ឋានានុក្រម, សេចក្តី ប្រាថ្នា នៃ ចំណេះដឹង, ចំណង់ នៃ ការខិតខំ ធ្វើការ, ប្រយោជន៍ នៃ ការសន្សំទុក នៃ ទ្រព្យ។

សួរ ថា តើ បដិវត្តន៍ របស់ តា ត្រសក់ ផ្អែម ទទួល បាន ជោគជ័យ ដែរ ឬទេ ? ស្ដីពី ការដូរ របប ដឹកនាំ គឺ អាច ថា ទទួល បាន, តែ ស្ដីពី ការផ្ដួល នៃ ស្ថានភាព ទាំងមូល នៃ អត្តង្គត ខ្មែរ គឺ អាច ថា វា គ្មាន ជោគជ័យ ជាក់ស្ដែង នោះទេ

65 ត្រង់ ចំណុច នេះ ពួក ភិក្ខុ ជា អ្នក សរសេរ ពង្សាវតារ តែង បកស្រាយ ថា តា ត្រសក់ ផ្អែម បង្កើត ពួក បាគូរ គឺ ពួក ព្រាហ្ម បុរោហិត នោះ ឯង វិឯ ទៅ ស្វែង រក ក្បួន វិញ ថា ទៅ ចំឡង ព្រះត្រៃបិដក ទៅ វិញ។

66 ប្រហែល មាន ពួក បាគូរ នៃ លទ្ធិ ជី ដែល មិន ព្រម ចុះចូល នឹង ព្រហ្ម ញ្ញ និង ពុទ្ធ សាសនា នាំ គ្នា ទៅ រស់នៅ ស្រុកលាវ ដែល នៅ ជំនាន់ នោះ នៅ ជា ទឹកដី ស្រុកខ្មែរ នៅឡើយ។

ព្រោះ អត្តង្គត ខ្មែរ វា មិន ស្ថិត នៅ ត្រឹម តែ របប នយោបាយ ដឹកនាំ ជាតិ នោះឡើយ, វា ស៊ី ជម្រៅ រហូត ដល់ ចិត្តគំនិត តែម្តង។ ដូច យ៉ាង ខ្មែរ ភាគ ច្រើន នាំ គ្នា និយាយ តៗ គ្នា ថា ខ្មែរ ចុះអន់ថយ ដោយ សារ ខ្មែរ បាត់ ក្បួន ដែល បុព្វបុរស យក ទៅ លាក់ ទុក ក្នុង ពោះ ព្រះគោ ហើយ ព្រះគោ នោះ ត្រូវ សៀម គេ យក ទៅ ស្រុក គេ នៅ សម័យ លង្វែង ដែល ខ្មែរ ចាញ់ ស ង្គ្រាម សៀម (១៥៩៣)។ ការណ៍ នេះ វា មាន ការពិត ព្រោះ ជំនាន់ នោះ សៀម គេ កេណ្ឌ យក អ្នកប្រាជ្ញ ខ្មែរ ជា ច្រើន យក ទៅ ស្រុក គេ ដែល នាំ ឱ្យ ខ្មែរ បាត់ ប្រភព នៃ ចំណេះដឹង។ ដូច្នេះ រូបភាព នៃ ការបាត់បង់ នោះ អ្នកប្រាជ្ញ ខ្មែរ គាត់ យក ការជញ្ជូន យក បេតិកភ័ណ្ឌ មាន ព្រះគោ និង ព្រះកែវ ជា និមិត្តរូប នៃ ការបាត់បង់ បញ្ញា ខ្មែរ។ ប៉ុន្តែ ការបាត់បង់ បញ្ញា នៅ សម័យ នោះ មិន មែន បាត់ ក្រោយ ពី បរាជ័យ យោធា នោះឡើយ គឺ បាត់ ពី មុន មក ម្លេះ។ ដូច្នេះ បរាជ័យ យោធា វា គ្រាន់តែ ជា អនុភាព នៃ ការបាត់ បញ្ញា នោះ ឯង។ បន្ទាប់ ពី សម័យ លង្វែក មក ស្រុកខ្មែរ រំអិលខ្លួន ធ្លាក់ ចុះ ទៅ ក្នុង អន្លង់ ងងឹត ហើយ សំគោក ខ្លួន នៅ ក្នុង  សភាព ហេវហត់ រហូត ដល់ សម័យ បារាំង ចូល ស្រុក ដែល ខ្មែរ និយម ទុក ជា ការសង្គ្រោះជាតិ ពី យួន និង សៀម ដែល ជា បរិប្រទេស[67] កំណាច របស់ ស្រុកខ្មែរ។ តើ មក ដល់ ស្ថានភាព នេះ តើ ខ្មែរ មាន ដែល សួរ ខ្លួន ឯង ថា មក ពី ហេតុអ្វី ? ពិត ជា មាន ដូច

67 បរិប្រទេស : ប្រទេស ជិតខាង។

បាន ជំរាប ខ្លះៗ ពី ខាង លើ នោះ, តែ តើ មាន ដំណោះស្រាយ អ្វី ខ្លះ ដើម្បី ឆ្លើយ សម្រប ប្រកប ដោយ ប្រសិទ្ធិភាព នឹង បញ្ហា ដែល ខ្មែរ បាន ជួប ប្រទេះ ដែរ ឬទេ ?

# ការកែទម្រង់

មាន កំណែទម្រង់ ជា ច្រើន នៅ ក្នុង ប្រវត្តិសាស្ត្រ ខ្មែរ ដើម្បី ឆ្លើយ តម នឹង បញ្ហា ធំៗ របស់ ប្រជាជាតិខ្មែរ។ ដូច លោក Jean IMBERT (ទំព័រ ទី៤៩) ចោទ ជា សំនួរ មួយ ចំនួន អំពី មូលហេតុ នៃ អត្ថង្គត របស់ ប្រជាជាតិ ខ្មែរ។ យើង លើក សំនួរ ផ្សេងៗ ទៀត ដែល បញ្ញាជន និង អ្នកប្រាជ្ញ ខ្លះ គេ ចោទ ជា សំនួរ ថា :

### ឯណា គ្រោះថ្នាក់ សំរាប់ ប្រជាជាតិ ខ្មែរ ?

ចំពោះ លោក នួន ឃឿន គ្រោះថ្នាក់ នៃ ប្រជាជាតិ ខ្មែរ គឺ បញ្ហា នៃ ប្រជាជាតិ យួន នោះ ឯង ដែល ជា អ្នក ជិតខាង ខ្មែរ នៅ មាន ជា និច្ច  មហិច្ឆិតា ទឹកដី មក លើ ខ្មែរ។ លោក រាប់រៀប កត្តា ជា គ្រោះថ្នាក់ ធំ បី យ៉ាង ដូចជា កម្លាំង នយោបាយ - គុណសម្បត្តិ នៃ ប្រជាជន - ការវិវត្តន៏ នៃ បណ្តាជន ដែល ជនជាតិ យួន មាន ទាំងអស់ ដោយ ឥត ប្រកែក បាន។ វប្បធម៏ ខ្មែរ និង យួន មាន ការវិវត្តន៏ ផ្ទុយគ្នា ពោល ថា វប្បធម៏ យួន ចេះ តែ មាន ការចំរើន ឡើង រីឯ វប្បធម៏ ខ្មែរ វិញ នៅនឹង ហើយ គ្មាន ជំហ៊ាន ឈានមុខ, តើ មក ពី ជាតិសាសន៏ ខ្មែរ អត់ប្រាជ្ញា ជាង ជាតិសាន៏ យួន ?

ជន បារាំងសែស ម្នាក់ ឈ្មោះ អ. បូន្ទរ សរសេរ ក្នុង ឆ្នាំ ១៩០០ សៀវភៅ មួយ មាន ចំណងជើង ថា ‹ ឥណ្ឌូចិន › ថា : ‹ *ប្រជាជននៅ កម្ពុជា ប្រហែល ជា ខ្លាំង តាម ផ្លូវកាយ ជាង ប្រជាជន អណ្ណាម មែន ប៉ុន្តែ ខ្វះ ថាមពល ខ្វះ សមត្ថភាព។ ការរៀបចំ លើ ផ្ទៃ សង្គម នៅ រាក់ កំភែល ហើយ ស្រដៀង នឹង របៀប ព្រៃ។ គ្មាន ការបណ្តុះបណ្តាល គំនិត ប្រាជ្ញា ឡើយ (ក្នុង ពេល ដែល នៅ អណ្ណាម យួន ក្រ យ៉ាង ណា ក៏ ដោយ ហើយ គ្រួសារ ខ្លួន តូចតាច យ៉ាង ណា ក៏ ដោយ ក៏ នៅ តែ មាន ការ អប់រំ រំលឹក តែ គ្រប់ គ្នា។ ភូមិ យួន ទាំងអស់ មាន សាលារៀន បង្រៀន ឥត យក ថ្លៃ បើ មិន ចង់ ថា គេ តម្រូវ អោយ កូន ក្មេង ទៅ រៀន គ្រប់ គ្នា) រីឯ ភូមិខ្មែរ គ្មាន សាមគ្គីធម៌ តាម ផ្លូវ ចិត្ត ឡើយ ហើយ ដោយ ហេតុ នេះ ឥត មាន មនោសញ្ចេតនា ជាតិ បន្តិចបន្តួច ឥត មាន គំនិត ថា មាតុភូមិ ជា អ្វី ឡើយ។ ជនខ្មែរ អន់ ជាង ជនយួន យ៉ាង ឆ្ងាយ ក្នុង គ្រប់ ផ្នែក ទាំងអស់។ ប៉ុន្តែ បើ ខ្មែរ គ្មាន គុណសម្បត្តិ យួន ខ្មែរ មាន គុណវិបត្តិ យួន រហូត ដល់ ទៅ ប្រាក់ ចំណូល មែន ទែន នៃ ស្តេចខ្មែរ បាន មក តែ ពី ការយកតុង លើ បន ល្បែង ស៊ីសង ដែល ចិន ជា អ្នក កាន់កាប់ ហើយ ដែល ធ្វើ អោយ ប្រទេស ហិនហោច....ពាណិជកម្ម ទាំងមូល នៅ ក្នុង ដៃ បរទេស : យួន ចិន ចាម ជ្វា* › ។

គំនន់ (ការសង្កេត) ដ៏ អប្បិយ បែប នេះ មាន នៅ ក្នុង សៀវភៅ ‹ទំលាប់ និង ទំនៀម នៃ ខ្មែរ› បោះពុម្ព ផ្សាយ នៅ ឆ្នាំ

១៩៣៨ សរសេរ ដោយ លោក និង លោកស្រី ហ្គីប៉ូរ៉េ និង អេវ៉ីលីន ម៉ាស្ប៉េរ៉ូ[68] មាន សេចក្ដី ដូច ត ទៅ : « *ខ្មែរ ទាំងឡាយ ដែល ថា លូតលាស់ ច្រើន តែ មិនសូវ ប្រាជ្ញា មិនសូវ ចេះដឹង អ្វី ទេ ហើយ ឥត យក ចិត្ត ទុកដាក់ លើ អ្វី ទាំងអស់។ តាម ពាក្យ និយាយ របស់ សិស្ស ក្មេង ម្នាក់ នៃ វិទ្យាល័យ ស៊ីសុវត្ថិ ថា ‹ មួយ ពួក ជា ក្របី អត់ឃ្លាន › ដែល ស៊ី ប្រទេស ឯង, ‹ មួយ ពួក ទៀត ជា ពពែ ល្ងីល្ងើ › ដែល ចេះ តែ ស្រែក តែពីសតែពាស ឥត ដឹង ខុស ត្រូវ។ ពួក ទី១ បើ ខ្លួន មាន បង ប្អូន ឬ អ្នក គាំពារ ធំ បាន មុខ ងារ ‹ខ្លាញ់› ជា អ្នក រាជការ ហើយ ទាញ យក កំរៃ អោយ អស់ ពី ដៃ។ យឺតស្លឹក ប្រាជ្ញា ទាល ប៉ុន្តែ ស្នាន តែ ខ្លួន វៃ ឆ្លាត, ពួក នេះ មើលងាយ ជូនកាល ជនជាតិ អ៊ឺរ៉ុប ក្នុង នាម នៃ ប្រពៃណី អាថ៌កំបាំង អ្វី ម្យ៉ាង ដែល យើង ទៅ មិន ដល់ ឡើយ ហើយ ដែល នៅ ក្រោយ នោះ គេ លាក់បាំង ការល្ងង់ខ្លៅ របស់ គេ ជូនកាល ដល់ បង ប្អូន រួម ជាតិ ឯង ដែល គ្នា ក្រីក្រ ហើយ មិន លូតលាស់។ សារៈសំខាន់ ចំពោះ អស់ លោក ទាំង នេះ គឺ មិន បាច់ ធ្វើ អ្វី មាន ឋានន្តរសក្តិ មួយ (បណ្ណទូត ក្នុង រដ្ឋការ សឹង តែ ជា ងារ អភិជន មួយ ហើយ) វាយ ឫក ‹ ពូជ អង្គរវត្ត › នៅ មុខ ពួក អ៊ឺរ៉ុប ធ្វើ ត្រាប់ តាម ជនជាតិ អ៊ឺរ៉ុប ដើម្បី អោយ អ្នក នៅ ក្រោម បង្គាប់ ខ្លួន កោត ហើយនឹង ស្ទាប អង្អែល សន្លឹក ប្រាក់ នៅ គ្រប់ ពេលណា បើក ឱកាស*

[68] Guy Porée et Evelyne Maspero, Mœurs et coutumes des Khmèrs : origines, histoire, religions, croyances, rites, évolution, Payot, Paris, 1938.

*អោយ។ ត្រង់ កន្លែង នេះ ពួក នេះ ធ្វើ តាម ប្រពៃណី មួយ យ៉ាង ចាស់ យូរ មក ហើយ  ហើយ ខ្ញុំ យល់ ថា កិច្ចការ នៃ ជីដូនជីតា ពួក នេះ ក្នុង សម័យអង្គរ នៅ ត្រឹម តែ ត្រង់ ភារៈ យ៉ាង ធ្ងន់ នៃ អ្នក ទា លុយ។ ‹ ក្រុម ទី២ ពួក ពាំពែ ដែល មាន ចំនួន ធំ ជាង គេ មាន ច្រើន តែ ជា អ្នក រងគ្រោះ។ ពិត ហើយ ពួក នេះ ចង់ បាន ជោគជ័យ  ដូច ពួក ទី១ ដែរ ប៉ុន្តែ គ្នា ដឹង ខ្លួន ថា អស់ កម្លាំង ពេក ដើម្បី ទៅ ដល់ ទី នោះ រួច។ តាម សំដី ពួក នេះ ការខិតខំ នៃ ជីដូនជីតា ខ្លួន ដែល ជា ជាង (កសាង អង្គរ) និង ជា អ្នក ច្បាំង បាន ធ្វើ អោយ ខ្លួន ហេវហើវហៃ។ ខ្លួន មិនអាច ទៅ ជា វេជ្ជបណ្ឌិតកើត ទេ - សាស្ត្រាចារ្យ ក៏ មិនកើត - គិលានុបដ្ឋាក ក៏ មិនកើត - អ្នក ជំនួញ ក៏ មិនកើត - និយោជិក ក៏ មិនកើត - កម្មករ ក៏ មិនបាន - អ្វី ក៏ មិនបាន ដែរ ក្រៅ ពី នាម៉ឺន ឬ មួយ បណ្ណទូត ›។*

ចំណែក លោក ប៉ូល ឌូមែរ គូវែរន័រ[69] ហ្សេណេរ៉ាល់  នៃ ឥណ្ឌូចិន ពីឆ្នាំ ១៨៩៧ ទៅ ១៩០២ បាន សរសេរ រហូត ដល់ ការជេត្លះ ដល់ ជនជាតិ ខ្មែរ តែ ម្តង ក្នុង សៀវភៅ មួយ ឈ្មោះ ‹ឥណ្ឌូចិន

[69] Joseph Athanase Doumer, dit Paul Doumer, né le 22 mars 1857 à Aurillac (Cantal) et mort assassiné le 7 mai 1932 à Paris, est un homme d'État français. Il est président de la République du 13 juin 1931 au 7 mai 1932. Entré en politique comme radical, il s'éloigne de la gauche à partir de la fin des années 1890. Il est élu plusieurs fois député entre 1888 et 1910, alternativement pour l'Aisne et l'Yonne. Partisan du colonialisme, il occupe de 1897 à 1902 la fonction de gouverneur général de l'Indochine française, dont il assainit les finances publiques et où il lance d'importants travaux, notamment le Trans indochinois et le chemin de fer du Yunnan.

បារាំង› ចេញ នៅ ឆ្នាំ ១៩០៥ ដែល មាន សេចក្តី ថា : « តើ សាសន៍ ខ្មែរ នេះ មាន នៅ សល់ ទេ ? សាសន៍ នេះ បាន ឃើញ ការ ចុះអាប់អោន នៃ ខ្លួន ទេ ? ជនានុជន កម្ពុជា សព្វថ្ងៃ តើ សៀម ជា កូន របស់ ខ្លួន ឬទេ ? មិនមែន ទេ។ ពួក អ្នក ឈ្នះ មិន នៅ ត្រឹម តែ យក ទ្រព្យសម្បត្តិ ទេ គេ បាន ទាំង កំទេច សាសន៍ នេះ លប់ ចេញ ពី បញ្ជី មនុស្ស រស់។ ភស្តុតាង គឺ នៅ ក្នុង ជនានុជន កម្ពុជា គ្មាន សល់ ប្រពៃណី អ្វី មួយ អនុស្សាវរីអ្វី បន្តិច នៃ ភាសា ខ្មែរ។ យើង បាន ឃើញ ពួក នេះ ឈរ ជា ទស្សនិកជន ព្រងើយ កន្តើយ និង ឥត យល់ អ្វី នៅ មុខ អច្ឆរិយភាព នៃ ស្ថាបត្យកម្ម បុរាណ ឥត ដឹង យល់ អ្វី ទាំងអស់ អំពី អក្សរចារឹក លើ ថ្ម នៃ សំណង់ ប្រាសាទ ដ៏ ឆ្នើម ទាំង នេះ, គឺ ជា បរទេស ដូច យើង ដែរ ចំពោះ មុខ មនុស្ស ដែល រស់នៅ ក្នុង ទី នេះ មុន ខ្លួន ក្នុង ជីវិត មួយ ដែល ខ្ពស់ ជាង។ គ្មាន ប្រជាជន ណា មួយ ឡើយ ហើយ សឹង តែ គ្មាន បុគ្គល ណា ម្នាក់ ផង ដែល អាច អួត ខ្លួន ថា មាន ពូជ អំបូរ ជា ខ្មែរ។ ករណី ជាតិ ខ្មែរ នៅ អាស៊ី គឺ ដូច ជា ករណី ជាតិ ក្រិក និង រ៉ូម៉ាំង នៅ អ៊ឺរ៉ុបដែរ។

សេចក្តីស្លាប់ បាន ផ្តាច់ ជីវិត មនុស្ស ទាំងឡាយ ដែរ ក្នុង ពេល ជា មួយ គ្នា ដែល ខ្លួន បាន ផ្តាច់ ជីវិត ប្រជាជាតិ ទាំងពូង។ ក៏ ប៉ុន្តែ មាន ភូមិពីរ ដ៏ ឆ្ងាយ ពី គ្នា ដាច់ ស្រយាល ក្នុង កម្ពុជា កប់បាត់ ក្នុង ព្រៃស្រោង ជំ ចូល មិនចុះ ដែល មាន បណ្តាជន ក្នុង សាសន៍ មួយ ខុស ពី សាសន៍ កម្ពុជា ហើយ ដែល និយាយ

*ភាសា បុរាណ លែង ពីរោះ អស់ហើយ រឃើករឃាក អស់ហើយ ប៉ុន្តែ ដែល គេ ស្គាល់ ភ្លាម។ តើ មនុស្ស ក្រុម តូច នេះ មាន ខ្មែរ ដ៏ ឧត្តម ជា បុព្វការី ឬ ? ការណ៏ នេះ អាច ពិត ដែរ។ គ្រួសារ មួយ ពីរ បី មិន ដឹង ប្រហែល ជា បាន ផុត ខ្លួន ពី ការបំផ្លេច បំផ្លាញ ដែល បាន ត្រូវ ធ្វើ ឡើង កាល ពី ប្រាំ ប្រាំមួយ សតវត្ស រ៏ មុន ហើយ នៅ រស់រាន មាន ជីវិត បន្ទាប់ ពី បាន គៀស ខ្លួន ទៅ នៅ ទី ដំបន់ ព្រៃភ្នំ ហើយ បន្ត ពូជ រៀងរហូត មក ក្នុង ភាពគោកយ៉ាក និង ភាពអាប់អោន នៃ ការភ័យខ្លាច ជា និច្ច និរន្តរ៏។ តើ មនុស្ស រហេមរហាម ទាំង នេះ ជា កូន អ្នក ចំបាំង ដ៏ហំ ជា កូន នៃ សិល្បករ ដ៏ ឧត្តម នៃ រាជាណាចក្រ ដែល រលាយ បាត់ នោះ ឬ ? ការណ៏ នេះ អាច ពិត ដែរ។ ប៉ុន្តែ បើ ដូច្នេះ មែន មិន ដឹង ជា ឱពុក ខ្លួន ដែល មើល ឃើញ កូន ពី លើ ឋានសួគ៏ ព្រះពុទ្ធ នោះ ឈឺ ចិត្ត ចុកចាប់ ក្នុង ខ្លួន យ៉ាង ណា ទេ, ច្បាស់ ជា គាត់ ចង់ អោយ ការសម្លាប់ រង្គាល (ដែល បាន យក ជីវិត គាត់ នោះ) កុំ ទុក កូន គាត់ អោយ នៅ សល់ ម្នាក់ ជាជាង ទុក អោយ សល់ លើ ដី នូវ អនុស្សាវរីយ៏ របស់ គាត់ របៀប នេះ អោយ សល់ ដំបូន្មាន របៀប នេះ ដល់ ប្រជាជន ទាំងឡាយ ដែល បោះបង់ ខ្លួន ចោល»*។ (ដក ស្រង់ ចេញ ពី ឯកសារ របស់ លោក ចាន់ ដារា និង ប៉ែន នារី - កម្ពុជា និង សហព័ន្ធ ឥណ្ឌូចិន, បោះពុម្ភផ្សាយ នៅ ទីក្រុង ម៉ុងរេអាល ប្រទេស កាណាដា នៅ ឆ្នាំ ១៩៨៣)។

ការពិនិត្យកត់ត្រា ខាង លើ ច្បាស់ ជា ធ្វើ ឱ្យ ចិត្ត ខ្មែរ មាន ការ ក្រៀមក្រំ និង មាន កំហឹង អាច ទុក ជា គហារ[70] ដល់ ជាតិ សាសន៍ ខ្មែរ តែ ត្រូវ យើង ដែល ជា ខ្មែរ កុំ ភ្លេច ថា ពួក អ្នកប្រាជ្ញ បារាំង សែស ទាំង នោះ សុទ្ធ ជា អតីត គ្រូ និង ជា អ្នក ដឹកនាំ ជាតិ ខ្មែរ នៅ រាជ្យបារាំង ត្រួតត្រា ខ្មែរ ហើយ ដែល គេ មើល ឃើញ គម្លាត វា ធំ ក្រៃ ពេក រវាង រូបភាព ខ្មែរ នា បច្ចុប្បន្នកាល និង រូបភាព នៃ ប្រាសាទ ខ្មែរ ពី អតីតកាល, ក្បួន ប្រពៃណី គ្រប់សព្វ នូវ ច្បាប់ ស្ទើរ គ្រប់ វិស័យ ជា ច្រើន ដែល នាំ ឱ្យ ពួក គេ ទ្រាំ មិន អាច នឹង និយាយ ស្ដីពី អរិជ្ឋា របស់ ខ្មែរ នៅ លើ កំនរ ភាពសម្បូណ៌ នៃ វប្បធម៌ របស់ ខ្លួន។ សួរ ថា តើ សំណេរ ទាំងនោះ ជា ការតិទៀន ឬ ជា ការរំពុក ? ចម្លើយ វា នៅ លើ ទឹកចិត្ត របស់ ខ្មែរ ម្នាក់ៗ ដែល យល់ឃើញ អំពី ការពិត ឬ ការមិនពិត នៅ ក្នុង សំណេរ ទាំងនោះ។ បើ ថា វា ជា ការមិនពិត ត្រូវ ចាំបាច់ រក សេចក្ដីសំអាង មក ការពារ ជា ប្រតិនិក្ខេបបទ។ ពុំនោះសោត វា គ្រាន់ តែ ជា ការជំទាស់ ក្នុង អារម្មណ៍ ក្រែវក្រោធ តែ ប៉ុណ្ណោះ។

នៅ ក្នុង ការសាកល្បង ពិចារណា របស់ យើង យើង មិន លើក យក ការកែទម្រង់ ជា ច្រើន នៅ សម័យ អង្គរ ក្ដី ក្រោយ សម័យ អង្គរ ក្ដី មក សិក្សា ជា ពិស្ដា នោះឡើយ ព្រោះ នៅ ឆ្ងាយ ពី ការ ស្រមើលស្រមៃ របស់ ខ្មែរ យើង ពេក ហើយ ការកែទម្រង់ ដែរ

70 គហារ : ការតិះដៀល។

ធ្លាប់ មាន នៅ ក្នុង សម័យ នោះ ដូចយ៉ាង ការយក លទ្ធិទេវរាជ ជា លទ្ធិ ដឹកនាំ ជាតិ, ការប្តូរ សាសនា ពី ព្រាហ្មណ៍ សាសនា ទៅ ពុទ្ធ សាសនា និង បដិវត្តន៍ របស់ តា ត្រសក់ ផ្អែម វា នាំ មក ពិត នូវ ចិត្តគំនិត ថ្មី សំរាប់ អ្នក ដឹកនាំ តែ មិន ពិត ជា អាច ប្តូរ ជា ជម្រៅ ដល់ ចិត្តគំនិត ខ្មែរ នោះឡើយ។ ហើយ អ្នក ដឹកនាំ ខ្មែរ ច្រើន តែ ទំលាក់ កំហុស ទៅ លើ ប្រជារាស្ត្រ នៅ ពេលណា ខ្លួន ទទួល បរាជ័យ, ដូចយ៉ាង នៅ សម័យ សៀម វាយ បែក បន្ទាយ លង្វែក នៅ ក្នុង ពង្សាវតារ ខ្មែរ ដែល ទុក ជា ប្រវត្តិសាស្ត្រ ជា ផ្លូវការ របស់ ខ្មែរ គេ ច្រើន សង្កត់ ថា សៀម ឈ្នះ ខ្មែរ ដោយសារ រាស្ត្រ ខ្មែរ នាំ គ្នា កាប់ ដើមឫស្សី ដែល ជា របង ធម្មជាតិ សំរាប់ ការពារ បន្ទាយ លង្វែក ដើម្បី រករើស ប្រាក់ ដួង ដែល សៀម គេ បាច នៅ ក្នុង ព្រៃ ឫស្សី ដើម្បី ឱ្យ ខ្មែរ យើង កាប់ បំផ្លាញ របង ការពារ នោះ។ តើ យើង អាច ជឿ បាន ដែរ ឬ ទេ ? រឿង មួយ ទៀត ដែល របប រាជានិយម គេ តែងតែ ទម្លាក់ កំហុស ដល់ ព្រះបាទ ជ័យជេដ្ឋា ទី២ ដែល មាន ព្រះមហេសី ជា កូន ស្រី ស្តេច យួន ហើយ ដោយ ស្រឡាញ់ ព្រះ មហេសី ពេក ក៏ សុខចិត្ត អនុញ្ញាត តាម ការស្នើ របស់ ស្តេច យួន ជា ព្រះសស្សុរោ (បិតាក្មេង) ឱ្យ ទ័ព យួន ចូល មក តាំង ទី ដើម្បី ហាត់រៀន សឹក នៅ ខេត្ត ព្រៃនគរ ផ្សិត នគរ យួន កំពុង ច្បាំង នឹង ចិន។ តែ មិន បាន បង្ហាញ ថា នៅ ក្នុង រជ្ជកាល របស់ ព្រះអង្គ ទ្រង់ បាន ទប់ទល់ នឹង ការវាយលុក យ៉ាង ធំ ពី សំណាក់ សៀម បី ដង តែ ច្បាំង មិន ឈ្នះ ខ្មែរ។ ចំពោះ របប

រាជានិយម ដើម្បី វៀរចាក ទទួល ខុសត្រូវ លើ ការបាត់បង់ ទឹកដី កម្ពុជា ក្រោម គឺ គេ យក ព្រះបាទ ជ័យជេដ្ឋា ទី២ ជា និមិត្តរូប នៃ កំហុស ក្នុង ឋានៈ ជា បុគ្គល តែ មិនមែន ជា របប រាជានិយម នោះឡើយ។

លោក ឧត្តមសេនីយ Douglas MacArthur ដែល ជា អ្នកត្រួតត្រា ប្រទេស ជប៉ុន ពី ឆ្នាំ ១៩៤៥ ដល់ ១៩៥២ លោក មាន គោលគំនិត ថា រាជានិយម នៅ ប្រទេស ជប៉ុន ជា ប្រពៃណី មិនមែន ជា ប្រព័ន្ធ ដឹកនាំ នោះទេ, ដូច្នេះ វា មិន ចាំបាច់ ដូរ របប រាជានិយម នោះឡើយ គឺ ត្រូវ ដូរ តែ របប ដឹកនាំ ដែល វា នឹង នាំ ដូរ ចិត្តគំនិត នៃ ប្រជាពលរដ្ឋ ជប៉ុន។ ដូច្នេះ លោក បង្កើត របប រាជានិយម អាស្រ័យ រដ្ឋធម្មនុញ្ញ ដែល មាន ប្រព័ន្ធ ដឹកនាំ គឺ លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស។ វិធានការ នេះ គឺ លោក ភ្នង់ ទៅ លើ ការកែទម្រង់ ចិត្តគំនិត ដែល លោក យល់ឃើញ ថា វា ជា ការបើក ទ្វារ សេរីភាព ដែល ជា ចលករ នៃ បញ្ញា ដែល ជនជប៉ុន មាន រួចហើយ។ លោក ទុក ប្រពៃណី ជា មូលដ្ឋាន គ្រឹះ សំរាប់ ទ្រទ្រង់ ចលនា នៃ បញ្ញា ដែល មាន ដំណើរ ជា ល្បឿន ទៅ មុខ ជា និច្ច។ ដូច្នេះ ដំណើរ នេះ ត្រូវការ មាន កន្លែងក្រិត សំរាប់ វាយ តម្លៃ នៃ ការជឿនលឿន របស់ ខ្លួន នៅ លើ របស់ ពិត មួយ ដែល ប្រជាជាតិ មួយ មាន សំរាប់ ខ្លួន ហើយ ជា របស់ ខ្លួន ផ្ទាល់។ ដូច្នេះ អត្តភាព ពិត របស់ ជាតិសាសន៍ ជប៉ុន គឺ ប្រពៃណី នោះ ឯង។

គតិ នេះ វា ក៏ មាន នៅ ក្នុង ចិត្តគំនិត ខ្មែរ តាំង ពី បុរាណ កាល មក, ដូចយ៉ាង ការកែទម្រង់ វប្បធម៌ ឥណ្ឌា ដែល ហូរ ចូល មក ស្រុកខ្មែរ ឱ្យ ក្លាយ ជា វប្បធម៌ មហា នគរ ដែល មាន មូលដ្ឋាន ដើម ខ្មែរ ជា សសរ ទ្រទ្រង់។ ចំណុច នេះ ដែល លោក កេង វ៉ាន់សាក់ គាត់ លើក មក បញ្ជាក់ ប្រកប ដោយ គំនិត មមៃ ថា វា ជា ការពិត។ តែ បញ្ញជន ខ្មែរ ទាំងឡាយ បែរ ជា នាំ គ្នា តែ សញ្ជឹងគិត យក សំណង់ ប្រាសាទ ទាំងឡាយ ជា និមិត្តរូប ចម្បង នៃ អត្តភាព នៃ បញ្ញា ខ្មែរ មិន នាំ គិត ដោយ សួរ ថា តើ សំណង់ ទាំងនោះ វា មាន ប្រយោជន៍ អ្វីខ្លះ ដល់ ការរស់នៅ របស់ ប្រជារាស្ត្រ ខ្មែរ ? ត្រូវ ខ្មែរយើង ពិចារណា ថា សៀម និង យួន គេ គ្មាន ប្រាសាទ ដូច ខ្មែរ នោះឡើយ តែ ប្រជាជាតិ របស់ គេ មាន ការវិវត្តន៍ វិជ្ជមាន ផ្ទុយ ពី ប្រជាជាតិ ខ្មែរ។ យើង មាន មតិ បែប នេះ មិនមែន មាន សេចក្តី ថា ខ្មែរ មិន ត្រូវ មាន មោទនភាព លើ ប្រាសាទ បុរាណ ដ៏ ល្អ ត្រចេះ ត្រចង់ នោះឡើយ តែ ខ្មែរយើង ត្រូវ មាន គំនិត ស្វែង រក ការ ពិត លើ អ្វី ដែល ខ្មែរយើង ទុក ជា ខ្លឹមសារជាតិ នៃ ប្រជាជាតិ ខ្លួន។

### ដាន នៃ កំណែទម្រង់ នាពេល កន្លងមក

នៅ ស្រុកខ្មែរ នៅ សម័យ អាណាព្យាបាល បារាំង សែស (១៨៦៣-១៩៥៣) ដែល បារាំង គេ ទុក ជា ការសង្គ្រោះ ខ្មែរ ពី ការរុលចូល នៃ ប្រទេស សៀម និង យួន ចូល មក ក្នុង ទឹកដី

ខ្មែរ ផង និង ការកែទម្រង់ ចិត្តគំនិត ខ្មែរ ផង។ បារាំង ចូល មក ក្នុង ស្រុកខ្មែរ គេ មាន គោលបំណង ជា បេសកកម្ម អរិយធម្មូបនីយកម្ម, សេដ្ឋកិច្ច និង អាណានិគមនិយម។ អរិយធម្មូបនីយកម្ម គឺ ការផ្សាយ សាសនា ផង និង វប្បធម៌ ផង, សេដ្ឋកិច្ច គឺ ស្វែង រក ផលប្រយោជន៍ ពី ធនធាន ធម្មជាតិ គ្រប់ បែប យ៉ាង និង អាណានិគមនិយម គឺ ត្រួតត្រា នគរ ទាំងមូល ជា អ្នក ដឹកនាំ។ យើង ឃើញ ថា គោលបំណង បារាំង សែស និង គោលដៅ អាមេរិកាំង វា ខុស គ្នា ឆ្ងាយ ណាស់ តែ សម័យ ក៏ វា ខុស គ្នា ដែរ។ តែ ត្រូវ ដឹង ដែរ ថា អាមេរិក ធ្លាប់ ជា អ្នក រង គ្រោះ នឹង អាណានិគមនិយម ដូច្នេះ អ្នក ដឹកនាំ និង ប្រជាពលរដ្ឋ អាមេរិកាំង ពុំ អាច មាន ចិត្តគំនិត ជា អ្នក ជញ្ជក់ ផលប្រយោជ៍ ទៅ លើ ជាតិសាសន៍ ដទៃ នោះឡើយ។ ហេតុ នេះ ឯង បាន ជា ក្រោយ សង្គ្រាម លោក លើក ទី២, អាមេរិក មិន គាំទ្រ ជា ផ្លូវការ ការបន្ត អាណានិគមនិយម នៃ មស្ជឹមប្រទេស នៅ លើ ពិភពលោក។

តែ បេសកកម្ម បារាំង សែស ក៏ មាន ចំណុច មួយ ខុស ពី អាមេរិកាំង ដែរ គឺ នៅ ក្នុង សន្ធិសញ្ញា អាណាព្យាបាល នៅ ឆ្នាំ ១៨៦៣ បារាំង ត្រូវ ការពារ មហាក្សត្រ ខ្មែរ ជា ដាច់ខាត ដោយ ប្តូរ នឹង ការបោះបង់ រាជ អំណាច នៃ កិច្ចការ បរទេស ទាំង អស់ របស់ ព្រះអង្គ។ ប៉ុន្តែ ការយល់ច្រឡំ រវាង ព្រះបាទ នរោត្តម និង បារាំង វា នាំ បង្កើត បញ្ហា មួយ ចំនួន។ បំណង របស់ ស្តេច ខ្មែរ ទៅ ពឹង បារាំង គឺ ចង់ ឱ្យ បារាំង ជួយ ដណ្តើម ទឹកដី

កម្ពុជា ក្រោម ពី យួន តែ ប៉ុណ្ណោះ ហើយ ព្រះអង្គ ក៏ គ្មាន គំនិត អ្វី ចង់ រើរុះ ទំនាក់ទំនង រវាង ខ្មែរ និង សៀម នោះ ទេ។ តែ ចំពោះ បារាំង គេ យល់ ឃើញ ថា ការពារ គឺ ការពារ ទាំងអស់ ហើយ ឆ្លៀត ឱកាស សើរើ ទំនាក់ទំនង ស្តេច ខ្មែរ និង ប្រទេស សៀម ដែល មាន ឥទ្ធិពល ខ្លាំង មក លើ ស្តេច ខ្មែរ ព្រោះ បញ្ហា ដែល បារាំង គេ អាច នឹង ជួប ប្រទះ ទៅ ថ្ងៃ មុខ គឺ ជា មួយ សៀម ច្រើន ជាង យួន ព្រោះ នៅ ពេល នោះ បារាំង គេ មាន កងទ័ព របស់ គេ មក បោះ ទី នៅ ស្រុកយួន រួច មកហើយ ហើយ ស្រុកសៀម ក៏ ជា ទីដៅ មួយ ដែល បារាំង គេ មាន គោល បំណង ចង់ យក មក ដាក់ នៅ ក្រោម ការត្រួតត្រា របស់ គេ។ តែ នៅ ពេល នោះ បើ គ្មាន ប្រទេស អង់គ្លេស ចេញមុខ ជំទាស់ ហើយ តម្រូវ ឱ្យ ប្រទេស ទាំងពីរ សុខចិត្ត ទុក ប្រទេស សៀម ជា ដំបន់ទ្រា រវាង អាណានិគម អង់គ្លេស និង បារាំង នៅ អាស៊ី ភាគ អាគ្នេយ៍ ដែល ជា កត្តា នាំ ឱ្យ ប្រទេស សៀម មិន ក្លាយ ទៅ ជា ប្រទេស អាណានិគម។ ចំណែក ខាង យួន វិញ បារាំង គេ ការពារ ព្រំដែន ខ្មែរ-យួន គឺ គ្រាន់ តែ សំរាប់ ទប់ ស្កាត់ ពួក បះបោរ យួន ប្រឆាំង នឹង បារាំង នាំ គ្នា រត់ មក ពួន នៅ ស្រុកខ្មែរ។

ពី ឆ្នាំ ១៨៦៣ ដល់ ឆ្នាំ ១៨៨៤ នៅ ស្រុកខ្មែរ នៅ ក្រោម អាណា ព្យាបាល បារាំង សែស, អជ្ញាធរ បារាំង គេ ដើរ តួ ជា ឧបត្ថម្ភក នៅ ក្នុង កិច្ចការ រាជការ ខ្មែរ។ រយៈពេល នោះ ដែល លោក

Alain Forest[71] ឱ្យ ឈ្មោះ ថា រយៈពេល នៃ អ្នក ត្រួសត្រាយ ផ្លូវ (sic)។ អ្វីៗ ដែល ដែល អាជ្ញាធរ បារាំង នៅ ស្រុកខ្មែរ ធ្វើ សេចក្តីរាយការណ៍ ទៅ អគ្គទេសាភិបាល បារាំង នៅ ទីក្រុង ហាណូយ ហើយ ពី ទីក្រុង ហាណូយ ទៅ ប្រធានាធិបតី បារាំង គឺ គេ បង្ហាញ តែ អំពី ឧត្តមភាព នៃ អាណានិគមនិយម ជា រូបភាព នៃ ស្រុកខ្មែរ ជា ប្រទេស និង ប្រជារាស្ត្រ មិនរឹងរូស នឹង អជ្ញាធរ របស់ បារាំង។

ចាប់ ពី ឆ្នាំ ១៨៨៤ បារាំង ចាប់ ផ្តើម ធ្វើ ការកែទម្រង់ នៃ ប្រព័ន្ធ រដ្ឋបាល និង ហេរញ្ញវត្ថុ និង ព្រម ទាំង ដក ចេញ ពី មុខ ដំណែង កុង្សី សេនាបតី ខ្មែរ ដែល មាន ឥទ្ធិពល ទៅ លើ ស្តេច ខ្មែរ និង តែងតាំង មន្ត្រី ខ្មែរ ថ្មី ដែល គេ មើល ឃើញ ថា ជា អ្នក ចុះចូល ទាំងស្រុក នឹង គំនិត កែទម្រង់ របស់ គេ។ ការកែ ទម្រង់ តម្រូវ ឱ្យ មាន ការកែ ចិត្តគំនិត ថ្មី ដូច្នេះ បារាំង គេ បង្កើត សាលា ក្រមការ ដើម្បី បង្ហាត់បង្រៀន អ្នក រាជការ ខ្មែរ ឱ្យ ចេះ វិជ្ជា រដ្ឋបាល តុលាការ ទំនើប, គេ បង្កើត សាលា អប់រំ ថ្មី សំរាប់ បង្រៀន យុវជន ខ្មែរ ឱ្យ ចេះ មុខ វិជ្ជា ទំនើប គ្រប់ វិស័យ វិទ្យាសាស្ត្រ ជាន់ដំបូង និង សំខាន់ៗ ដែល ជា មូលដ្ឋាន សំរាប់ បណ្តុះបណ្តាល ចិត្តគំនិត នៃ តក្កភាព និង វិចារណភាព ដែល ជា សត្រូវ នឹង អបិយជំនឿ។ មែនពិត ការកែទម្រង់ ទាំងឡាយ នោះ វា ជា វិធានការ វិជ្ជមាន ដល់ ប្រជារាស្ត្រ ខ្មែរ

[71] លោក បាន សរសេរ សៀវភៅ មួយ មាន ចំណងជើង ថា Le Cambodge et la colonisation française – Edition L’HARMATTAN - 1980.

ដែល មិន អាច ប្រកែក បាន នោះឡើយ តែ បារាំង គេ ធ្វើ នៅ ក្នុង គំនិត អាណានិគមនិយម គឺថា សំរាប់ បំរើ ផលប្រយោជន៍ នយោបាយ របស់ គេ ច្រើន ជាង ផលប្រយោជន៍ ខ្មែរ ដូច យ៉ាង បង្ខំ ខ្មែរ ឱ្យ ទទួល ស្គាល់ តម្លៃ នៃ អរិយធម៌ បារាំង ថា ជា អរិយធម៌ ប្រសើរ ដាច់ខាត។ ដូច្នេះ ការបណ្តុះបណ្តាល ឱ្យ មាន ចិត្តគំនិត តក្កភាព និង វិចារណាភាព គឺ ធ្វើឡើង នៅ ក្នុង ចិត្តគំនិត ទោល នោះឯង ដែល នាំ បង្កើត វណ្ណៈ អ្នក ចេះ ដឹង ខ្មែរ ថ្មី ដែល ជា វណ្ណៈ កាត់ ផ្តាច់ ពី មូលដ្ឋាន ជាតិ ពិត ប្រាកដ។ បើ និយាយ ខ្លី ឱ្យ ស្រួល យល់ គឺថា ការកែទម្រង់ របស់ បារាំង វា មាន លក្ខណៈ ជា ការយក ចំណេះដឹង ថ្មី មក ប្រជួស នឹង ចំណេះដឹង ខ្មែរ តែ ម្តង។ ដូច លោក បុណ្ណ ចន្ទម៉ុល គាត់ សរសេរ នៅ ក្នុង សៀវភៅ របស់ គាត់ ថា នៅ សម័យ រាជ្យ បារាំង អ្វី ដែល ជា គំនិត បារាំង គឺ ប្រសើរ ជាង គំនិត ខ្មែរ ជា និច្ច សំរាប់ អ្នក ចេះដឹង ខ្មែរ, សូម្បី និយាយ និង អាន ជា ភាសា បារាំង ក៏ ទុក ជា សញ្ញា នៃ ការចេះដឹង នោះដែរ។ នេះហើយ ដែល ជា មរតក ដែល គេ ទុក ឱ្យ ខ្មែរ នៅ ក្នុង រយៈពេល ៩០ ឆ្នាំ នៃ អាណានិគមនិយម បារាំង នៅ ក្នុង ចិត្តគំនិត អ្នក ចេះ ដឹង ខ្មែរ។ តើ ការណ៍ នេះ វា ជា កំហុស របស់ បារាំង ឬ ជា កំហុស របស់ ខ្មែរ ? ជា កំហុស របស់ បារាំង នៅ លើ ចំណុច ថា អ្នក ខ្លាំង ប្រើ កម្លាំង ជិះជាន់ អ្នក ខ្សោយ។ ជា កំហុស របស់ ខ្មែរ នៅ ត្រង់ ថា អ្នក ខ្សោយ ទុក ឱ្យ អ្នក ខ្លាំង ជិះជាន់ ខ្លួន តាម សេរី។ លើ ចំណុច នេះ ឯង ដែល វា ខុស គ្នា ពី ចិត្តគំនិត

អាមេរិកាំង នៅ ពេល គេ ត្រួតត្រា ប្រទេស ជប៉ុន គឺ គេ ធ្វើ នៅ ក្នុង គំនិត ជួយ ប្រជារាស្ត្រ ជប៉ុន ឱ្យ យល់ ដឹង អំពី តម្លៃ វប្បធម៌ ជាតិ របស់ ខ្លួន ដោយ ផ្តល់ សេរីភាព តាម ផ្លូវ លទ្ធិ ប្រជាធិបតេយ្យ ឱ្យ ជនជប៉ុន គិតពិចារណា ដោយ សេរី ដើម្បី កសាង ជោគវាសនា របស់ ប្រជាជាតិ ខ្លួន ដោយ ខ្លួន ឯង, រី ឯ អ្នក ចេះដឹង ជប៉ុន វិញ គេ ឆ្លៀត យក អ្វី ដែល ជា វិជ្ជា ទំនើប មក កសាង ប្រជាជាតិ របស់ គេ នៅ ក្នុង ចិត្តគំនិត ជប៉ុន។ ប្រយោគ ដ៏ ពិស្សត របស់ ជនជាតិ ជប៉ុន នៅ សម័យ នោះ គឺ ‹ ប្រើ បច្ចេកទេស នៃ មស្ទឹមប្រទេស នៅ ក្នុង ចិត្ត គំនិត ជប៉ុន› ដែល ជា ពាក្យ សង្ខេប មួយ ថា ‹បុនក្ការ› (rénovation)។

ការសង្កេត នេះ មិនមែន ជា គំនិត រមិលគុណ ចំពោះ ប្រជាជាតិ បារាំង នោះឡើយ តែ ប្រជាជាតិ បារាំង ក៏ មិនមែន ជា អាណានិគមនិយម នោះដែរ ព្រោះ អាណានិគមនិយម ជា ប្រព័ន្ធ នយោបាយ បង្កើត ឡើង ដោយ មនុស្ស មួយ ក្រុម យក មក អនុវត្ត ដើម្បី បំរើ ផលប្រយោជន៍ អ្វីមួយ ហើយ ប្រព័ន្ធ នេះ គេ អាច ទុក បាន ជា ការវិវត្តន៍ ថយក្រោយ នៃ ដំណើរ នៃ មនុស្សជាតិ ដែល គេ អាច បន្ទោស បាន ហើយ ត្រូវ គេ ផ្តន្ទាទោស តាម ផ្លូវ ចិត្ត ក្រោយ ពី សង្គ្រាម លោក លើក ទី២។ ដូច្នេះ ខ្មែរ មិន អាច អគុណ ប្រព័ន្ធ ប្រឆាំង នឹង មនុស្សជាតិ មួយ ថា ជា ការសង្គ្រោះជាតិ ខ្មែរ បាន នោះឡើយ ហើយ អាណានិគមនិយម បារាំង សែស ក៏ មិន បាន កែទម្រង់ ចិត្តគំនិត

អ្នក ដឹកនាំ ខ្មែរ បន្តិច សោះឡើយ ឬ ផ្តល់ នូវ រូបធាតុ នៃ ចិត្ត គំនិត អ្វីមួយ សំរាប់ យក មក គិត បំភ្លឺ ផ្លូវ កសាង ជាតិ។ តែ ជនខ្មែរ ភាគ ច្រើន ទុក អាណានិគមនិយម បារាំង សែស ជា ជម្រើស ត្រឹមត្រូវ មួយ ដើម្បី ការពារ ប្រជាជាតិ ពី ការ ឈ្លានពាន របស់ បរទេស សៀម និង យួន។ ពិតណាស់ បារាំង គេ មិន បាន លុបបំបាត់ ចោល អំណាច ផ្តាច់ការ របស់ របប រាជានិយម តែ គេ បាន ធ្វើ ឱ្យ មាន ការរីកចំរើន មួយ ចំនួន នៅ ក្នុង សង្គម ខ្មែរ ដូចយ៉ាង នៅ ក្នុង វិស័យ សុខាភិបាល សា ធារណៈ, ហេដ្ឋារចនាសម្ព័ន្ធ, ជំរឿន នៃ បុគ្គល តាម ប្រព័ន្ធ នៃ ការអប់រំ ជាតិ បែប ទំនើប និង ការយល់ដឹង អំពី តម្លៃ នៃ ប្រជាជាតិ តាម ការស្រាវជ្រាវ រក ឃើញ អរិយធម៌ រុងរឿង របស់ ជាតិ សាសន៍ ខ្មែរ នៅ សម័យ មហា នគរ។

ក្រោយ ពី ស្រុកខ្មែរ ទទួល បាន ឯករាជ្យ ជាតិ ពេញលេញ នៅ ឆ្នាំ ១៩៥៣ និង បន្ទាប់ ពី ការសាកល្បង អនុវត្ត ប្រព័ន្ធ នៃ លទ្ធិប្រជាធិបតេយ្យ ចាប់ ពី ឆ្នាំ ១៩៤៦ នៅ ក្រោម ទម្ងន់ នៃ ចិត្តគំនិត ហួសសម័យ។ សព សម្តេច សីហនុ ទ្រង់ ប្រើ មធ្យោបាយ គ្រប់ បែបយ៉ាង ដើម្បី បញ្ចប់ ដំណើរ នៃ លទ្ធិប្រជា ធិបតេយ្យ សេរី ពហុបក្ស នៅ ស្រុកខ្មែរ ដោយ បង្កើត ប្រព័ន្ធ នយោបាយ ថ្មី មួយ ដែល ព្រះអង្គ យល់ឃើញ ថា ជា ប្រព័ន្ធ ងាយយល់ សំរាប់ ប្រជារាស្ត្រ, ព្រះអង្គ ប្រទាន នាម ថា ‹ចលនា សង្គមរាស្ត្រនិយម› ដែល មិនមែន ជា ចលនា នយោបាយ។ ន

យៈវិទូ[72] បរទេស ខ្លះ ទុក ការបង្កើត នេះ ជា ដំណាក់ការ អន្តរការ នៃ ការកែទម្រង់ នៃ ប្រព័ន្ធ នយោបាយ ខ្មែរ ទៅ រក លទ្ធិប្រជាធិបតេយ្យ។ បញ្ញាជន ខ្មែរ ច្រើន ទុក ដំណាក់ការ អន្តរការ នេះ ថា ជា ផ្លូវ កណ្ដាល គឺ ជា ការផ្សំ រវាង លទ្ធិប្រជាធិបតេយ្យ សេរី នៃ មស្ចឹមប្រទេស និង លទ្ធិសង្គមនិយម ឬ កុម្មុយនិស្ដ នៃ ពួក ប្រទេស នៃ លោក ខាង កើត ឬ ជា សំយោគ រវាង លទ្ធិប្រជាធិបតេយ្យ សេរី, សង្គមនិយម និង ប្រពៃណី ជាតិ។ តាមការពិត សព សម្ដេច សីហនុ ព្រះអង្គ យក គំនិត តាម គំរូ នៃ ប្រទេស បី គឺ ប្រទេស យូហ្គោស្លាវី, អ៊ីស្រាអែល និង ចិនប្រជាមានិត មក ធ្វើ ជា សំយោគ។ តែ មូលដ្ឋាន នេះ វា មិន អាច បង្កើត បាន ជា ឧត្តមគតិ នយោបាយ មាំមួន និង អាច យក វា មក អនុវត្ត នៅ ក្នុង សកម្មភាព របស់ រដ្ឋាភិបាល ឱ្យ ត្រូវ នឹង បញ្ហា ជាតិ ខ្មែរ ពិត ប្រាកដ។ តែ គេ អាច យល់ព្រម បាន ថា ប្រជាធិបតី វា ជា ទម្រង់ មួយ នៃ ការរៀបចំ នៃ អំណាច នយោបាយ ទៅ រក ការរកឃើញ អត្តសញ្ញាណ (identification) នៃ ការរួបរួម រវាង អ្នក ដឹកនាំ និង ប្រជារាស្ត្រ សំរាប់ អនាគត ដែល ទុក ជា គតិបណ្ឌិត មួយ ដែល ត្រូវ តែ ធ្វើ ឱ្យ សំរេច បាន ជា ចាំបាច់។ គោលដៅ នេះ ឯង ដែល តម្រូវ ឱ្យ មាន ការរីកចំរើន គ្មានកំរិត និង វឌ្ឍនកម្ម មិន ចេះ ឈប់ ដើរ ទៅ រក សង្គម ដ៏ ល្អ មួយ ដែល ប្រជាជាតិ ប្រាថ្នា ចង់ បាន។ ការរកឃើញ អត្តសញ្ញាណ នេះ ដែល ព្រះបាទ ជ័យវរ្ម័ន ទី៧ (១១៨១-

[72] នយ់វិទូ : នយោបាយវិទូ ; politicologue។

១២១៨) ត្រាស់ ឱ្យ ចារ ពាក្យ ស្លោក ថា ‹ទុក្ខ របស់ ប្រជារាស្ត្រ ជា ទុក្ខ របស់ ព្រះមហាក្សត្រ ផ្ទាល់›។ ប៉ុន្តែ ចិត្តមេត្តា របស់ ព្រះអង្គ មិន អាច ខាឃាំង មិន ឱ្យ មហា នគរ ខ្មែរ រលំ បាន នោះឡើយ ព្រោះ ចិត្តមេត្តា វា មិន ឆ្លើយ ត្រូវ នឹង បញ្ហា ពិត របស់ ប្រជាជាតិ ខ្មែរ នៅ សម័យ នោះ ដែល លោក ប៊ុន ចន្ទម៉ុល កត់ សំគាល់ នៅ ក្នុង សៀវភៅ របស់ គាត់ ថា បញ្ហា ដែល នាំ ឱ្យ ប្រជាជាតិ ខ្មែរ ខូះ ការរួបរួម នៅ ក្នុង សង្គម គឺ បញ្ហា ចរិត របស់ ខ្មែរ តែ ម្តង។

ចរិត គឺ ចិត្តគំនិត, មិន អញ្ចឹង ទេ ? ចិត្តគំនិត នយោបាយ នៃ ប្រជាជន វា អាច ជា ចិត្តគំនិត បង្កើត ឬ បំផ្លាញ, ជា គំនិត ដុះដាល ឬ គំនិត ខ្សត់ខ្សោយ ដែល វា បញ្ចាំង ចេញ មក ក្រៅ ជា រូបភាព វិជ្ជមាន ឬ អវិជ្ជមាន របស់ ប្រជាជាតិ។ ហើយ យើង ដឹង ថា កម្លាំង ខ្លាំងក្លា របស់ ប្រជាជាតិ គេ អាច វាស់ វា បាន តែ ឱនភាព របស់ វា វិញ វា គ្រាន់ តែ មាន នៅ ក្នុង អារម្មណ៍ តែ ប៉ុណ្ណោះ, ហើយ នៅ ពេល ដែល ប្រជាជាតិ រលាយ ឬ ធ្លាក់ ខ្លួន ជា ខ្ញុំ បរទេស ទើប ដឹង ថា វា យឺត ពេល ទៅ ហើយ។ បាតុភូត បែប នេះ ឯង ដែល មាន កើត ឡើង នៅ សម័យ មហា នគរ ខ្មែរ។ សួរ ថា តើ បុព្វបុរស ខ្មែរ បាន ធ្វើ អ្វី ខ្លះ ដែល អាច ឱ្យ បាតុភូត បែប នេះ អាច កើត មាន បាន ដល់ ស្រុកខ្មែរ ? ត្រូវ ដឹង ថា ប្រសិន បើ ខ្មែរយើង លើក យក លទ្ធផល ជា មរតក ដែល បុព្វបុរស យើង ទុក ឱ្យ មក ពិចារណា យើង ក៏ អាច និយាយ បាន ថា គាត់ ក៏ ជា អ្នក កសាង

ប្រាសាទ អច្ឆរិយៈ ទាំងឡាយ ហើយ គាត់ ក៏ ជា អ្នក បោះបង់ ប្រាសាទ ទាំងនោះ ចោល នៅ កណ្ដាល ព្រៃស្បាត នោះដែរ ដែល ក្លាយ ទៅ ជា ទីស្ថាន ដែល ធម្មជាតិ យក មក ធ្លាក់ ជា បូរី ថ្មី សំរាប់ ទេពារក្ស ធ្វើ ជា ពនាល័យ[73] ក្រោយ ពី ពួក អាទិទេព និង ទេព្ដា នាំ គ្នា ចាកចេញ ដោយ គ្មាន អាល័យ ព្រោះ នាំ គ្នា យាង តាម ព្រះបាទ ពញា យាត (១៣៨៤-១៤២៧) នៅ ឆ្នាំ ១៣៩២ ទៅ សាង រាជធានី ថ្មី នៅ ស្រុក បាសាន (ស្រុក ស្រីសន្ធ បច្ចុប្បន្ន)។ ការផ្ទេរ រាជធានី នេះ វា ដៅ ជា ទស្សនៈ ថ្មី នៃ យុទ្ធសាស្ត្រ ការពារ ជាតិ របស់ អ្នក ដឹកនាំ ខ្មែរ នៅ ចំពោះមុខ នយោបាយ វាត ទឹកដី របស់ នគរ សៀម, គឺថា ឱ្យ អាទិភាព ដាច់ខាត ទៅ លើ ការទប់ទល់នឹង ការវាយ ប្រហារ របស់ សត្រូវ នៅ ក្នុង ផ្ទៃក្នុង នៃ នគរ ដែល ជា យុទ្ធសាស្ត្រ បោះបង់ ការ ការពារ ព្រំដែន ជាតិ។ យុទ្ធសាស្ត្រ នេះ វា មាន អនុភាព អវិជ្ជមាន ព្រោះ សៀម គេ មក ធ្វើ សង្គ្រាម នៅ ក្នុង ស្រុកខ្មែរ តាម តែ ចិត្ត គេ ចង់ ព្រោះ ខ្មែរ បើក ចំហរ ព្រំដែន ឱ្យ គេ ចូល បាន យ៉ាង ងាយស្រួល, ហើយ មាន សង្គ្រាម ម្ដងៗ តែង តែ នាំ ទុក្ខ វេទនា ដល់ ប្រជារាស្ត្រ ខ្មែរ ក្រៃលែង។ នេះ ជា ចិត្ត គំនិត របស់ អ្នក ដឹកនាំ ខ្មែរ នៅ សម័យ នោះ ដែល យក គំនិត សាមញ្ញ មក ដោះស្រាយ មិស្ស បញ្ហា (problème complexe)។

[73] ពនាល័យ : លំនៅក្នុងព្រៃ។

ក៏ ដូច សព សម្តេច សីហនុ ព្រះអង្គ យក ចលនា សង្គមរាស្ត្រនិយម ជា ដំណោះស្រាយ សាមញ្ញ ដែល ព្រះអង្គ យល់ឃើញ ដោយ មាន ជំនឿ ថា រាស្ត្រ ងាយ យល់ បាន មក ដោះស្រាយ មិស្ស បញ្ហា របស់ ប្រជាជាតិ ខ្មែរ។ មែនទែន ទ្រឹស្តី នៃ សង្គមរាស្ត្រនិយម វា អាច ជា ដំណោះស្រាយ មួយ សំរាប់ រយៈពេល មួយ នៅ បរិបទ មួយ គឺ ការប្រមូល កម្លាំង ជាតិ ដើម្បី បំរើ ប្រយោជន៍ ជាតិ ដែល វា នាំ ឱ្យ សង្គមរាស្ត្រនិយម ទទួល បាន ជោគជ័យ មួយ រយៈ ដែល គ្មាន នរណា អាច ប្រកែក បាន។ តែ វឌ្ឍនកម្ម របស់ សង្គមរាស្ត្រនិយម វា គ្មាន ការកែទម្រង់ នៃ ចិត្តគំនិត ជា ជម្រៅ នៃ ពពួក អ្នក ដឹកនាំ ជាតិ វា នាំ ទាញ ចលនា នោះ ឱ្យ វិលត្រឡប់ មក រក ទម្លាប់ ចាស់ គឺ អំណាច ផ្តាច់ការ ព្រោះ វា ជា របស់ សាមញ្ញ ហើយ ងាយស្រួល សំរាប់ ប្រព្រឹត្ត អំពើ ជិះជាន់ ដល់ មនុស្ស។ សង្គមរាស្ត្រនិយម ជា មធ្យោបាយ សំរាប់ ធ្វើ អភិវឌ្ឍន៍ ជាតិ ក៏ វា ក្លាយ តាម បែប នេះ ទៅ ជា ឧបករណ៍ នយោបាយ ផ្តាច់ការ របស់ សព សម្តេច សីហនុ។ តែ វា គ្មាន អ្វី ជា ការចម្លែក នោះឡើយ ព្រោះ វា ស្ថិត នៅ ក្នុង ការប្រតិបត្តិ និង ចិត្តគំនិត របស់ ខ្មែរ តាំង ពី អតីតកាល មក ម្លេះ ដែល ជា ចិត្តគំនិត នៅនឹងមួយកន្លែង។

មក ដល់ សម័យ ដ៏ខ្លីមួយ នៃ របប សាធារណរដ្ឋ ខ្មែរ ចិត្តគំនិត នេះ វា មិន បាន កម្រើក នោះឡើយ ទោះបី មាន បំណង ល្អ ពី សំណាក់ របស់ ពួក អ្នក ដឹកនាំ ថា នឹងនាំ គ្នា កែ ចិត្តគំនិត ខ្មែរ តាម ការប្តូរ របប រាជានិយម មក ជា របប សាធារណរដ្ឋ។

សួរ ថា តើ សង្គ្រាម វា ធ្វើ ឲ អាក់ខាន នៃ ការកែទម្រង់ នោះ ? យក សង្គ្រាម មក ធ្វើ ជា លេស វា មិន ត្រឹមត្រូវ នោះឡើយ។ ផ្ទុយ ទៅ វិញ សង្គ្រាម ការពារ ជាតិ នោះឯង ដែល ពួក អ្នក ដឹកនាំ ត្រូវ ចាំបាច់ ធ្វើ ការកែទម្រង់ នោះ ឱ្យ បាន ជា ដាច់ ខាត ព្រោះ ជា កត្តា សំខាន់ មួយ សំរាប់ យក មក ធ្វើ អាវុធ ចិត្ត ដើម្បី ការពារ ជាតិ ពី ការឈ្លានពាន ពី សំណាក់ ទ័ព យួន កុម្មុយនិស្ត។ នៅ ពេល ដែល ប្រជារាស្ត្រ ខ្មែរ ចាប់ ផ្តើម សួរ ថា តើ សង្គ្រាម នោះ ធ្វើ ដើម្បី អ្នកណា គឺ ពិត ជា ការផ្តើម នៃ បរាជ័យ នោះឯង។

តើ គេ អាច ទុក របប កម្ពុជា ប្រជាធិបតេយ្យ ហៅ ថា របប ខ្មែរ ក្រហម ជា អ្នក កែទម្រង់ ដាច់ខាត នៃ ចិត្តគំនិត អវិជ្ជមាន ខ្មែរ ? ចម្លើយ គឺ ពិត ជា ថា ទេ ព្រោះ របប នេះ នាំ យក លទ្ធិកុម្មុយនិស្ត មក អនុវត្ត ដើម្បី វាយ កម្ទេច សង្គម ខ្មែរ ដើម្បី កសាង សង្គម សិប្បនិម្មិត ថ្មី មួយ ដែល វា គ្មាន ខ្លឹមសារ ជាតិ អ្វី បន្តិច សោះឡើយ។ ពួក បញ្ញាជន ខ្មែរ ក្រហម គេ តែង នាំ គ្នា និយាយ ថា របប របស់ គេ គឺ ផ្អែក លើ មូលដ្ឋាន វិទ្យា សាស្ត្រ ព្រោះ លទ្ធិកុម្មុយនិស្ត ជា វិទ្យាសាស្ត្រ នៃ បដិវត្តន៍ សំរាប់ ប្តូរ របប ដឹកនាំ ដើម្បី កសាង សង្គម កុម្មុយនិស្ត ដែល ជា សង្គម គ្មាន វណ្ណៈ។ តែ ពួក ទាំងនោះ ភ្លេច គិត ថា ការសម្លាប់ មហាជន មិនមែន ជា ការកែទម្រង់ នោះទេ។ ការភាន់ច្រឡំ នេះឯង ដែល នាំ ឱ្យ របប នេះ ទទួល បរាជ័យ មិនត្រឹម តែ ជា បរាជ័យ នៃ របប របស់ ខ្លួន តែ ប៉ុណ្ណោះ ទេ គឺ ថែម ទាំង នាំ

ឱ្យ ប្រជាជាតិ ខ្មែរ ធ្លាក់ ទៅ ក្រោម ការត្រួតត្រា របស់ យួន ដែល ធ្លាប់ ជា មិត្ត រួម អារុជ។ តើ នេះ មិនមែន ជា ភាព ល្ងង់ល្ងើ របស់ ពួក អ្នក ដឹកនាំ នោះ ទេឬ ? នេះ ហើយ ដែល លោក ប៉ុណ្ណចន្ទ ម៉ុល គាត់ ថា ជា ចារិត ស្វា ពាក់ ម្កុដ។

របប ដឹកនាំ បច្ចុប្បន្ន ជា របប លួច គឺ ពួក អ្នក ដឹកនាំ គិត តែ ពី លួច ជាតិ ហើយ នាំ គ្នា ថា ស្រុក មាន សន្តិភាព ហើយ បង្ខំ ឱ្យ ប្រជារាស្ត្រ ខ្មែរ អគុណ ដល់ សន្តិភាព។ សួរ ថា បើ មាន ប្រជាជន យួន រាប់ លាន នាក់ គេ ចូល មក រស់នៅ ក្នុង ស្រុក ខ្មែរ តាម សេរី , ហើយ ព្រំដែន សមុទ្រ ក្តី ទឹកដី ក្តី របស់ ខ្មែរ ត្រូវ យួន បង្ខិត តាម អំពើ ចិត្ត ចូល មក ក្នុង ផ្ទៃដី ខ្មែរ, ហើយ ប្រជាពលរដ្ឋ នាំ គ្នា ចំណាក ស្រុក ទៅ ធ្វើ ការ នៅ បរទេស មាន ចំនួន ដល់ លាន នាក់, សួរ ថា តើ សន្តិភាព អះអាង នោះ ជា សន្តិភាព សំរាប់ អ្នកណា ? មិន នាំ គ្នា កែ ចិត្តគំនិត ពួក អ្នក ដឹកនាំ នាំ គ្នា ពាក់ ងារ វណ្ណអភិជន នៃ របប សក្តិភូមិ ដូច ស្វា ពាក់ ម្កុដ នោះឯង។

### តើ ខ្មែរ អាច ធ្វើ អ្វី បាន ?

យើង វិល ត្រឡប់ មក រក មស្សិ ចិត្តគំនិត (pensées complexes) ដើម្បី ផ្ទះមើល ថា តើ ការកែទម្រង់ នៃ ចិត្តគំនិត វា អាច ធ្វើ នៅ លើ ចំណុច ណា បាន ខ្លះ ? ដូច ពពួក សង្គម វិទូ ខ្លះ យល់ឃើញ ថា ចំណេះដឹង ត្រូវ យល់ ដឹង អំពី ភាព ផ្ទុយ គ្នា មាន តក្កភាព (logique) ដែល យើង ត្រូវ ប្រឈរ មុខ។ :

- សណ្ដាប់ធ្នាប់ ក៏ មាន អសណ្ដាប់ធ្នាប់ (ការច្រឡំបល់) ;
- វិទ្យាសាស្ត្រ បំភ្លឺ ការល្ងង់ខ្លៅ ;
- វប្បធម៌ ក៏ មាន អនារ្យធម៌ នេះ ដែរ ;
- ហេតុផល បរិសុទ្ធ ក៏ វា អាច មិន សមហេតុផល ;
- ហេតុផល និង តណ្ហា ត្រូវ ការ គ្នា ទៅ វិញ ទៅ មក ;
- របស់ តែ មួយ ក៏ មាន អនេកគុណ ផ្ទាល់ ខ្លួន របស់ វា។

ចំណុច ទាំង ៦ ខាង លើ នេះ វា បង្ហាញ ថា អ្វី ដែល យើង យល់ ថា ត្រូវ ក៏ វា អាច ខុស នោះ ដែរ, ដូច្នេះ វា គ្មាន អ្វី ជា ការពិត ដាច់ខាត នៅ ក្នុង ចិត្តគំនិត របស់ មនុស្ស នោះឡើយ។ ដូច បុរាណ ភាសិត ខ្មែរ ថ្លែង ថា ‹ ចេះ ឯង ឱ្យ ក្រែង គេ ›។ ហើយ អ្វី ដែល ជា សម័យ ក៏ វា មិន ពិត ជា ល្អ ប្រសើរ ជាង អ្វី ដែល ជា បុរាណ នោះ ដែរ, តែ អ្វី ដែល ជា ទំនៀមទំលាប់ ហួស សម័យ ហើយ មិន សមរម្យ ក៏ គួរ ចោល ទៅ ចុះ តែ ក៏ មិន ត្រូវ យក អ្វី មក ប្ដូរ ដោយ គ្មាន ការគិតពិចារណា នោះ ដែរ។ នៅ ក្នុង សៀវភៅ របស់ លោក ប៊ុណ្ណចន្ទ ម៉ុល គាត់ បាន លើកឡើង ចរិត ខ្មែរ មួយ ចំនួន ដែល គាត់ ទុក ជា ចរិត អវិជ្ជមាន ដូច យ៉ាង : *គំនិត ‹ មាន តែ អញ ›, គំនិត លួច យក យោបល់ គេ, គួរ តែ ពីព្រោះ សាកសួរ, គំនិត ខ្លាច នយោបាយ, គំនិត សង សឹក សួរពូជ, គំនិត ផ្ដាច់ផ្ដាល, គំនិត លោភ ពង្រេចពង្រើល, គំនិត ចង្រៃ, ចូល ប្រយ័ត្ន មនុស្ស ជំនិត, មេអំបៅ, ស្វា ពាក់ ម*

*ក្លុង, បើ មិន ច្បាស់ កុំ អះអាង, គួរ និយាយ តែ រឿង មាន ប្រយោជន៍, គួរ ពត់ ឈើ ពី នៅ តូច, គួរ ស្ទួន គ្រប់ លក្ខណៈ ខ្មែរ ខ្លះ ផង, គម្បី ម៉ឺងម៉ាត់ ឱ្យ បាន យូរអង្វែង។*

តើ ចរិត ទាំងឡាយ នោះឬ ដែល ខ្មែរ ត្រូវ កែទម្រង់ ដើម្បី ប្តូរ ចិត្តគំនិត សំរាប់ កសាង ប្រជាជាតិ ?

នៅ ក្នុង ការសាកល្បង ពិចារណា របស់ ខ្ញុំ, ខ្ញុំ មិន យក គំនិត អវិជ្ជមាន ខាង លើ នេះ មក ពិពណ៌នា លម្អិត នោះ ទេ, សូម អ្នកអាន អាន សៀវភៅ របស់ លោក ប៊ុណ្ណចន្ទ ម៉ុល ដោយ ខ្លួន ឯង។ ហើយ ក៏ ខ្ញុំ គ្មាន ចម្លើយ លើ សំនួរ ថា តើ ខ្មែរ អាច ធ្វើ អ្វី ខ្លះ សំរាប់ កសាង ប្រជាជាតិ ឱ្យ បាន ប្រសើរ ជាង ខ្មែរ ពី ជំនាន់ មួយ ទៅ ជំនាន់ មួយ ទៀត។ ចិត្តគំនិត ស្វែង រក ស្នាដៃ ពិសេស និង គុណករ ជា និច្ចភាព ដែល ជា វប្បធម៌ នៃ ឧត្តម ភាព វា ជា ចលករ នៃ ការរីកចំរើន សំរាប់ ប្រជាជាតិ ខ្មែរ។ តែ បើ ខ្មែរយើង មិន ធ្វើ កំណែទម្រង់ ចិត្តគំនិត អវិជ្ជមាន ឬក៏ តាម ការកែទម្រង់ សាកល ដែល បាន រៀបរាប់ ខាង លើ នេះ ឬក៏ ស្វែង រក ផ្លូវ ផ្ទាល់ ខ្លួន តែ ផ្អែក លើ មូលដ្ឋាន លទ្ធិប្រជាធិបតេយ្យ សេរី ដែល ជា ចរន្ត បាន បញ្ជាក់ រួចហើយ ពី ប្រសិទ្ធភាព របស់ ខ្លួន សម្រាប់ វឌ្ឍនភាព នៃ សង្គម នៅ លើ ពិភពលោក គឺ ប្រជាជាតិ ខ្មែរ នឹង ក្លាយ ទៅ ជា ទឹកដី របស់ ប្រទេស ជិតខាង នៅ ពេល អនាគត ដ៏ ខ្លី មួយ ជា ពុំខាត។ ដូច លោក និង លោកស្រី Guy Porée និង Evelyne Maspero និង លោក

Paul Doumer រិះគន់ លើចរិត ខ្មែរ ថា ជា ជាតិសាសន៍ មាន ចរិត អវិជ្ជមាន ដែល នាំ ឱ្យ ប្រជាជាតិ ខ្មែរ ចុះ ដុនដាប់ ជា និច្ច នៅ ចំពោះ មុខ ការរីកចំរើន នៃ ប្រទេស ជិតខាង ខ្លួន គឺ ប្រទេស សៀម និង យួន។ បើ ខ្មែរយើង ឆ្លុះមើល ដោយ ខ្លួន ឯង លើ សង្គម និង ស្ថានភាព នៃ ប្រជាជាតិ ខ្មែរ សព្វថ្ងៃ, សួរ ថា តើ ការតិទៀន នេះ វា ត្រឹមត្រូវ ដែរ ឬទេ ? លោក ប៉ុនចន្ទ ម៉ុល ក្តី លោក នួន ឃឿន ក្តី លោក ធ្លាប់ បាន បើក ទ្វារ នៃ ចិត្តគំនិត វិជ្ជាមាន ខ្មែរ រួច មកហើយ តែ ហាក់បី សព្វថ្ងៃ នេះ ខ្មែរយើង លះបង់ចោល សិទ្ធិ ជា ពលរដ្ឋ ប្តូរ នឹង ការរស់នៅ ក្នុង ទុក្ខវេទនា ក្នុង សន្តិភាព មួយ ដែល គ្មាន ទស្សនវិស័យ នៃ អនាគត។ គំនិត នេះ វា ជា សេចក្តី សន្និដ្ឋាន ផ្ទាល់ របស់ ខ្ញុំ។

សូម ឱ្យ ប្រជាជាតិ ខ្មែរ រស់ នៅ ជា ខ្មែរ ឱ្យ បាន គង់វង់ ជា និច្ច នៅ ក្នុង ការរីកចំរើន គ្រប់ វិស័យ នៃ សង្គម៕

**ចប់**